ឆ្នាំទី២ លេខ០០៨ ចេញផ្សាយប្រចាំខែមីនា ឆ្នាំ២០១២

# ព្រឹត្តិបត្រការងារ
# Labour Bulletin

ជាស្ពានឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ⌖ Gateway to ♦Jobs ♦Labour Forces ♦Labour Market Information



រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល


- ជំនាញមូលដ្ឋានគ្រឹះ( ត ) [ទំព័រ៥]
- ការបង្កើតបណ្តាញសង្គម និងការស្វែងរកការងារធ្វើ [ទំព័រ២០]
- អានុភាពនៃកិច្ចសន្យាការងារ [ទំព័រ៣១]
- [ទំព័រ៣៥] ព័ត៌មានទីផ្សារការងារនៅកម្ពុជា
- [ទំព័រ៤០] ព័ត៌មានជ្រើសរើសបុគ្គលិក
- [ទំព័រ៥០] បទពិសោធន៍ និងជោគជ័យក្នុងជីវិតសិក្សា

## ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## ព្រឹត្តិបត្រការងារ

# មាតិកា

ទំព័រ


◈ **មគ្គុទេសក៍អាជីព** ៥

➢ ជំនាញមូលដ្ឋានគ្រឹះ (Fundamental Skills) (ត...) ៥

◘ *ជំនាញ ៣៖ ការប្រើលេខនព្វន្ត [ទំព័រ ៥]* ◘ *ជំនាញ ៤៖ ការស្ដាប់ [ទំព័រ ៧]*

➢ ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប ១០

◘ *អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្ម (Agriculture Scientists) [ទំព័រ ១០]* ◘ *អ្នកឯកទេសគីមី (Chemists) [ទំព័រ ១២]* ◘ *គិលានុបដ្ឋាក (Nurses) [ទំព័រ ១៤]* ◘ *បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយ (Campaign Workers) [ទំព័រ ១៦]* ◘ *អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ (Database Specialists) [ទំព័រ ១៨]*

➢ ការរៀបចំមូលដ្ឋានគ្រឹះក្នុងការស្វែងរកការងារធ្វើ

◘ *ការបង្កើតបណ្ដាញសង្គម (Social Networking) និងការស្វែងរកការងារធ្វើ* ២០

➢ ការរៀបចំខ្លួនសម្រាប់ចូលសម្ភាសន៍ការងារ

◘ *ប្រភេទនៃសំណួរ និងរបៀបឆ្លើយសំណួរក្នុងពេលសម្ភាសន៍ការងារ៖* ២៧

- សំណួរអំពីការយល់ដឹងរបស់បេក្ខជនចំពោះកិច្ចការជំនួញ [ទំព័រ ២៧]
- សំណួរអំពីភាពជាអ្នកដឹកនាំរបស់បេក្ខជនក្នុងការបំពេញការងារ [ទំព័រ ២៩]

◈ **លិខិតបទដ្ឋានគតិយុត្តការងារ** ៣១

➢ អានុភាពនៃកិច្ចសន្យាការងារ ៣១

◈ **ព័ត៌មានទីផ្សារការងារនៅកម្ពុជា** ៣៥

➢ ទិន្នន័យសង្ខេបសំខាន់ៗស្ដីពី អ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ៣៥

◈ **ព័ត៌មានជ្រើសរើសបុគ្គលិក** ៤០

➢ ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែមេសាដែលបានប្រមូលដោយ ទ.ជ.ម.ក ៤០

◈ **បទពិសោធន៍ និងជោគជ័យក្នុងជីវិតសិក្សា** ៥០

➢ *បទសម្ភាសន៍ជាមួយ កញ្ញា **ខេង សុជាតា** បេក្ខជនជាប់អាហារូបករណ៍ផ្នែកជំនាញបច្ចេកទេសអគ្គិសនី របស់ក្រុមហ៊ុន C.I.I.D.G ទៅសិក្សានៅប្រទេសចិន* ៥០

◈ **ព័ត៌មាន និងសកម្មភាព**

➢ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្ដុះបណ្ដាល.... ៥៣

◈ **ផ្សេងៗ**

◈ ទំព័រ «កំសាន្ត និងប្រាជ្ញា» ៥៦


*ក្របមុខ: ទីផ្សារការងារ និងវិស័យទ្រទ្រង់សេដ្ឋកិច្ច*

*ក្របក្រោយ: ខ្សែនភាពឆ្ពោះទៅអនាគត*


# ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន

ឯកឧត្តម ប៉ុក ប៉ាន់

ឯកឧត្តម ឡៅ ហ៊ីម

ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក សាម៉េន សុខា

**និពន្ធនាយករង**

លោក ហៃ ហ៊ុនឡេង

លោក សួង សង្វារុទ្ធី

លោក ទូច សុផាត

**ការីនិពន្ធ**

លោក សុកខុន ដារីដ

លោក តាំង ហ៊ាងថារិទ្ធ

លោកស្រី លី រ៉ូចចេង

លោក ខាន់ ចិន្ដា

លោក តាំង ផេងរិទ្ធី

លោក សុជាតិ កញ្ញារិទ្ធ

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក ខេង សុគន្ធា

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវរស្មី

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូរ ឧស្សាហ៍រចនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី

**អ្នកកែសម្រួលអក្ខរាវិរុទ្ធ**

មន្ត្រី ទីភ្នាក់ងារជាតិមុខរបរ និងការងារ

# សួស្ដីឆ្នាំថ្មី ឆ្នាំ២០១២

## សូមគោរពប្រសិទ្ធពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរ
## ជូនចំពោះ



### សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
### សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
### សម្ដេចពញាចក្រី ហេង សំរិន

ដែលជាអគ្គមគ្គុទ្ទេសក៍ និងប្រមុខដឹកនាំដ៏ឆ្នើមនៃព្រឹទ្ធសភា រាជរដ្ឋាភិបាល រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក**
**ព.ស ២៥៥៦ ត្រូវនឹងគ.ស ២០១២**

សូមបួងសួងដល់វត្ថុស័ក្ដិសិទ្ធក្នុងលោក និងទេវតាឆ្នាំថ្មីព្រះនាម កិមិរាទេវី តាមជួយបីបាច់ថែរក្សាសម្ដេចទាំងបីប្រកបដោយពលានុភាពខ្លាំងក្លា
បញ្ញាញាណឈ្លាសវៃ សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីដឹកនាំប្រទេស និងប្រជាពលរដ្ឋកម្ពុជា
ឆ្ពោះទៅកាន់ភាពសម្បូរណ៍រុងរឿង ការអភិវឌ្ឍ សន្តិភាព សុភមង្គល និងសេចក្ដីចម្រុងចម្រើនជានិច្ចនិរន្ដ៍ៗ
ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងដ៏ឈ្លាសវៃរបស់សម្ដេចទាំងបី
បានធ្វើឱ្យប្រទេស និងប្រជាពលរដ្ឋកម្ពុជាទទួលបាននូវ
វឌ្ឍនភាព សម្បូរណ៍សប្បាយ ជីវភាពធូរធារ សន្តិភាពពេញលេញ ព្រមទាំងមានមោទនភាពជាតិខ្ពស់ៗ

គោរពជូនពរដោយសេចក្ដីស្មោះអស់ពីដួងចិត្តពី
ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

## សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ
## ជូនចំពោះ



**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក ព.ស ២៥៥៦ ត្រូវនឹងគ.ស ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក និងទេវតាឆ្នាំថ្មី ព្រះនាម គិមិរាទេវី ជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ដែលជាកុលបុត្រខ្មែរដ៏មានប្រាជ្ញាឈ្លាសវៃមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុង ការចូលរួមចំណែកដឹកនាំ រាជរដ្ឋាភិបាល និងប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ

សូមឯកឧត្តមបណ្ឌិតសភាចារ្យ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី

ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

**សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ**
**ជូនចំពោះ**



**ឯកឧត្តមបណ្ឌិត វង សូត**
រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
**ក្នុងឱកាសដ៏មហានក្ខត្តឬក្សនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក**
**ព.ស ២៥៥៦ ត្រូវនឹង គ.ស ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក និងទេវតាឆ្នាំថ្មីព្រះនាម កិមិរាទេវី ជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់ ឯកឧត្តមបណ្ឌិត **វង សូត** ដែលជាកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុងការចូលរួមចំណែកដឹកនាំ ប្រទេសកម្ពុជាឆ្ពោះទៅកាន់នាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ

សូមឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺៈ
អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី
ប្រធានទីផ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# សួស្តីឆ្នាំថ្មី ឆ្នាំ២០១២

## សូមគោរពប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ
## ជូនចំពោះ



## ឯកឧត្តមបណ្ឌិត ពេជ សោភ័ន

រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

និងជាអនុប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

**ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក**
**ព.ស ២៥៥៦ ត្រូវនឹងគ.ស ២០១២**

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក និងទេវតាឆ្នាំថ្មីព្រះនាម កិមិរាទេវី ជួយប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការជូនដល់ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** ដែលជាកុលបុត្រខ្មែរដ៏បញ្ញាញាណឈ្លាសវៃមួយរូប បានចំណាយកម្លាំងកាយចិត្តក្នុងការចូលរួមចំណែកដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងថ្កុំថ្កើងៗ

សូមឯកឧត្តមបណ្ឌិត និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារពើបប្រទះតែពុទ្ធពរទាំងបួនប្រការគឺៈ

អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយៗ

គោរពជូនពរដោយសេចក្តីស្មោះអស់ពីដួងចិត្តពី

ប្រធានទីផ្នាក់ងារជាតិមុខរបរ និងការងារ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់




មគ្គុទេសក៍អាជីព

# ជំនាញមូលដ្ឋានគ្រឹះ (ត..)

## FUNDAMENTAL SKILLS

នៅក្នុងការផ្សាយលេខ ០០៧ ព្រឹត្តិបត្រការងារបាន លើកយកមកបង្ហាញជូនមិត្តអ្នកអាន និងប្រិយមិត្ត ទាំងអស់អំពីជំនាញមូលដ្ឋានគ្រឹះ ដែលត្រូវប្រើនៅក្នុងការ បំពេញការងារ ឬប្រើក្នុងកិច្ចការប្រចាំថ្ងៃ។ កាលនោះ យើងខ្ញុំ បានបកស្រាយជូនជាលំដាប់លំដោយនូវជំនាញពីរប្រភេទគឺ ជំនាញនៃការអាន និងជំនាញនៃការសរសេរ។

នៅក្នុងការផ្សាយលេខនេះ យើងខ្ញុំសូមនាំមកបង្ហាញ ជូនមិត្តអាន និងប្រិយមិត្តទាំងអស់នូវជំនាញមូលដ្ឋានចំនួន ពីរផ្សេងទៀត ដែលត្រូវការប្រើក្នុងជីវភាពប្រចាំថ្ងៃគឺ ជំនាញ ក្នុងការប្រើលេខនព្វន្ត (Working with numbers) និងជំនាញ ក្នុងការស្តាប់ (Listening)។

អាស្រ័យហេតុនេះ សូមប្រិយមិត្ត និងមិត្តអ្នកអានទាំង អស់តាមដានស្វែងយល់នូវជំនាញទាំងពីរនេះ ដើម្បីទុកជា ចំណេះ និងការប្រតិបត្តិសម្រាប់ការងារផ្ទាល់របស់ខ្លួន ដែល មានបរិយាយជូនជាលំដាប់លំដោយដូចតទៅ៖

| ជំនាញ ៣ | ការប្រើលេខនព្វន្ត (Working with numbers) |
| --- | --- |

គណិតវិទ្យាគឺមានជាប់ពាក់ព័ន្ធជាពិសេសជាមួយ ការប្រើប្រាស់លេខ។ គេសង្កេតឃើញថា ការប្រើ-ប្រាស់លេខគឺច្រើនទាក់ទិនទៅនឹងការគន់គូរលេខ (គិតលេខ) ដើម្បីជួយនរណាម្នាក់ក្នុងការដោះស្រាយបញ្ហា ឬក៏ស្ថាន-ការណ៍អ្វីមួយ។ ជាទូទៅ ការប្រើលេខ និងក្បួនគណិតវិទ្យា អាចចាប់ផ្តើមចេញពីការគិតលេខបែបសាមញ្ញៗ រហូតដល់ ការគិតគូរបែបស្មុគស្មាញ និងមានការលំបាកទាក់ទងនឹងការ ព្យាករណ៍អំពីព្រឹត្តិការណ៍អ្វីមួយ ដែលអាចកើតមានឡើង។ ក្នុងន័យនេះ ការប្រើប្រាស់លេខ ឬគណិតវិទ្យាបានកំពុងចូល រួមចំណែកយ៉ាងសកម្ម នៅក្នុងការជួយមនុស្សនានាឱ្យស្គាល់ និងអាចបង្ហាញគំនិតផ្សេងអំពីបរិយាកាសជុំវិញខ្លួន និងអំពី ពិភពលោកទាំងមូលផងដែរ។

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញអានឯកសារឈ្មោះ Younger Person's Career Skills Handbook. JIST Publishing, 2006. ដែលមានតម្កល់នៅក្នុង «**បណ្ណាល័យការងារ**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ។*

តទៅទំព័របន្ទាប់

ជំនាញក្នុងការប្រើលេខនព្វន្ត គឺសំដៅដល់លទ្ធភាពដែលអាចបំពេញកិច្ចការនានាមានជាអាទិ៍៖

- ការគិតលេខតាមក្បួនមូលដ្ឋានរួមទាំងលេខគត់ និងលេខប្រភាគ
- ការប៉ាន់ប្រមាណតាមក្បួនគណិតវិទ្យាដោយមិនចាំបាច់គិតលេខ
- ការរៀបចំព័ត៌មានដោយមានបង្ហាញពីតារាង ឬក្រាហ្វិកទិន្នន័យ
- ការជ្រើសរើសយកក្បួនគណិតវិទ្យាខ្លះមកប្រើក្នុងការដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងការងារ ឬក្នុងជីវភាព

## # អាជីពដែលត្រូវការជំនាញនៃការគិតលេខនព្វន្ត

គេកត់សម្គាល់ឃើញថា បុគ្គលិក ឬអ្នកបំពេញការងារទាំងឡាយនឹងបំពេញការងារបានល្អប្រសើរ ប្រសិនពួកគេមានជំនាញមូលដ្ឋាន ឬជំនាញជាក់លាក់ក្នុងការប្រើប្រាស់លេខដើម្បីគន់គូរ និងដោះស្រាយបញ្ហានានាដែលជួបប្រទះក្នុងវង្វង់ការងារ។

ទោះជាយ៉ាងដូច្នោះក្តី នៅក្នុងបរិបទការងារគេសង្កេតឃើញមានជំនាញជាក់លាក់មួយចំនួនដែលត្រូវការប្រើប្រាស់ក្បួនគណិតវិទ្យា និងលេខនព្វន្តដោយខានពុំបាន ដូចជា៖

- គណិតវិទូ
- អ្នកវិទ្យាសាស្ត្រ
- វិស្វករ
- គណនេយ្យករ
- អ្នកស្ថិតិ
- ស្ថាបត្យករ
- វិស្វករផ្នែកកម្មវិធីកុំព្យូទ័រ និង
- អ្នកប៉ាន់ស្មានតម្លៃ ជាដើម។



## # ហេតុអ្វី និយោជកត្រូវការជំនាញបែបនេះ?

ការពិត មានការងារជាច្រើនប្រភេទដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយការប្រើលេខតាមបែបគណិតវិទ្យា។ ឧទាហរណ៍ ការងារផ្នែកគណនេយ្យ វិស្វករ អ្នកប្រឹក្សាផ្នែកការវិនិយោគ និងបុគ្គលិកផ្នែកធនាគារ ជាដើម។ យ៉ាងណាមិញក៏នៅមានការងារប្រភេទខ្លះទៀត ដែលតម្រូវឱ្យប្រើប្រាស់នូវក្បួនលេខនព្វន្តក្នុងការសម្រេចលទ្ធផលការងារ។ បានន័យថាគ្រាន់តែប្រើវិធីគិតលេខងាយៗដើម្បីជួយសម្រួលការងារ។

នៅក្នុងវិស័យពាណិជ្ជកម្ម និងធុរកិច្ចវិញ គេប្រើប្រាស់គណិតវិទ្យាទៅលើកិច្ចការច្រើនជំពូក និងស្ទើរគ្រប់ពេល។ ឧទាហរណ៍ ការរៀបចំតារាងតម្លៃ បូកដកតម្លៃនៅក្នុងវិក្កយបត្រ និងការគិតពីភាគរយនៃផលិតផលដែលបានលក់ទៅក្នុងទីផ្សារ ឬក៏រៀបចំពីតារាងក្រាហ្វិកដើម្បីបង្ហាញពីនិន្នាការរបស់ទីផ្សារ ជាដើម។

ហេតុនេះ ការងារភាគច្រើនតម្រូវឱ្យបុគ្គលិកធ្វើកិច្ចការពាក់ព័ន្ធនឹងលេខ។ ការងារនោះអាចប្រើប្រាស់វិធីគិតលេខតាមក្បួនសាមញ្ញៗ ឬក៏ការប្រើគំនិត និងវិធីលំបាកៗក្នុងការគិតលេខ។ ម្យ៉ាងទៀត បុគ្គលិកក្នុងការងារគួរមានចំណេះដឹងផ្នែកការបញ្ចូលកម្មវិធី និងប្រើប្រាស់កម្មវិធីគិតលេខក្នុងប្រព័ន្ធកុំព្យូទ័រផងដែរ។

## # ការបង្កើតជំនាញនៃការគិតលេខនព្វន្ត

ជម្មតា អ្នកសិក្សាគណិតវិទ្យានៅក្នុងសាលា ប៉ុន្តែការសិក្សាពេលនោះអាចមានលក្ខណៈជាទ្រឹស្តី និងមិនសូវមានការអនុវត្ត។ ដូច្នេះ អ្នកអាចបង្កើនចំណេះនេះតាមរយៈការធ្វើការ និងសកម្មភាពមួយចំនួនផ្សេងទៀត៖


តទៅទំព័របន្ទាប់

### ការបង្កើនជំនាញតាមរយៈការអប់រំ៖

- ជ្រើសរើសរៀនមុខវិជ្ជាពិជគណិត និងធរណីមាត្រ។ ចំណោះផ្នែកពិជគណិតនឹងជួយក្នុងការគិតលេខ ចំណែកធរណីមាត្រវិញនឹងជួយក្នុងការប្រើក្បួនវាស់វែង និងគណនាអំពីទម្រង់របស់វត្ថុ ឬរូបរាងផ្សេងៗ។
- រៀនមុខវិជ្ជាផ្នែកកុំព្យូទ័រ ដែលមានកម្មវិធីពាក់ព័ន្ធរូបមន្តក្នុងការគណនាលេខ។
- រៀនមុខវិជ្ជាផ្នែកគណនេយ្យ ដើម្បីចេះគណនាពីការធ្វើចំណូលចំណាយ និងពាក់ព័ន្ធលុយកាក់។

### ការបង្កើនជំនាញតាមរយៈសកម្មភាពផ្សេងៗ៖

- រក្សាទុកទិន្នន័យអំពីការចំណាយផ្ទាល់របស់ខ្លួន និងគណនាថវិកាប្រចាំខែ។
- ចូលរួមក្នុងសកម្មភាព ដែលមានពាក់ព័ន្ធជាមួយជំនាញគណិតវិទ្យា ឧទាហរណ៍ ចូលរួមក្លឹបដែលធ្វើការផ្នែករៀបគម្រោង ឬធ្វើបញ្ជី ឬក៏ស្ម័គ្រចិត្តធ្វើជាហិរញ្ញិកនៅក្នុងក្លឹបដើម្បីមានឱកាសអាចអនុវត្តនូវជំនាញនោះបាន។
- តាមដានសភាពការណ៍តម្លៃរបស់ទីផ្សារមូលប័ត្រតាមរយៈប្រព័ន្ធអ៊ិនធើណិត ហើយប្រើប្រាស់គំនូរក្រាហ្វិកក្នុងការកំណត់ពីតម្លៃឡើងចុះរបស់ទីផ្សារមូលប័ត្រ។
- គួរអានសៀវភៅ និងឯកសារនានាពាក់ព័ន្ធគណិតវិទ្យា និងវេបសាយគណិតវិទ្យាឱ្យបានច្រើន។



## ជំនាញ ៤ ការស្តាប់

(Listening)

*នៅក្នុងពេលប្រាស្រ័យទាក់ទងគ្នា ជាទូទៅមានពាក់ព័ន្ធនឹងសកម្មភាពសំខាន់ៗពីរគឺ: ភាគីម្ខាងជាអ្នកផ្ញើដំណឹង និងភាគីម្ខាងទៀតជាអ្នកទទួលព័ត៌មាន ហើយធ្វើការឆ្លើយតប។ នៅក្នុងខណៈពេលដែលការបញ្ជូនដំណឹងត្រូវបានធ្វើឡើងជាពាក្យសម្តី នោះភាគីខាងទទួលព័ត៌មាននឹងត្រូវស្តាប់នូវខ្លឹមសារនោះ។ ការពិត ការស្តាប់ពុំមែនជាការងាយនោះទេ អ្នកត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះពាក្យពេចន៍ដែលបាននិយាយ ជៀសវាងការភាន់ច្រឡំ ឬយល់មិនបានច្បាស់ពីអត្ថន័យ ដែលអាចបង្កឱ្យមានបញ្ហា ឬការយល់ច្រឡំផ្សេងៗ។*

*ជំនាញក្នុងការស្តាប់ គឺសំដៅដល់លទ្ធភាពដែលអាចបំពេញកិច្ចការនានាមានជាអាទិ៍៖*

- ផ្តោតការយកចិត្តទុកដាក់ និងយល់អំពីពាក្យពេចន៍ដែលបាននិយាយ រួមទាំងសម្លេងផ្សេងៗ។
- កត់សម្គាល់ និងយល់អំពីអត្ថន័យនៃភាសាបែបកាយវិការបស់អ្នកដែលកំពុងនិយាយ និងរបៀបនៃការលើកដាក់សម្លេង។
- ឆ្លើយតបទៅកាន់អ្នកដែលកំពុងនិយាយដោយក្តីគួរសម និងត្រឹមត្រូវតាមរឿងហេតុ។

### អាជីពដែលត្រូវការជំនាញនៃការស្តាប់

*ទោះបីជា បុគ្គលិកកម្មករក្នុងកិច្ចការនានាត្រូវមានជំនាញប្រភេទនេះ ដើម្បីបំពេញការងារឱ្យបានល្អ និងមានភាពរលូនក៏ដោយ គេសង្កេតឃើញមានការងារមួយចំនួនដែលតម្រូវឱ្យមានជំនាញនេះជាចាំបាច់ ដូចជា៖*

- អ្នកតំណាងផ្នែកសេវាកម្មអតិថិជន
- អ្នកព្យាបាលជម្ងឺផ្នែកពេគចិត្ត
- អ្នកសារព័ត៌មាន
- អ្នកបកប្រែភាសា
- មន្រ្តីផ្នែកសេវាសាធារណៈ
- អ្នកបម្រើផ្នែកម្ហូបអាហារ
- វេជ្ជបណ្ឌិត
- បុគ្គលិកផ្នែកសេវាធនាគារ
- អ្នកឯកទេសខាងជួសជុល ថែទាំកុំព្យូទ័រ និង
- វេជ្ជបណ្ឌិតផ្នែកចេញវេជ្ជបញ្ជា ។ល។



## ហេតុអ្វី និយោជកត្រូវការជំនាញបែបនេះ?

និយោជកតែងមានការលើកទឹកចិត្ត និងកោតសរសើរចំពោះបុគ្គលិកណាដែលអាចស្តាប់បានយ៉ាងប្រុងប្រយ័ត្នអំពីសេចក្តីណែនាំ ការហ្វឹកហ្វឺន អតិថិជន បុគ្គលិកដទៃ និងស្តាប់ពីថ្នាក់ដឹកនាំរបស់ខ្លួន។ ផ្ទុយទៅវិញ បុគ្គលិកដែលមិនសូវផ្តោតការយកចិត្តទុកដាក់ស្តាប់ក្នុងពេលបំពេញកិច្ចការ ភាគច្រើនបានធ្វើនូវកំហុសតាមរយៈការភាន់ច្រឡំ។ បានន័យថាពួកគេមិនអាចស្តាប់យល់នូវការណែនាំ មិនយល់ពីដំណើរការ និងគោលនយោបាយ។ យ៉ាងណាមិញ បុគ្គលដែលពូកែក្នុងការស្តាប់តែងយល់បានយ៉ាងច្បាស់នូវអ្វីដែលត្រូវធ្វើ និងដឹងពីតម្រូវការរបស់ការងារ ហើយទំនងជាប្រព្រឹត្តិនូវកំហុសតិចតួចបំផុត។

ក្រៅតែពីការស្តាប់ឮអ្វីដែលគេបាននិយាយ អ្នកពូកែស្តាប់តែងតែយល់បានល្អ ហើយបកស្រាយនូវព័ត៌មាន និងឆ្លើយតបត្រលប់វិញបានដោយប្រសើរ និងដ៏ត្រឹមត្រូវ។ ឧទាហរណ៍ នៅក្នុងស្ថានភាពមួយនៃមុខជំនួញ ប្រសិនអតិថិជនម្នាក់បាននិយាយទៅកាន់បុគ្គលិក ឬអ្នកទទួលខុសត្រូវផ្នែកលក់ (salesperson) ថាគាត់ (អតិថិជន) មិនសប្បាយចិត្តចំពោះសេវាដែលកំពុងបម្រើជូន បានន័យថាបុគ្គលិកម្នាក់នោះត្រូវរិះរកវិធីផ្សេងៗ ដើម្បីធ្វើឱ្យអតិថិជនម្នាក់នោះមានក្តីរីករាយ និងពេញចិត្តចំពោះសេវាកម្មជាថ្មីម្តងទៀត។ នៅក្នុងស្ថានភាពបែបនេះបុគ្គលិកផ្នែកលក់ត្រូវយកចិត្តទុកដាក់ និងព្យាយាមស្តាប់នូវរាល់ពាក្យពេចន៍ ឬក៏ការសម្តែងក្តីមិនពេញចិត្តដែលភ្ញៀវកំពុងរៀបរាប់។ បុគ្គលិកផ្នែកលក់ ក៏គួរកត់សម្គាល់ផងដែរនូវភាសា និងសម្លេងដែលភ្ញៀវកំពុងបញ្ចេញតើជាការខឹងសម្បារខ្លាំង ឬក៏ជាការបន្ទោសធម្មតា។ ក្រៅពីនេះ ត្រូវកត់សម្គាល់នូវភាសាកាយវិកា (body language) និងសកម្មភាពដែលអាចបង្ហាញពីការធុញទ្រាន់ និងម៉ូម៉ៅដោយសម្តែងចេញមកពីក្នុងចិត្ត និងអ្វីដែលកំពុងគិត។



ការស្តាប់បានល្អ គឺមិនគ្រាន់តែមានតួនាទីសំខាន់នៅក្នុងការងារ និងជួយឱ្យអ្នកបំពេញកិច្ចការបានត្រឹមត្រូវតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយអ្នកឱ្យមានទំនាក់ទំនង និងងាយសម្របសម្រួលជាមួយអ្នកដទៃទៀតផង។ ប្រសិនបើ អ្នកស្តាប់នូវការរៀបរាប់របស់បុគ្គលិកនានានៅក្នុងកន្លែងការងារ អ្នកអាចយល់ពីអារម្មណ៍ និងទស្សនៈគំនិតរបស់ពួកគេដែលចង់សម្តែងពីអ្វីមួយ ដូចជា ការបារម្ភ ឬមិនសប្បាយចិត្តចំពោះរឿងហេតុអ្វីមួយ។ អ្នកដែលពូកែខាងស្តាប់នឹងជួយពួកគេឱ្យយល់ពីដើមហេតុរបស់បញ្ហា ហើយអាចដោះ

ស្រាយបញ្ហានោះបានទៀតផង។ ប្រសិនអ្នកស្ថិតនៅក្នុងតំណែងជាអ្នកគ្រប់គ្រងក្នុងស្ថាប័ន ឬក្រុមហ៊ុន អ្នកអាចស្ដាប់នូវរឿងហេតុ ឬការបកស្រាយរបស់បុគ្គលិកទាំងពួង ហើយព្យាយាមស្វែងយល់អំពីបញ្ហានីមួយៗ និងលើកទឹកចិត្តពួកគេឱ្យខិតខំធ្វើការងារប្រកបដោយភាពសប្បាយរីករាយក្នុងចិត្ត។

## ការបង្កើតជំនាញនៃការស្ដាប់

ជាក្រឹត្យក្រមធម្មជាតិ ដែលមនុស្សបានចាប់ផ្ដើមហាត់រៀនស្ដាប់តាំងពីពេលនៅជាទារកមកម៉្លេះ។ បន្ទាប់មក អ្នកបានហ្វឹកហាត់ការស្ដាប់ជារៀងរាល់ថ្ងៃក្នុងការទំនាក់ទំនងជាមួយមនុស្សទូទៅ។ ប៉ុន្តែ អ្នកអាចបំប៉នការស្ដាប់តាមវិធីផ្សេងៗដូចជា៖

### ការបង្កើនជំនាញតាមរយៈការអប់រំ៖

- អាចស្វែងរករៀនមុខវិជ្ជាផ្នែកការនិយាយ ឬធ្វើបទបង្ហាញ ឬក៏របៀបជាល្ខោននិយាយ ដើម្បីអាចឱ្យអ្នកហាត់និយាយ និងស្ដាប់នូវអ្វីដែលអ្នកដទៃបាននិយាយ។
- ហាត់ស្ដាប់នៅក្នុងថ្នាក់រៀន ហើយព្យាយាមកត់ចំណាំនូវចំណុចសំខាន់ៗដើម្បីងាយចាំ និងប្រើនៅពេលក្រោយ។
- រៀនភាសាបរទេសប្លែកៗ ហើយហាត់ស្ដាប់នៅពេលអ្នកដទៃនិយាយភាសាបរទេស ដើម្បីជួយឱ្យអ្នកមានការផ្ដោតអារម្មណ៍ ពីព្រោះការគិតរបស់អ្នកនឹងមានភាពសកម្ម ដោយហេតុថាអ្នកត្រូវខិតខំស្ដាប់ និងបកប្រែក្នុងចិត្តនូវពាក្យសព្ទ ឬឃ្លាប្រយោគនីមួយៗ។

### ការបង្កើនជំនាញតាមរយៈសកម្មភាពផ្សេងៗ៖

- ស្ដាប់មេរៀនជាសម្លេង (audio books) ឬការផ្សព្វផ្សាយតាមរលកធាតុអាកាស ហើយត្រូវផ្ដោតចំពោះអ្វីដែលគេនិយាយ។
- ចូលរួមសកម្មភាពក្នុងក្លឹបផ្នែកជជែកពិគ្រោះមតិ និងពិភាក្សាអំពីអត្ថបទ ឬសៀវភៅ។
- ប្រសិនអ្នកមានបញ្ហាក្នុងការស្ដាប់ សូមកុំរួញរាក្នុងការសាកសួរបញ្ជាក់ឡើងវិញអំពីការយល់របស់អ្នកទៅកាន់អ្នកដែលកំពុងនិយាយ (speaker) ដើម្បីឱ្យគេពន្យល់ជាថ្មី។
- សិក្សាពីភាសាកាយវិការ សម្លេង និងរលកសម្លេងរបស់មនុស្ស ដើម្បីជាអាចទាញជាសេចក្ដីសន្និដ្ឋានអំពីអត្ថន័យពីអ្វីដែលគេបាននិយាយ។
- ព្យាយាមឆ្លើយតបទៅកាន់អ្នកនិយាយ ដោយចម្លើយត្រឹមត្រូវ។ ប្រសិនអ្នកមិនបានស្ដាប់ដោយជាក់លាក់ទេនោះ ការឆ្លើយរបស់អ្នក ក៏ប្រាកដជាមិនមានភាពត្រឹមត្រូវនោះដែរ។

«សូមអ្នកសង្កេតមើលថា ការនិយាយរបស់អ្នកបានបញ្ចប់មុនពេលដែលអ្នកស្ដាប់បង្ហាញពីឥរិយាបថធុញទ្រាន់ ឬលែងចង់ស្ដាប់»

សូមប្រិយមិត្ត និងមិត្តអ្នកអានរង់ចាំអានក្នុងការផ្សាយលេខក្រោយ ស្ដីពីជំនាញមូលដ្ឋានផ្សេងៗទៀត ដោយមេត្រី!



ការពិចារណាអំពីការងារជាអាជីព

# ការពិនិត្យ និង ជ្រើសរើស អាជីព ឬ ការងារដែលសមស្រប

## អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្ម

( Agricultural Scientists )

### សង្ខេបអំពីជំនាញ

អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មធ្វើការងារ៖

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- បង្កើត ឬបង្កើនប្រព័ន្ធដំណើរការ

### ជំនាញដែលត្រូវការប្រើ៖

- ការដោះស្រាយបញ្ហា
- ការពិចារណា ឬធ្វើកិច្ចការប្រកបដោយហេតុផល
- ការគិតប្រកបដោយភាពច្នៃប្រឌិត

## តើអ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មបំពេញកិច្ចការអ្វីខ្លះ?

ជាទូទៅ អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មធ្វើការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិ និងសត្វនៅក្នុងបរិដ្ឋានធម្មជាតិដែលគេរស់នៅ។ ការស្រាវជ្រាវអាចធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍ ឬនៅកន្លែងផ្ទាល់ក្នុងធម្មជាតិ។ តាមរយៈលទ្ធផលដែលបានមកពីការសិក្សា ពួកគេអាចប្រើប្រាស់វាសម្រាប់ជាវិធីក្នុងការជួយបង្កើនទិន្នផលកសិកម្ម និងរក្សាលំនឹងបរិដ្ឋានផងដែរ។ ក្រៅពីនេះ ពួកគេក៏មានកម្មវិធី ឬគម្រោងក្នុងការរៀបចំពិសោធន៍ចំពោះចំណីអាហារ ឱសថ ឬថ្នាំសង្កូវ ព្រមទាំងផលិតផលជាច្រើនមុខផ្សេងទៀត។

អ្នកវិទ្យាសាស្ត្រផ្នែកនេះខ្លះអាចបម្រើការនៅក្នុងសួនសត្វ ដែលទទួលបន្ទុកការរៀបចំដាក់តាំងបង្ហាញសត្វ រុក្ខជាតិ និងឧទ្យានទាំងមូលទៅដល់សាធារណជន។ អ្នកខ្លះកាន់តួនាទីជាគ្រូបង្រៀននៅសាលាបច្ចេកទេសកសិកម្ម ឬសកលវិទ្យាល័យ ឬក៏ធ្វើជាអ្នកប្រឹក្សាយោបល់ក្នុងមុខជំនួញ

*អត្ថបទដកស្រង់ និងប្រែសម្រួលចេញពីឯកសារ Career Discovery Encyclopedia. Infobase Publishing. Seven Edition, 2009. ដោយ **ហៃ ហ៊ុនឡេង**។*
*ប្រសិនលោកអ្នកចង់ជ្រាបនូវព័ត៌មានបន្ថែមស្ដីពីឯកសារនេះសូមអញ្ជើញរកអាននៅ **«បណ្ណាល័យការងារ»** របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*


តទៅទំព័របន្ទាប់

កសិកម្មនៅក្នុងវិស័យឯកជន ឬផ្នែករដ្ឋាភិបាល។ បន្ថែមលើនេះអ្នកវិទ្យាសាស្ត្រកសិកម្មខ្លះធ្វើការផ្នែកបម្រើសេវា ឬផ្នែកលក់នៅក្នុងក្រុមហ៊ុនដែលផលិតផលកសិកម្ម។

គេកត់សម្គាល់ឃើញថា ប្រធាន ឬនាយកផ្នែកការស្រាវជ្រាវអំពីគម្រោងកសិកម្មក្នុងស្ថាប័នណាមួយ តែងមានកម្រិតសញ្ញាបត្រខ្ពស់ដូចជាថ្នាក់បណ្ឌិតផ្នែកកសិកម្មជាដើម។ អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មភាគច្រើន ទោះបីជាបម្រើការនៅកន្លែងណា ឬទីណាក៏ដោយ ពួកគេតែងផ្តោតជាសំខាន់ទៅលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ជាមួយក្រុមអ្នកវិទ្យាសាស្ត្រ ឬវិស្វករផ្នែកកសិកម្ម។

អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មក៏ត្រូវបានបែងចែកជាឯកទេសផ្សេងៗគ្នាផងដែរ ឧទាហរណ៍ អ្នកបច្ចេកទេសផ្នែកដោះស្រាយបញ្ហា និងបង្កើនទិន្នផលស្រូវ ឬដំណាំធញ្ញជាតិ (agronomist) ធ្វើការស្រាវជ្រាវទៅលើជម្ងឺរបស់ដំណាំ ថ្នាំសម្លាប់សត្វល្អិត គ្រាប់ធញ្ញជាតិ និងគុណភាព ឬប្រភេទរបស់ដីដែលតម្រូវទៅតាមដំណាំនីមួយៗ។ គោលបំណងនៃការសិក្សា គឺដើម្បីស្វែងរកវិធីក្នុងការបង្កើនកម្រិតលូតលាស់របស់រុក្ខជាតិ ទិន្នផល និងរសជាតិរបស់ដំណាំគ្រប់ប្រភេទ។

ដោយឡែក អ្នកវិទ្យាសាស្ត្រផ្នែកបង្កាត់ពូជសត្វ ឬរុក្ខជាតិ (horticulturists) ធ្វើការស្រាវជ្រាវអំពីពូជ រូបលក្ខណៈ និងធាតុផ្សំរបស់រុក្ខជាតិ ដើម្បីប្រែក្លាយឱ្យជាពូជល្អដែលមានគុណភាពខ្ពស់។ ពួកគេជួយជម្រុញ និងបង្កើនល្បឿន ទំហំ និងការធន់ទ្រាំទៅនឹងជម្ងឺក្នុងការលូតលាស់របស់ដំណាំមានដូចជា ពពួកផ្កា បន្លែ ផ្លែឈើ និងរុក្ខជាតិមើម ជាដើម។

រីឯ អ្នកដែលមានឯកទេសខាងថែរក្សាបសុសត្វវិញធ្វើការថែទាំសត្វនៅក្នុងជម្រក បង្កាត់ពូជ និងផ្តល់ចំណី។ ពួកគេព្យាយាមការពារជម្ងឺកុំឱ្យឆ្លងទៅកាន់សត្វ ដែលចិញ្ចឹមនៅក្នុងកសិដ្ឋាន។ ការសិក្សាខ្លះធ្វើការតាមដានពីដំណើរនៃការវិវឌ្ឍ និងរបបចំណីរបស់សត្វដែលចិញ្ចឹមយកទឹកដោះ។

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកដែលចង់ក្លាយជាអ្នកវិទ្យាសាស្ត្រកសិកម្ម គួរចាប់ផ្តើមសិក្សានូវមុខវិជ្ជាសំខាន់ៗមួយចំនួនតាំងពីនៅវិទ្យាល័យ ដូចជា ភាសាបរទេស គណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ជាដើម។ ម្យ៉ាងទៀត គួររៀនជំនាញកុំព្យូទ័រ និងកម្មវិធីខ្លះៗទៀត។

បន្ទាប់ពីវិទ្យាល័យ គេគួរចូលរៀនយកបរិញ្ញាបត្រផ្នែកកសិកម្ម ដើម្បីទទួលបានជំនាញជាក់លាក់ណាមួយក្នុង វិស័យនេះ។ ប្រសិន ពួកគេមានបំណងក្លាយជាអ្នកស្រាវជ្រាវ ឬបង្រៀន គួរគិតបន្តការសិក្សាដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតទើបជាការប្រសើរ។ តាមរយៈការសិក្សាបន្តអាចអនុញ្ញាតឱ្យគេមានលទ្ធភាព និងចំណេះខ្លង់ខ្លស់ក្នុងការអនុវត្ត និងបង្កើតនូវការច្នៃប្រឌិតថ្មីៗពាក់ព័ន្ធកិច្ចកសិកម្ម។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជីវវិទ្យា និងគីមីវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបច្ចេកទេសកសិពាណិជ្ជកម្ម

វិស្វករកសិកម្ម

អ្នកបច្ចេកទេសខាងការបង្កាត់ពូជ និង

អ្នកបច្ចេកទេសខាងគុណភាពដី ជាដើម។

តទៅទំព័របន្ទាប់

# អ្នកឯកទេសគីមី

( Chemists )

**សង្ខេបអំពីជំនាញ**

**អ្នកឯកទេសគីមីធ្វើការងារ៖**

- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ បង្រៀន
- ✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

**ជំនាញដែលត្រូវការប្រើ៖**

- ✦ គណិតវិទ្យា
- ✦ ការដោះស្រាយបញ្ហា
- ✦ ការពិចារណា ឬធ្វើកិច្ចការប្រកបដោយហេតុផល

## តើអ្នកឯកទេសគីមីបំពេញកិច្ចការអ្វីខ្លះ?

គីមីវិទ្យា គឺសិក្សាអំពីរូបលក្ខណៈ និងសមាសធាតុគីមីរបស់វត្ថុ ឬអង្គធាតុ។ អ្នកឯកទេសគីមីរិះរកវិធីបង្កើនផលិតផល និងបង្កើតផលិតផលថ្មី ដូចជា ថ្នាំសង្កូវ វត្ថុធាតុផ្លាស្ទិក និងក្រណាត់។ ពួកគេក៏ធ្វើការផ្នែកថាមពល និងឥន្ទនៈ និងអភិវឌ្ឍនូវវត្ថុប្រើប្រាស់ជាលោហធាតុដែលទាញយកចេញពីសារធាតុរ៉ែជាច្រើនប្រភេទ ដូចជា អាលុយមីញ៉ូម ម៉ាញ៉េស្យូម និងទីតានីញ៉ូម ។ល។

អ្នកឯកទេសគីមីខាងម្ហូបអាហារ (food chemists) វិញ ខិតខំគិតបង្កើតនូវចំណីអាហារថ្មីៗ និងរិះរកវិធីរក្សាទុកឱ្យបានយូរ។ ពួកគេសិក្សាទៅលើវិធីសាស្ត្រក្នុងការចម្អិន វេចខ្ចប់ ដាក់កំប៉ុង និងបង្ករក ដើម្បីកុំឱ្យប៉ះពាល់រសជាតិ រូបរាង និងគុណភាពរបស់ចំណីអាហារ។ បន្ថែមលើនេះ អ្នកគីមីម្ហូប-អាហារក៏ធ្វើការសាកល្បង និងពិសោធន៍នូវរាល់ផលិតផលដើម្បីវាស់នូវកម្រិតស្តង់ដារ ដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

អ្នកគីមីផ្នែកវិភាគ (analytical chemists) សិក្សាវិភាគអំពីសមាសធាតុរបស់វត្ថុ ឬធាតុផ្សំដែលប្រើសម្រាប់ផលិតសម្ភារផ្សេងៗ។ ពួកគេកំណត់ស្តង់ដារសុវត្ថិរបស់សារធាតុគីមីដែលប្រើនៅក្នុងម្ហូបអាហារ ភេសជ្ជៈ ព្រមទាំងពិនិត្យរកសារ-ជាតិពុល ដែលបញ្ចេញចោលដោយរោងចក្រទៅក្នុងបរិដ្ឋាន ឬទៅក្នុងទឹកទន្លេ និងសមុទ្រ។

អ្នកគីមីផ្នែកជីវរូប (biological chemists) សិក្សាអំពីសមាសធាតុ និងធាតុសកម្មរបស់គីមីដែលមាននៅក្នុងសរីរាង្គរបស់ភាវរូបមានជីវិតទាំងអស់។ ពួកគេវិភាគ និងកំណត់អំពីដំណើរការរបស់សាធាតុគីមី ដែលជាប់ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជីវរូប ដូចជា ការឡើងទម្ងន់ ការបង្កកំណើត និងការសិក្សាអំពីហ្ស៊ែន (gene) ផងដែរ។

ចំណែកអ្នកគីមីសរីរាង្គ (organic chemists) សិក្សាអំពីធាតុផ្សំរបស់គីមីដែលមាននៅក្នុងសាធាតុកាបូន (carbon) និងអ៊ីដ្រូសែន។ អ្នកគីមីផ្នែករូប និងទ្រឹស្តី (physical and theo-retical chemists)សិក្សាអំពីរូបលក្ខណៈរបស់អាតូម (atoms) និងម៉ូលេគុល (molecules) ដើម្បីចង់ដឹងពីប្រតិកម្មរបស់សារធាតុគីមីនានា។



អ្នកគីមីផ្នែករូបអាចធ្វើការនៅក្នុងរោងចក្រនុយក្លេអ៊ែរ ដើម្បីសិក្សាទាញយកនូវផលប្រយោជន៍ជាថាមពលអគ្គិសនី ដោយប្រើប្រាស់សារធាតុប្រតិកម្មរបស់នុយក្លេអ៊ែរ។

អ្នកគីមីផ្នែកឱសថ (medicinal chemists) សិក្សាអំពីរចនាសម្ព័ន្ធរបស់សមាសធាតុផ្សំ ដែលនឹងត្រូវប្រើប្រាស់នៅក្នុងឱសថសម្រាប់ព្យាបាលជម្ងឺរបស់មនុស្ស។




## ការអប់រំ និងការបណ្តុះបណ្តាល

ការសិក្សា និងបណ្តុះបណ្តាលជំនាញផ្នែកគីមី គឺត្រូវចាប់ផ្តើមឡើងពីពេលនៅសិក្សាក្នុងវិទ្យាល័យមកម៉្លេះ។ អ្នកគួរសិក្សាមុខវិជ្ជាគណិតវិទ្យា ធរណីមាត្រ និងការគណនាឱ្យបានច្រើន។ ក្រៅពីនេះ ក៏ត្រូវសិក្សាផងដែរលើមុខវិជ្ជាវិទ្យាសាស្រ្ត ជីវវិទ្យា គីមីវិទ្យា និងរូបវិទ្យា។ គេក៏មិនគួរភ្លេចសិក្សាភាសាបរទេស និងជំនាញកុំព្យូទ័រនោះទេ។

បន្ទាប់មក គេត្រូវសិក្សាយកជំនាញនេះនៅកម្រិតបរិញ្ញាបត្រ ដែលជាកម្រិតគ្រប់គ្រាន់ល្មមសម្រាប់ចូលទៅបំពេញការងារសាមញ្ញៗ។ ប៉ុន្តែការងារបែបលំបាក និងស្មុគស្មាញតម្រូវឱ្យគេសិក្សា និងទទួលសញ្ញាបត្រកម្រិតខ្ពស់ជាងនេះជាបន្ថែមទៀត។

ប្រសិន អ្នកមានបំណងក្លាយជាអ្នកស្រាវជ្រាវនៅក្នុងវិស័យនេះ គួរតែសិក្សារហូតដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជាការចាំបាច់។ គេក៏កត់សម្គាល់ផងដែរថា បុគ្គលិក ឬសាស្រ្តាចារ្យដែលមានជំនាញផ្នែកនេះក៏តម្រូវឱ្យមានកម្រិតសញ្ញាបត្រខ្ពស់ផងដែរ។

### គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជីវវិទ្យា គីមីវិទ្យា គណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកជីវវិទ្យា

វិស្វករគីមី

ឱសថការី ។ល។

### តើអ្នកដឹងឬទេ?

ប្រសិនអ្នកមានបំណងសិក្សាលើមុខជំនាញផ្នែកគីមី អ្នកអាចស្វែងរកសិក្សាមុខជំនាញនេះនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (Institute of Technology of Cambodia) ដែលជាគ្រឹះស្ថានអប់រំរបស់រដ្ឋ។ បច្ចុប្បន្នវិទ្យាស្ថាននេះមានទទួលសិស្ស និស្សិតឱ្យសិក្សាជំនាញបច្ចេកទេស និងវិស្វករជាច្រើនផ្នែក ដែលក្នុងនោះរួមមានទាំងជំនាញជាវិស្វករផ្នែកគីមី និងម្ហូបអាហារផងដែរ។

# គិលានុបដ្ឋាក

( Nurses )

សង្ខេបអំពីជំនាញ

គិលានុបដ្ឋាកធ្វើការងារ៖

- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- ✦ បង្រៀន

ជំនាញដែលត្រូវការប្រើ៖

- ✦ ការធ្វើសេចក្តីសម្រេចចិត្ត
- ✦ ការទទួលខុសត្រូវ
- ✦ ការនិយាយ និងការស្តាប់

## តើគិលានុបដ្ឋាកបំពេញកិច្ចការអ្វីខ្លះ?

គិលានុបដ្ឋាកមានភារៈកិច្ចទទួលថែទាំអ្នកជម្ងឺ អ្នករងរបួស ឬអ្នកដែលមានសុខភាពមិនប្រក្រតី។ ពោលជារួម គិលានុបដ្ឋាកមានតួនាទី និងកិច្ចការច្រើនត្រូវអនុវត្ត ដូចជាការជួយកិច្ចការធ្ងន់ស្រាល និងធ្វើឱ្យអ្នកជម្ងឺមានភាពល្ហែល្ហើយ និងសះស្បើយពីរោគា ការផ្តល់ឱសថព្យាបាល និងតាមដានសភាពវិវឌ្ឍនៃជម្ងឺ ព្រមទាំងរៀបចំសម្ភារបរិក្ខាដែលត្រូវប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ។

គិលានុបដ្ឋាកមួយរូបៗមិនមានការសិក្សា និងហ្វឹក-ហាត់ការងារដូចគ្នានោះទេ ហេតុនេះកិច្ចការដែលពួកគេធ្វើក៏មានភាពប្លែកគ្នាទៅតាមនោះដែរ។ គិលានុបដ្ឋាកខ្លះមានភារៈជួយកិច្ចការដល់វេជ្ជបណ្ឌិតផ្នែកវះកាត់ តាមដានដំណើរការនៃការផ្តល់ឱសថដល់អ្នកជម្ងឺ ព្រមទាំងជួយមើលកិច្ចការផ្នែកផ្តល់ឱវាទ និងបង្រៀនដល់គិលានុបដ្ឋាកផ្សេងទៀតដែលស្ថិតនៅក្រោមបង្គាប់។

អាស្រ័យដោយគិលានុបដ្ឋាកមានជំនាញ និងភារៈខុសៗគ្នាដូច្នេះហើយ ទើបគេសង្កេតឃើញមានគិលានុបដ្ឋាកផ្នែកផ្សេងៗដូចជា៖

● **គិលានុបដ្ឋាកទទួលបន្ទុកទូទៅ** ធ្វើការជាផ្នែកមួយនៃក្រុមថែទាំជម្ងឺ។ ក្រុមការងារនេះធ្វើការកំណត់ពីសភាពជម្ងឺរបស់អ្នកជម្ងឺ និងរៀបផែនការព្យាបាល ឬការថែទាំសុខភាព។ ពួកគេពិនិត្យកម្រិតសម្ពាធឈាម សីតុណ្ហភាព និងដំណើរជីពចររបស់អ្នកជម្ងឺ ព្រមទាំងផ្តល់ថ្នាំសង្កូវទៅដល់អ្នកជម្ងឺ។ ពួកគេពិនិត្យរោគសញ្ញារបស់អ្នកជម្ងឺ ផ្លាស់ប្តូរសម្លៀកបំពាក់ឱ្យអ្នកជម្ងឺ រៀបចំអ្នកជម្ងឺសម្រាប់ការវះកាត់ និងជាពិសេសបំពេញភារកិច្ចផ្សេងៗទៅតាមជំនាញ និងតម្រូវការរបស់អ្នកជម្ងឺគ្រប់ៗរូប។

● **គិលានុបដ្ឋាកផ្នែកវះកាត់** ជួយកិច្ចការដល់វេជ្ជបណ្ឌិតផ្នែកវះកាត់នៅក្នុងពេលធ្វើការវះកាត់។ ● **គិលានុបដ្ឋាកផ្នែក-សម្ភព** ជួយកិច្ចការនៅក្នុងបន្ទប់សម្រាលកូន និងជួយមើលថែទាំទារកដែលទើបនឹងកើត។ ពួកគេបង្រៀនដល់ស្ត្រីជាម្តាយឱ្យយល់ដឹងពីការថែទាំ និងចញ្ចឹមកូនង៉ែតឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។ ● **គិលានុបដ្ឋាកផ្នែកបង្រៀន** ជួយផ្តល់ឱវាទដល់សិស្ស ព្យាបាលជម្ងឺ ឬរបួសស្រាលៗបន្តិចបន្តួច និងផ្តល់យោបល់ទូទៅពាក់ព័ន្ធនឹងបញ្ហាសុខភាព។



- **គិលានុបដ្ឋាកផ្នែកសង្គ្រោះជម្ងឺធ្ងន់ធ្ងរ** ជួយមើលថែអ្នកជម្ងឺដែលមានអាការធ្ងន់ធ្ងរនៅក្នុងមន្ទីរពេទ្យ ឬធ្វើដំណើរទៅពិនិត្យ និងព្យាបាលជម្ងឺជារឿយៗ នៅតាមគេហដ្ឋានរបស់អ្នកជម្ងឺដែលមានអាការធ្ងន់ធ្ងរមិនអាចសម្រាកនៅមន្ទីរពេទ្យបាន។

ក្រៅពីនេះ គេក៏សង្កេតឃើញមានគិលានុបដ្ឋាកខ្លះទៀត ដែលទទួលបានការអប់រំវគ្គខ្លីសម្រាប់ជំនាញក្នុងការថែទាំទូទៅដល់អ្នកជម្ងឺ ផ្តល់ឱសថដល់អ្នកជម្ងឺ និងធ្វើកិច្ចការបែបរដ្ឋបាល ឬស្មៀននៅក្នុងមន្ទីរពេទ្យផងដែរ។

## ការអប់រំ និងការបណ្តុះបណ្តាល

អំឡុងពេលសិក្សានៅមធ្យមសិក្សាទុតិយភូមិ អ្នកគួរផ្តោតជាសំខាន់លើមុខវិជ្ជាជីវវិទ្យា សុខភាព គណិតវិទ្យា និងវិទ្យាសាស្ត្រសង្គម ដែលមុខវិជ្ជាទាំងអស់នេះនឹងផ្តល់នូវមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ឈានទៅការសិក្សានៅជំនាញផ្នែកគិលានុបដ្ឋាក។

បន្ទាប់ពីសិក្សានៅវិទ្យាល័យ អ្នកអាចបន្តការសិក្សាជំនាញឯកទេសគិលានុបដ្ឋាក ទៅតាមកម្រិតសញ្ញាបត្រដូចមានបង្ហាញក្នុងរូបខាងក្រោម៖




### គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា៖

ជីវវិទ្យា និងគីមីវិទ្យា

✦ កម្រិតអប់រំទាបបំផុត៖

បរិញ្ញាបត្រ និងការបណ្តុះបណ្តាលវិជ្ជាជីវៈគិលានុបដ្ឋាក

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖

ជំនួយការគិលានុបដ្ឋាក និង

គិលានុបដ្ឋាកផ្នែកជម្ងឺធ្ងន់ ។ល។

### តើអ្នកដឹងឬទេ?

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (Université des Sciences de la Santé) ជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ ដែលមានទស្សនវិស័យក្នុងការអប់រំបណ្តុះបណ្តាលយុវជន យុវនារីខ្មែរឱ្យទទួលបាននូវចំណេះដឹងទូទៅ និងឯកទេសផ្នែកការថែទាំសុខភាព។ម្យ៉ាងទៀត សាកលវិទ្យាល័យក៏ឈរនៅលើទស្សនៈនៃការផ្សព្វផ្សាយអំពីបញ្ហាសុខភាព ព្រមទាំងគុណភាព និងសុវត្ថិភាពនៃសេវាសុខភាពនៅទូទាំងប្រទេស។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យចំនួន ៣ និងសាលាបច្ចេកទេសមួយគឺ៖ មហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យឱសថសាស្ត្រ មហាវិទ្យាល័យទន្តសាស្ត្រ និងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ។

ក្រៅពីនេះ គេក៏សង្កេតឃើញមានសាកលវិទ្យាល័យឯកជនមួយចំនួនទៀត កំពុងផ្តល់ការអប់រំលើមុខជំនាញផ្នែកវេជ្ជសាស្ត្រផងដែរ។ ហេតុនេះ សិស្ស និស្សិតអាចធ្វើការជ្រើសរើសសិក្សាជំនាញណាមួយតាមការគួរ។

# បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយ

( Campaign Workers )

**សង្ខេបអំពីជំនាញ**

**បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយធ្វើការងារ៖**

- បែងចែកមូលនិធិ និងធនធាន
- គ្រប់គ្រងក្រុមមនុស្ស ឬមហាជន
- បំពេញកិច្ចការជាក្រុម

**ជំនាញដែលត្រូវការប្រើ៖**

- ការអាន និងសរសេរ
- គណិតវិទ្យា
- ការនិយាយ និងស្តាប់

## តើបុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយបំពេញកិច្ចការអ្វីខ្លះ?

បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយធ្វើការងារបែបជួយជ្រោមសកម្មភាពឃោសនាក្នុងដំណើរការ-បោះឆ្នោត និងជួយបេក្ខជនឈរឈ្មោះឱ្យទទួលបានការគាំទ្រព្រមទាំងជាប់ឆ្នោត។ ពួកគេធ្វើការពន្យល់អប់រំទៅដល់មហា-ជនអំពីសមាសភាព និងចំណុចខ្លាំងរបស់បេក្ខជនដែលឈរឈ្មោះ ចែកចាយព័ត៌មានតាមរយៈបណ្ណផ្សព្វផ្សាយ ឃោស-នាតាមរយៈទូរទស្សន៍ វិទ្យុ និងបណ្តាញឃោសនាដទៃទៀត។

ហេតុនេះ បេក្ខជនឈរឈ្មោះនៅក្នុងរដ្ឋាភិបាល និងគណបក្សនយោបាយផ្សេងៗត្រូវការប្រើប្រាស់នូវសេវារបស់អ្នកជួយឃោសនាដើម្បីរៀបចំកិច្ចការលម្អិតនានាក្នុងដំណើរការបោះឆ្នោតដូចជា ថវិកា និងការចំណាយ ការកៀរគររកជំនួយពីអ្នកឧបត្ថម្ភ ឬសប្បុរសជនដែលគាំទ្រ ព្រមទាំងរៀប-ចំការផ្សព្វផ្សាយតាមរយៈសន្និសីទសារព័ត៌មាន ជាដើម។

គេកត់សម្គាល់ថា យុទ្ធនាការឃោសនាបោះឆ្នោតដែលរៀបចំបានល្អ គឺមានសារសំខាន់ជាងចំណុចខ្លាំងរបស់បេក្ខ-ជនផ្ទាល់ទៀតផង។ កិច្ចការនេះអាស្រ័យជាពិសេសទៅលើការស្ម័គ្រចិត្ត និងការពុះពាររបស់អ្នកឃោសនា ព្រមទាំងការរៀបចំបានល្អពីសំណាក់អ្នកគ្រប់គ្រង។ ជាទូទៅ ឧបករណ៍សម្រាប់ការឃោសនាមានច្រើនប្រភេទ និងទម្រង់ខុសៗគ្នាដូចជា ការបោះពុម្ពស្លាកសញ្ញាលើអាវយឺត បណ្ណផ្ទត់ដែលពណ៌នាអំពីចំណុចល្អរបស់បេក្ខជន ផ្ទាំងរូបភាពអំពីខ្លឹមសារឬបាវចនារបស់គណបក្សបិតនៅតាមជញ្ជាំង ដើមឈើ និងទីវាលសាធារណ ទាំងអស់នេះសុទ្ធសឹងមានសារសំខាន់ក្នុងការចូលរួមចំណែកទាក់ទាញមហាជនឱ្យពិចារណា និងបោះឆ្នោតជូនបេក្ខជនតំណាង។

អ្នកឃោសនាក៏មានភារៈក្នុងការអភិវឌ្ឍបច្ចេកទេសជាយុទ្ធសាស្ត្រក្នុងការឃោសនាដូចជា គួរលើកយកបញ្ហា ឬគោលនយោបាយបែបណាមកបង្ហាញ ហើយគួរបង្ហាញពីប្រវត្តិនយោបាយរបស់បេក្ខជនតំណាងយ៉ាងដូចម្តេច។ ក្រៅពីនេះ អ្នកឃោសនាត្រូវរៀបចំសុន្ទរកថា អត្ថបទសម្រាប់អ្នកសារព័ត៌មាន រៀបចំការជួបផ្ទាល់រវាងបេក្ខជនតំណាង និងអ្នកបោះឆ្នោតដើម្បីបង្ហាញខ្លួន និងជជែកជាសាធារណៈ។



## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកដែលមានបំណងចង់ក្លាយខ្លួនជាអ្នកឃោស-នាគួរផ្តោតការសិក្សាទៅលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា ប្រវត្តិសាស្ត្រ រដ្ឋបាល ឬរដ្ឋាភិបាល គណិតវិទ្យា កុំព្យូទ័រ និងផ្នែកធុរកិច្ច។ ក្រៅពីនេះ អ្នកគួររៀនភាសាបរទេស ការធ្វើបទបង្ហាញ ឬការធ្វើសុន្ទរកថា ដើម្បីជួយបង្កើនចំណេះ និងជំនាញក្នុងការនិយាយ ឬសរសេរទំនាក់-ទំនងក្នុងកិច្ចការ។

សម្រាប់ការអនុវត្តជាក់ស្តែង អ្នកគួរសាកល្បងចូលរួមក្នុងយុទ្ធនាការឃោសនាណាមួយ ដើម្បីជាការដកស្រង់បទ-ពិសោធន៍ និងត្រៀមខ្លួនរៀបចំដោយខ្លួនឯងនៅក្នុងពេលអនាគត។ យ៉ាងណាមិញ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតលំដាប់ជាតិ ដូចជាការបោះឆ្នោតសាកលជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ជាដើម តម្រូវឱ្យអ្នកឃោសនាមានភាពស្ទាត់ជំនាញមានបទពិសោធន៍ច្រើន និងស្វែងយល់ពីគោលនយោបាយរបស់គណបក្ស និងសមាសភាពរបស់បេក្ខជនតំណាង ដើម្បីអាចធ្វើការពន្យល់ ឬបង្ហាញនូវចំណុចខ្លាំងទាំងឡាយទៅដល់មហាជន និងអ្នកបោះឆ្នោត។




### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ធុរកិច្ច (ពាណិជ្ជកម្ម) និងរដ្ឋបាល ឬរដ្ឋាភិបាល

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកវិទ្យាសាស្ត្រនយោបាយ និង

អ្នកបញ្ចុះបញ្ចូល ជាដើម។

### តើអ្នកដឹងឬទេ?

នៅប្រទេសកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត (គ.ជ.ប) មានភារៈទទួលខុសត្រូវលើការបោះឆ្នោតសំខាន់ៗដូចជា ការបោះឆ្នោតព្រឹទ្ធសភា ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម។

តាមក្របខ័ណ្ឌគតិយុត្ត វិធាននៃការឃោសនាសម្រាប់ការបោះឆ្នោតត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត។ ឧទាហរណ៍ នៅក្នុងមាត្រានៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅត្រង់ជំពូកទី ៧ បានចែងអំពីការឃោសនាបោះឆ្នោតដូច្នេះថា៖ យុទ្ធនា-ការឃោសនាបោះឆ្នោតមានរយៈពេល ៣០ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត។ ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោតគណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងគោលការណ៍ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនិតិវិធីរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិ-មនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ *(មាត្រា៧២ និង៧៣ថ្មីនៃច្បាប់បោះឆ្នោត)*

តទៅទំព័របន្ទាប់

# អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ

( Database Specialists )

**សង្ខេបអំពីជំនាញ**

**អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើការងារ៖**

- បង្កើត ឬអភិវឌ្ឍប្រព័ន្ធ
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

**ជំនាញដែលត្រូវការប្រើ៖**

- ការធ្វើសេចក្តីសម្រេចចិត្ត
- គណិតវិទ្យា
- ការដោះស្រាយបញ្ហា

## តើអ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើកិច្ចការអ្វីខ្លះ?

ការប្រមូលនូវព័ត៌មាន ឬទិន្នន័យដើម្បីបញ្ចូល និងរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រហៅថា «មូលដ្ឋានទិន្នន័យ» (database)។ អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើកិច្ចការនៅក្នុងក្រុមហ៊ុនផ្នែកលក់សម្ភារ ក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនទូរគមនាគមន៍ និងក្រសួងស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល។ ពួកគេរៀបចំបង្កើត និងថែទាំមូលដ្ឋានទិន្នន័យ ទិញសម្ភារកុំព្យូទ័រ បង្កើតកម្មវិធីកុំព្យូទ័រដើម្បីប្រមូល វិភាគ រក្សា និងផ្សព្វផ្សាយព័ត៌មាន។

អ្នកបច្ចេកទេសមូលដ្ឋានទិន្នន័យស្រាវជ្រាវនិងស្វែងរកប្រភេទប្រព័ន្ធកុំព្យូទ័រដែលក្រុមហ៊ុន ឬស្ថាប័នត្រូវការប្រើ។ ពួកគេត្រូវការជជែកពិភាក្សាជាមួយថ្នាក់ដឹកនាំកំពូលរបស់ក្រុមហ៊ុន ឬស្ថាប័នអំពីសេចក្តីត្រូវការទាំងឡាយ។ បន្ទាប់មកភាគីទាំងពីរធ្វើសេចក្តីសម្រេចចិត្តទៅលើប្រភេទនៃឧបករណ៍ និងកម្មវិធីដែលនឹងប្រើប្រាស់សម្រាប់បង្កើតមូលដ្ឋានទិន្នន័យរបស់ស្ថាប័ន។ អ្នកបច្ចេកទេសមូលដ្ឋានទិន្នន័យក៏ត្រូវធ្វើការប៉ាន់ស្មានតម្លៃ និងការចំណាយសម្រាប់សម្ភារដើម្បីលើកជាសំណើរក្នុងការទិញវត្ថុទាំងនោះ។

អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យនឹងធ្វើការបង្កើតប្រព័ន្ធទិន្នន័យទៅតាមសម្ភារដែលបានទិញ។ ចំណែកអ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ (database managers) វិញ នឹងសម្រេចអំពីវិធីក្នុងការរៀបចំ និងរក្សាទុកទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ។ ការងារបន្ទាប់មកទៀតគឺ បង្ហាត់បង្ហាញបុគ្គលិកក្នុងក្រុមហ៊ុន ឬស្ថាប័នឱ្យចេះប្រើប្រាស់ និងទាញយកព័ត៌មាន ឬទិន្នន័យពីប្រព័ន្ធដែលបានបង្កើតរួច។



ជួនកាលកម្មវិធីកុំព្យូទ័រគាំងមិនដំណើរការ ឬខូចគាំង ដូច្នេះ អ្នកបច្ចេកទេសត្រូវប្រុងប្រយ័ត្ន និងថតចម្លងឯកសារដើម្បីរក្សាទុកជៀសវាងការបាត់បង់។ បន្ថែមលើនេះ អ្នកបច្ចេកទេសត្រូវរិះរកវិធីក្នុងរក្សា ឬការពារទិន្នន័យក្នុងករណីមានគោលការណ៍ហាមឃាត់មិនឱ្យអ្នកដទៃមើលឃើញ ឬទាញយកព័ត៌មានទាំងនោះ ពីព្រោះទិន្នន័យរបស់ស្ថាប័ន ឬក្រុមហ៊ុននីមួយៗតែងមានចំណុចសម្ងាត់ និងសម្រាប់ការប្រើ

ប្រាស់ផ្ទៃក្នុង។ ស្ថាប័នធំៗខ្លះអាចមានទិន្នន័យមួយ ឬច្រើន ដែលមានតួនាទីខុសៗគ្នា ដូច្នេះ អ្នកបច្ចេកទេសត្រូវគិតអំពីវិធីក្នុងការចែករំលែកព័ត៌មានរវាងមូលដ្ឋានទិន្នន័យទាំងអស់នោះ ដើម្បីកំណត់ថាព័ត៌មានណាអាចចែករំលែកបាន និងព័ត៌មានបែបណាមិនអាចចែករំលែកបាន។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិន អ្នកមានបំណងក្លាយជាអ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ អ្នកគួរខិតខំរៀននូវមុខវិជ្ជាពាក់ព័ន្ធកុំព្យូទ័រឱ្យបានច្រើន។ បន្ថែមលើនេះ អ្នកគួរសិក្សាគណិតវិទ្យា គណនេយ្យ វិទ្យាសាស្ត្រ ភាសាបរទេស និងមុខវិជ្ជាផ្នែកទំនាក់ទំនង។

អ្នកត្រូវមានសញ្ញាបត្រទាបបំផុតត្រឹមកម្រិតបរិញ្ញាបត្ររង ឬបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងមុខវិជ្ជានានាពាក់ព័ន្ធបច្ចេកទេសកុំព្យូទ័រ និងការបញ្ចូលទិន្នន័យ ជាដើម។ ក្រៅពីនេះ អ្នកក៏ត្រូវមានជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ដើម្បីអាចកាន់តំណែង ឬមុខនាទីធំដុំនៅក្នុងការងារ។ អ្នកខ្លះអាចបន្តការសិក្សារហូតដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីអាចមានលទ្ធភាពកាន់តែច្រើន ចំពោះការប្រកួតប្រជែងនៅក្នុងទីផ្សារការងារ។



### គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា៖

វិទ្យាសាស្ត្រកុំព្យូទ័រ

គណិតវិទ្យា

គីមីវិទ្យា

✦ កម្រិតអប់រំទាបបំផុត៖

បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖

អ្នកបង្កើតកម្មវិធីកុំព្យូទ័រ

អ្នកបង្រៀនកុំព្យូទ័រ

អ្នកឯកទេសខាងគំនូរក្រាហ្វិក និង

វិស្វករផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ ជាដើម។

### តើអ្នកដឹងឬទេ?

សព្វថ្ងៃនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ កំពុងរៀបចំរចនាប្រព័ន្ធមូលដ្ឋានទិន្នន័យអំពីព័ត៌មានទីផ្សារការងារ។ ក្នុងពេលអនាគត ពេលដែលមូលដ្ឋានទិន្នន័យនេះកសាងចប់រួចរាល់ អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំគោលនយោបាយ និងសាធារណជនទូទៅអាចប្រើប្រាស់មូលដ្ឋានទិន្នន័យនេះដោយទូលំទូលាយ។

សូមរង់ចាំអាននៅក្នុងការផ្សាយលេខក្រោយ

ស្តីពីប្រភេទនៃជំនាញ និងការងារផ្សេងៗទៀត

ដោយមេត្រី!

ការរៀបចំមូលដ្ឋានគ្រឹះ




ក្នុងការស្វែងរកការងារធ្វើ

# ការបង្កើតបណ្តាញសង្គម និង ការស្វែងរកការងារ



នៅក្នុងការផ្សាយលេខ ០០៧ ព្រឹត្តិបត្រការងារ បាននាំអារម្មណ៍លោកអ្នក អ្នកស្វែងរកការងារធ្វើ និងមិត្តអ្នកអានទាំងអស់ទៅស្វែងយល់អំពីការទទួលបាននូវបទពិសោធន៍ការងារតាមរយៈ «កម្មសិក្សាការងារ» ។ ក្នុងការផ្សាយលេខនេះ យើងខ្ញុំសូមទាញការយកចិត្តទុកដាក់ពីសំណាក់មិត្តអ្នកអានគ្រប់ប្រភេទឱ្យមកពិនិត្យមើលអំពីលទ្ធភាពមួយបែបផ្សេងទៀតក្នុងទទួលបានការងារ ពោលគឺ «**ការបង្កើតនូវបណ្តាញសង្គម**» (social networking)។ ទស្សនៈខ្មែរយើងច្រើនយល់ថាការស្គាល់ ឬរាប់អានគ្នា ច្រើននាំដល់ការជួយយកអាសារ និងជួយដោះស្រាយទុក្ខធុរៈគ្នាទៅវិញទៅមក ឬក៏ពោលម្យ៉ាងទៀតថា «ជួយគ្នាក្នុងគ្រាក្រ»។ ការពិតគំនិតនេះគឺជាការយល់ឃើញតាមរបៀបជាប្រពៃណី ឬវប្បធម៌នៃការរស់របស់មនុស្សក្នុងសង្គម។ ប៉ុន្តែ បច្ចុប្បន្នពាក្យថាបង្កើតបណ្តាញសង្គម ច្រើនពោលសំដៅដល់ការចងក្រងជាបណ្តាញរវាងអ្នកដែលមានចំណូលចិត្ត ឬការងារប្រហាក់ប្រហែលគ្នា ដើម្បីការពង្រីកមុខជំនួញ និងពង្រីកទំនាក់ទំនងទៅកាន់មនុស្សថ្មីៗឱ្យបានទូលំទូលាយ។ បានន័យថា មិនត្រឹមតែស្គាល់គ្នាក្នុងក្របខ័ណ្ឌប្រពៃណី ឬគុណតម្លៃរបស់វប្បធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកវិសាលភាពនៃការស្គាល់ទៅដល់កម្រិតជំនាញ ឯកទេស និងវិជ្ជាជីវៈនីមួយៗទៀតផង។

## ហេតុអ្វីបណ្តាញសង្គម មានសារសំខាន់?

យើងដឹងថាលោកអ្នកមានជំនាញ និងសមត្ថភាពពិសេសតែរៀងៗខ្លួន។ ហេតុអ្វីចាំបាច់បង្កើតបណ្តាញសង្គមដែលនាំឱ្យខាតពេលវេលា និងប្រាក់កាសក្នុងការចូលរួមសកម្មភាពរបស់ក្រុមបណ្តាញរបស់ខ្លួន?

តើការបង្កើតបណ្តាញសង្គមមានសារសំខាន់បែបណាខ្លះក្នុងការទទួលបានការងារ?

មុននឹងឆ្លើយទៅនឹងសំណួរនេះ យើងខ្ញុំសូមនាំអារម្មណ៍មិត្តអ្នកអានមកមើលឧទាហរណ៍របស់បុគ្គលម្នាក់

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង**។ សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញរកអានឯកសារស្តីពីអាជីព និងការងារដែលមានតម្កល់ទុកនៅក្នុង «**បណ្ណាល័យការងារ**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

ដែលទទួលបានការងារពីបណ្តាញសង្គម ដែលខ្លួនពុំធ្លាប់គិតពីមុនមក។

ឧទាហរណ៍៖ សោភា គឺជានារីម្នាក់ដែលទើបបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ។ នាងមិនធ្លាប់ដែលគិតពីមុនមកសោះថា រូបនាងអាចទទួលបានការងារមួយតាមរយៈការដែលនាងបានស្គាល់មនុស្សសំខាន់ៗនៅក្នុងឱកាសនៃពិធីជប់លៀងមួយនៅផ្ទះរបស់មិត្តភ័ក្តិនាង។ នាងបានពោលដោយក្តីរំភើបអំពីព្រឹត្តិការណ៍នៅក្នុងឱកាសនោះថា៖ ក្នុងពិធីជប់លៀងនោះ ខ្ញុំបានជួបជជែកតាមរបៀបអ្នកស្គាល់គ្នាដំបូងជាមួយស្ត្រីម្នាក់ឈ្មោះធីតា ដែលតាមការពិតនារីនោះត្រូវជាមិត្តភ័ក្តិរបស់បងស្រីជីដូនមួយរបស់ខ្ញុំ។ លោកស្រី ធីតា បានសាកសួរខ្ញុំពីនេះពីនោះ បន្ទាប់មកក៏ជជែកដល់រឿងរៀនសូត្រ។ គាត់បានសួរខ្ញុំថា៖ សោភាឯងបានបញ្ចប់ការសិក្សាជំនាញអ្វីដែរ? ខ្ញុំបានឆ្លើយដោយរួសរាន់ថា៖ ខ្ញុំបានសិក្សាជំនាញផ្នែកភាសាអង់គ្លេស ប៉ុន្តែបច្ចុប្បន្ននេះរកការងារមិនទាន់បានធ្វើនៅឡើយទេ។ លោកស្រី ធីតា សញ្ជឹងគិតបន្តិចបែបជ្រួញចិញ្ចើម រួចហើយក៏ពោលឡើងថា៖ មិត្តភ័ក្តិខ្ញុំម្នាក់ឈ្មោះ ពាសី ជាបុគ្គលិកទទួលកិច្ចការធំដុំម្នាក់នៅក្នុងបណ្ណាគារផ្នែកបោះពុម្ពផ្សាយ។ សោភាឯងគួរសាកល្បងជួបជជែកជាមួយគាត់ ជួនជាមានឱកាសការងារដែលគេអាចជួយបាន។ សោភាមានចិត្តត្រេកអរជាខ្លាំងពេលបានឮដូច្នោះ បន្ទាប់មកនាងបានទំនាក់ទំនង និងសុំពេលណាត់ជួបជាមួយលោកស្រី ពាសី ដើម្បីសាកសួរព័ត៌មាន និងសម្ភាសន៍។



នៅក្នុងថ្ងៃណាត់ជួប ពាសីបានសម្ភាសន៍ពីប្រវត្តិសិក្សា និងប្រវត្តិរូបខ្លះៗរបស់សោភា បន្ទាប់ក៏សម្រេចចិត្តផ្តល់ការងារមួយដល់សោភាដោយទទួលកិច្ចការជាជំនួយការផ្នែកពិនិត្យ និងរៀបរៀងការបោះពុម្ពផ្សាយ។

សោភាបានពោលរំឭកសរសើរដល់ លោកស្រីពាសី លោកស្រីធីតា និងមិត្តភ័ក្តិរបស់នាងដែលពួកគេបានបង្កនូវឱកាសដ៏ប្រពៃមួយ ក្នុងការនាំរូបនាងឱ្យទទួលបាននូវការងារដ៏គាប់ប្រសើរមួយក្នុងវិស័យបោះពុម្ពផ្សាយ។ សូមរំឭកដែរថា សោភា ប្រហែលជាពុំបានចាប់អារម្មណ៍ទេក្នុងឱកាសនៃថ្ងៃជប់លៀង ថានាងបានកំពុងប្រើប្រាស់នូវបណ្តាញសង្គមតាមរយៈការណែនាំ និងការស្គាល់គ្នាដែលបាននាំរូបនាងចូលទៅក្នុងទីផ្សារការងារ។

ជាការពិត ឱកាសបែបនេះអាចកើតឡើងដោយពុំបានព្រាងទុកជាមុន ហើយបានធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មនុស្សខ្លះដែលធ្លាប់គិតថា ការបង្កើត ឬចូលរួមក្នុងបណ្តាញសង្គមគឺនាំមកនូវភាពស្មុគស្មាញ និងចំណាយពេលវេលាឥតប្រយោជន៍។

## តើបណ្តាញសង្គមផ្តល់នូវអត្ថប្រយោជន៍អ្វីខ្លះ?

ជាទូទៅ ការបង្កើតបណ្តាញសង្គមគឺជារឿងសាមញ្ញដែលសំដៅទៅដល់ការចងក្រងនូវទំនាក់ទំនងជាមិត្តភាពដ៏មានសារសំខាន់ ហើយអាចប្រើប្រាស់នូវចំណងនេះដើម្បីទទួលបានការងារ ឬផលប្រយោជន៍ផ្សេងៗ។ គេសង្កេតឃើញថា បណ្តាញសង្គមមានពាក់ព័ន្ធជាពិសេសទៅដល់ការចូលរួមចែករំលែក និងប្រមូលនូវព័ត៌មាន ប្រភពទំនាក់ទំនងព្រមទាំងបទពិសោធន៍ទៀតផង។ ធម្មតា មនុស្សទូទៅច្រើន

បង្កើតបណ្តាញសង្គមតាមរបៀបផ្សេងៗក្នុងការរស់នៅប្រចាំថ្ងៃ ដូចជាទំនាក់ទំនងរវាងមិត្តភ័ក្តិ អ្នកធ្វើការជាមួយគ្នា ញាតិសន្តាន និងអ្នកដែលមិនធ្លាប់ស្គាល់គ្នាពីមុនតាមរយៈការជួបជជែកដោយចៃដន្យ និងតាមរយៈការសរសេរលិខិតឆ្លើយឆ្លងជាដើម។

បន្ថែមលើនេះ អាស្រ័យដោយបច្ចេកវិទ្យាផ្នែកព័ត៌មានវិទ្យាបច្ចុប្បន្នមានការរីកចម្រើន និងមានការបើកចំហយ៉ាងទូលំទូលាយ ដូច្នេះ ការបង្កើតបណ្តាញសង្គមក៏មានភាពងាយស្រួលយ៉ាងខ្លាំង តាមរយៈការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត អ៊ីម៉ែល គេហទំព័រផ្នែកបណ្តាញសង្គមជាច្រើនដូចជា Facebook, BlogSpot, Twitter, Yahoo Messenger ។ល។



## មូលដ្ឋានគ្រឹះក្នុងការបង្កើតនូវបណ្តាញសង្គម

លោកអ្នក និងមិត្តអ្នកអានបានយល់រួចហើយនូវខ្លឹមសាររួម និងសារសំខាន់របស់បណ្តាញសង្គម ប៉ុន្តែទំនងជាលោកអ្នកនៅមានចម្ងល់អំពីព័ត៌មានលម្អិត និងដំណើរការនៃការបង្កើតបណ្តាញសង្គម។ ហេតុនេះ នៅផ្នែកបន្ទាប់យើងខ្ញុំនឹងបកស្រាយពន្យល់អំពីព័ត៌មាន ឬគន្លឹះនានាពាក់ព័ន្ធនឹងការបង្កើតនូវបណ្តាញសង្គមដ៏មានប្រសិទ្ធភាពមួយ។

## ហេតុអ្វី ខ្ញុំត្រូវការបង្កើតបណ្តាញសង្គម?

ការបង្កើតបណ្តាញសង្គមនឹងជួយរូបអ្នកឱ្យទទួលបាននូវការងារ ឬព័ត៌មានអំពីការងារ។ ការសិក្សា និងអង្កេតជាច្រើនបានបង្ហាញឱ្យដឹងថា ការទទួលបានការងារតាមរយៈបណ្តាញសង្គមគឺមានភាគរយច្រើន និងកើតមាននៅស្ទើរគ្រប់ប្រទេស ឬសង្គមមនុស្ស។ ចំណុចនេះគឺជាគន្លឹះ ឬឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជួយរូបអ្នកឱ្យទទួលបានព័ត៌មានពីឱកាសការងារដែលនៅទំនេរ ទំនោរ និងការវិវឌ្ឍរបស់សេដ្ឋកិច្ច និងទីផ្សារការងារ ព្រមទាំងព័ត៌មានជាច្រើនប្រភេទផ្សេងទៀតពាក់ព័ន្ធនឹងអាជីព។ យើងខ្ញុំសង្ឃឹមថា ប្រាកដជាមាននរណាម្នាក់ ដែលអ្នកធ្លាប់ស្គាល់បានប្រើប្រាស់នូវបណ្តាញសង្គមរបស់គេ ហើយទទួលបានការងារ ឬកម្មសិក្សាការងារជាក់ជាពុំខាន។

## តើខ្ញុំគួរបង្កើតបណ្តាញសង្គមនៅពេលណាទើបល្អ?

មានមនុស្សខ្លះយល់ថា ការបង្កើតបណ្តាញសង្គមគួរធ្វើឡើងនៅពេលអ្នកបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ឬត្រូវរង់ចាំរហូតដល់ពេលនោះ ឬក៏បង្កើតនៅពេលដែលអ្នកបាត់បង់ការងារ។ ការពិត ការយល់បែបនេះហាក់មានការយឺតពេលរួចទៅហើយ ចំពោះការប្រើប្រាស់នូវជំនាញដ៏មានសារសំខាន់នេះ។ ប្រការល្អបំផុតគឺអ្នកត្រូវចាប់ផ្តើមកិច្ចការនេះតាំងពីពេលនៅរៀន ឬពេលកំពុងបំពេញការងារដើម្បីទទួលបាននូវការស្គាល់ និងមានទំនាក់ទំនងជាមួយមនុស្សផ្សេងប្រកដោយលក្ខណៈទូលំទូលាយបំផុត។


តទៅទំព័របន្ទាប់

## តើខ្ញុំគួរបង្កើតបណ្តាញសង្គម នៅកន្លែងបែបណា?

ជាទូទៅ មិនមានកន្លែងជាក់លាក់ណាមួយដែលតម្រូវថាអ្នកត្រូវតែបង្កើតបណ្តាញសង្គមនៅទីនោះទេ។ ផ្ទុយទៅវិញ មានកន្លែងជាច្រើនដែលរួមបញ្ចូលទាំងលក្ខណៈបែបផ្លូវការនៅក្នុងការប្រជុំសមាគមជំនួញ ឬអ្នកឯកទេសវិជ្ជាជីវៈ ពិព័រណ៌ការងារ និងនៅក្នុងការិយាល័យការងារ។ ម្យ៉ាងទៀតអ្នកក៏អាចបង្កើតនូវបណ្តាញនេះ តាមរយៈលក្ខណៈក្រៅផ្លូវការផងដែរដូចជា ការជួបជជែកជាមួយមិត្តភ័ក្តិ គ្រួសារ និងអ្នកជិតខាងដែលស្គាល់គ្នា។

លើសពីនេះ អ្នកក៏អាចចូលរួមក្នុងក្លឹបសង្គម (social clubs) ក្រុមនិកាយសាសនា សកម្មភាពស្ម័គ្រចិត្ត កម្មសិក្សាការងារ ឬបទពិសោធន៍ក្នុងសកម្មភាពផ្សេងៗ ចូលរួមក្នុងសកម្មភាពបណ្តាញសង្គមតាមរយៈប្រព័ន្ធអ៊ីនធើណេតដើម្បីផ្ញើនូវលិខិត ឬការពិភាក្សាលើប្រធានបទផ្សេងៗជាដើម។ បច្ចុប្បន្ននេះ គេសង្កេតឃើញថា មានយុវជន និងសិស្ស-និស្សិតភាគច្រើនដែលរស់នៅក្នុងទីក្រុង ទីប្រជុំជននានាដែលមានសេវាអ៊ីនធើណេតបានតភ្ជាប់ទៅក្នុងបណ្តាញសង្គម ដូចជា Facebook ដើម្បីជជែក ឬឆ្លើយឆ្លងនូវលិខិតនានាបានយ៉ាងទូលំទូលាយ។





## តើខ្ញុំគួរបង្កើតបណ្តាញសង្គម តាមវិធីបែបណា?

បណ្តាញសង្គមគឺផ្តោតជាពិសេស នឹងមានមូលដ្ឋាននៅលើការទំនាក់ទំនងគ្នាជាមួយភាគីម្ខាងទៀតតាមរយៈការជជែកឆ្លើយឆ្លងគ្នាតាមអ៊ីម៉េល ការសរសេរសំបុត្រ ជាដើម។ អាស្រ័យហេតុនេះ សូមអ្នកចាប់ផ្តើមធ្វើការទំនាក់ទំនងសាកសួរនូវព័ត៌មាន និងចែករំលែកព័ត៌មានជាមួយបណ្តាញរបស់អ្នកតាមលទ្ធភាពដែលអាចធ្វើបាន។

ត្រូវចាំក្នុងចិត្តថា អ្នកអាចបង្កើតនូវបណ្តាញសង្គមដ៏ធំ និងមានប្រសិទ្ធភាពបានលុះត្រាណា អ្នកបានចាប់ផ្តើមអនុវត្តចេញពីការទំនាក់ទំនងនូវបណ្តាញសាមញ្ញៗ ពីមនុស្សម្នាក់ទៅច្រើននាក់។ ធម្មតា ការស្គាល់មនុស្សម្នាក់អាចនាំរូបអ្នកឱ្យទៅស្គាល់មនុស្សជាច្រើននាក់ផ្សេងទៀត ប្រសិនមនុស្សដែលអ្នកស្គាល់នោះមានបណ្តាញសង្គមច្រើន ឬទូលំទូលាយ។ នៅក្នុងជីវភាពប្រចាំថ្ងៃ ប្រហែលជាអ្នកនឹងនិយាយថា៖ ខ្ញុំស្គាល់លោក សុខ ដោយសារមិត្តភ័ក្តិរបស់ខ្ញុំគឺលោក សៅ ជាអ្នកណែនាំឱ្យស្គាល់ ហើយតាមរយៈលោក សុខ ខ្ញុំបានស្គាល់មនុស្សបីនាក់ផ្សេងទៀតគឺ នាងចាន់ លោកពុធ និងលោកទិត ដែលបានធ្វើឱ្យបណ្តាញសង្គមរបស់ខ្ញុំកាន់តែរីកចម្រើន។

# តើបណ្តាញសង្គមអាចផ្តល់នូវភាពអវិជ្ជមានដែរឬទេ?

ជួនកាល អ្នកខ្លះព្យាយាមគេចវៀសពីការចូលរួមក្នុងបណ្តាញសង្គមដោយគេយល់ថា មនុស្សភាគច្រើនមិនមានភាពស្មោះត្រង់ និងមិនអាចទុកចិត្តបាន។ អ្នកខ្លះ គិតថាការបង្កើតបណ្តាញសង្គមប្រាកដជាពុំមានជោគជ័យដោយហេតុថាពួកគេមិនមានទំនុកចិត្ត មានការអៀនខ្មាស មិនហ៊ាន និងមិនមានជំនាញទំនាក់ទំនងជាដើម។

ប្រសិនអ្នកធ្លាក់ចូលទៅក្នុងការភាន់ច្រឡំបែបនេះ អ្នកនឹងមានការប្រថុយប្រថានចំពោះកិច្ចការ ដោយសារការមិនឱ្យតម្លៃខ្លួនឯង ហើយបានបោះបង់ឱកាសក្នុងការទទួលបានព័ត៌មានផ្សេងៗដែលពាក់ព័ន្ធការងារ។ ហេតុនេះ អ្នកត្រូវប្តូរនូវគំនិតនេះចេញ ហើយព្យាយាមយកឈ្នះលើការបង្កើតបណ្តាញសង្គមរបស់អ្នកឱ្យបាន។

ហេតុនេះ សូមអ្នកពិនិត្យមើលនូវចំណុចខ្លះៗដូចខាងក្រោម ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីក្តីមន្ទិលរបស់អ្នកចំពោះការបង្កើតបណ្តាញសង្គម។

## អ្នកដែលបង្កើតបណ្តាញសង្គម ជាមនុស្សដែលមិនមានភាពស្មោះត្រង់

ជាការធម្មតា មនុស្សដែលបង្កើតបណ្តាញសង្គមភាគច្រើនមិនសូវមានភាពស្មោះត្រង់ ប៉ុន្តែយ៉ាងហោចណាស់ពួកគេជាមនុស្ស ដែលមានជោគជ័យនៅក្នុងការបង្កើតបណ្តាញនោះ។ គេសម្គាល់ឃើញថា មនុស្សដែលទទួលបានផលប្រយោជន៍យ៉ាងខ្លាំងពីការបង្កើតបណ្តាញសង្គម គឺជាប្រភេទមនុស្សដែលពូកែក្នុងការកសាងនូវចំណងមិត្តភាព និងមាន



ភាពស្មោះត្រង់ចំពោះសមាជិក ឬមនុស្សនៅក្នុងបណ្តាញរបស់ខ្លួន ដែលអ្នកខ្លះពិតជាបានទទួលនូវវឌ្ឍនភាពយ៉ាងពិតប្រាកដក្នុងការកសាងបណ្តាញរបស់ខ្លួន។ មនុស្សស្ថិតក្នុងជំពូកនោះច្រើនមានសមានចិត្តទូលាយ រួសរាយរាក់ទាក់ និងចេះជួយយកអាសាអ្នកដទៃ ដោយស្មោះអស់ពីចិត្តនៅក្នុងគ្រាមានអាសន្ន អាស្រ័យដោយពួកគេធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍នៃការជួយជ្រោមជ្រែងពីមនុស្សដទៃនៅក្នុងបណ្តាញរបស់ពួកគេកាលពីពេលមុន។

## ខ្ញុំមិនអាចបង្កើតបណ្តាញសង្គមបាន ពីព្រោះខ្ញុំមានភាព-អៀនខ្មាស់ និងមិនមានទំនុកចិត្តក្នុងការទំនាក់ទំនង

ជាប្រការសំខាន់ដែលអ្នកគួរចងចាំថា មនុស្សគ្រប់គ្នាតែងមានអារម្មណ៍ខុសប្រក្រតីដូចជាភ័យ ឬបារម្ភ កាលណាជួបប្រាស្រ័យកិច្ចការ ឬទំនាក់ទំនងជាមួយមនុស្សថ្មីៗ ដែលពុំធ្លាប់ស្គាល់គ្នាពីមុនមក។ ប៉ុន្តែ អ្នកត្រូវគិតថានៅក្នុងព្រឹត្តិការណ៍ ឬការជួបជុំពួកមនុស្សដែលស្ថិតនៅក្នុងបណ្តាញសង្គម គ្រប់គ្នាសុទ្ធសឹងមានអារម្មណ៍ប្រហាក់ប្រហែលគ្នា អាស្រ័យដោយទាំងរូបគេ និងរូបអ្នកគឺជាមនុស្សថ្មីដូចគ្នា។ ការគិតដូច្នេះអាចជួយលើកទឹកចិត្តរបស់អ្នកក្នុងការបង្កើតនូវ


តទៅទំព័របន្ទាប់

បណ្ដាញ ឬស្គាល់មនុស្សឱ្យបានកាន់តែច្រើនថែមទៀត។

ការពិត ការបង្កើតបណ្ដាញសង្គមគឺសំដៅដល់ការចែករំលែកព័ត៌មានផ្សេងៗ ដូច្នេះប្រសិនបើអ្នកអាចឆ្លងផុតនូវរបាំងដែលអ្នកយល់ថាជាការលំបាក ហើយប្រែក្លាយនូវឱកាសនៃការជួបជុំនោះ ឱ្យប្រព្រឹត្តិទៅហាក់ដូចជាការដែលអ្នកកំពុងតែជជែកជាមួយមិត្តភ័ក្តិ នោះអ្វីៗនឹងមានភាពប្រសើរឡើងជាក់ជាពុំខាន។

ប្រសិនបើអ្នកនៅពុំទាន់មានទំនុកចិត្តចំពោះការបង្កើតបណ្ដាញជាលក្ខណ:ជួបមុខផ្ទាល់ ដូច្នេះអ្នកគួរគិតអំពីការផ្ញើយឆ្លងតាមរយ:អ៊ីម៉ែល Facebook ឬទូរសព្ទក៏បានដែរ។

## តើធ្វើដូចម្ដេចដើម្បីតម្រង់ទិសឆ្ពោះទៅភាពជោគជ័យក្នុងការបង្កើតបណ្ដាញសង្គម?

មនុស្សភាគច្រើនជឿថា ការចូលរួម ឬបង្ហាញខ្លួនតាមបែបធម្មតានៅក្នុងពិធីនៃការជួបជុំបែបបណ្ដាញសង្គមនានា គឺជាការស្រេច ហើយនឹងនាំគេទៅដល់ជោគជ័យក្នុងការបង្កើតនូវបណ្ដាញរបស់ខ្លួន។ ប៉ុន្តែការគិតដូច្នោះហាក់មិនជាការត្រឹមត្រូវនោះទេ បានន័យថា អ្នកត្រូវរៀបចំខ្លួន និងប្រតិបត្តិនូវកិច្ចការសំខាន់ៗមួយចំនួន មុនពេលចូលរួមក្នុងព្រឹត្តិការណ៍ជួបជុំគ្នាប្រភេទនោះ។ កិច្ចការនោះគឺសំដៅដល់ការរៀបចំមុនពេលចូលរួម អំឡុងពេលពិធី និងក្រោយពេលពិធី ដើម្បីប្រែក្លាយបទពិសោធន៍របស់អ្នកក្នុងកិច្ចការនេះឱ្យទទួលបានជោគជ័យ។

អាស្រ័យហេតុនេះ សូមអ្នកពិនិត្យ និងយកចិត្តទុកដាក់កត់ចំណាំនូវចំណុចសំខាន់ៗមួយចំនួន ដែលនឹងបកស្រាយជូនជាគន្លឹះ និងបទពិសោធន៍ជាលំដាប់លំដោយដូចតទៅ៖

## ការរៀបចំខ្លួនមុនពេលចូលរួមព្រឹត្តិការណ៍ជួបជុំបែបបណ្ដាញសង្គម

### ❶ កំណត់អំពីគោលបំណងរបស់អ្នកក្នុងការចូលរួមព្រឹត្តិការណ៍

អ្នកគួរសួរទៅកាន់ខ្លួនឯងនូវសំណួរមួយចំនួនដូចតទៅ៖

- តើហេតុអ្វីក៏ខ្ញុំត្រូវចូលរួមក្នុងព្រឹត្តិការណ៍ជួបជុំបណ្ដាញសង្គម?
- តើខ្ញុំចូលរួមដើម្បីប្រមូលនូវព័ត៌មានឱ្យបានច្រើនអំពីការផ្លាស់ប្ដូរអាជីព ឬក៏សកម្មភាពនៃការស្វែងរកការងារ?
- តើខ្ញុំគួរបង្កើតនូវទំនាក់ទំនងជាមួយមនុស្សថ្មីប៉ុន្មាននាក់?
- តើមានមនុស្សពិសេសណាម្នាក់ដែលខ្ញុំប៉ងជួបជជែកដែរឬទេ?

### ❷ ស្លៀកពាក់ឱ្យបានសមរម្យបំផុតតាមលទ្ធភាពរបស់អ្នក

ត្រូវស្លៀកពាក់ប្រកបដោយភាពសមរម្យថ្លៃថ្នូរ និងមានលក្ខណ:ជាអ្នកធ្វើការក្នុងអាជីព។ ឧទាហរណ៍: ពាក់អាវធំ ក្រវ៉ាត់ក សម្រាប់បុរស។ ប៉ុន្តែអ្នកអាចស្លៀកពាក់ធម្មតាបានលុះត្រា អ្នករៀបចំកម្មវិធីជូនដំណឹង និងតម្រូវដូច្នោះ។

អ្នកត្រូវប្រាកដក្នុងចិត្តថាការរៀបចំសម្លៀកបំពាក់ និងឥរិយាបថរបស់អ្នកមានភាពសមរម្យ ដើម្បីបង្ហាញទៅដល់មនុស្សដែលអ្នកជួបជជែកមានអារម្មណ៍ថា អ្នកជាមនុស្សមានការយល់ដឹងក្នុងវិជ្ជាជីវ:របស់ខ្លួន និងអាចរាប់អានជាមិត្តបាន។

### ❸ រៀបចំនាមបណ្ណ ឬលេខទំនាក់ទំនងរបស់អ្នក

ត្រូវរៀបចំបោះនាមបណ្ណប្រសិនមិនទាន់មាន ឬកែសម្រួលនាមបណ្ណចាស់របស់អ្នកឱ្យមានព័ត៌មានគ្រប់គ្រាន់ងាយទំនាក់ទំនង។ គួរយកនាមបណ្ណទៅជាមួយឱ្យបានច្រើនគ្រប់គ្រាន់ ដើម្បីអាចអនុញ្ញាតឱ្យអ្នកចែកទៅដល់មនុស្សនានាដោយសេរី និងមិនមានការខ្វះខាត។ម្យ៉ាងទៀត កុំភ្លេចយកសៀវភៅកត់ត្រា និងប៊ិចទៅជាមួយផង។



## នៅក្នុងអំឡុងពេលចូលរួមព្រឹត្តិការណ៍ជួបជុំបែបបណ្តាញសង្គម

### ❶ ចូលរួមឱ្យទាន់ពេលវេលាដែលបានកំណត់

អ្នកត្រូវទៅឱ្យទាន់ពេលវេលា និងកុំភ្លេចចុះឈ្មោះនៅក្នុងបញ្ជីនៅកន្លែងទទួលភ្ញៀវ។ ពេលចុះឈ្មោះអ្នកអាចដាក់លេខទំនាក់ទំនង ឬ

### ❷ ពាក់ស្លាកឈ្មោះជាប់នៅលើអាវប្រសិនមានការតម្រូវដូច្នោះ

នៅក្នុងពិធីជួបជុំបែបនេះភាគច្រើន គឺតម្រូវឱ្យពាក់ស្លាកឈ្មោះ ដើម្បីជាការងាយស្គាល់ឈ្មោះចំពោះអ្នកជួបគ្នាដំបូង។ អ្នកគួរពាក់ស្លាកឈ្មោះនៅផ្នែកខាងស្តាំនៅលើអាវ ដើម្បីបង្កការស្រួលឱ្យភាគីដែលអ្នកជួបនិយាយងាយអាន ជាពិសេសនៅពេលចាប់ដៃស្វាគមន៍

### ❸ ណែនាំខ្លួនឯងឱ្យបានល្អទៅមនុស្សនានានៅក្នុងពិធី

ត្រូវចេះណែនាំខ្លួនឯងទៅកាន់មនុស្សថ្មីៗ ដោយការគួរសមដូចជាការជម្រាបសួរ ឬចាប់ដៃចាដើម។ ប្រពៃណីខ្មែរស្ត្រីនិយមជម្រាបសួរ ដោយឡែកបុរសឥឡូវនិយមចាប់ដៃករណីមនុស្សក្នុងវ័យប្រហាក់ប្រហែលគ្នា ឬជម្រាបសួរទៅកាន់មនុស្សចាស់ជាងខ្លួន។ អ្នកត្រូវចាំនូវចំណុចទាំងអស់នេះ ប៉ុន្តែប្រយ័ត្នចំពោះការចាប់រលាក់ដៃ គឺមិនត្រូវចាប់ច្របាច់ខ្លាំងពេកទេ ព្រោះនាំឱ្យឈឺ ឬជាការមិនគួរសមចំពោះភាគីម្ខាងទៀត។

គួរចំណាយពេលខ្លីល្មមសម្រាប់ការណែនាំខ្លួនអំពីឈ្មោះ ការងារ ឬអាជីព ព្រមទាំងចំណង់ចំណូលចិត្តផ្ទាល់ខ្លួនរបស់អ្នក ។ល។




### ❹ ត្រូវចេះស្តាប់ការនិយាយរបស់អ្នកដទៃខ្លះផង

បន្ទាប់ពីបានណែនាំខ្លួនឯងរួចហើយអ្នកត្រូវចេះស្តាប់ការនិយាយរបស់ភាគីសន្ទនាវិញម្តង។ បន្តការសន្ទនាជាហូរហែពីនេះពីនោះ រហូតដល់ការបញ្ចប់សាច់រឿងដែលចង់និយាយ។ ប៉ុន្តែ មិនគួរអូសបន្លាយរូរពេកទេ ព្រោះអាចបណ្តាលឱ្យមានការធុញថប់ទៅវិញ។

### ❺ ការលាគ្នាពេលបញ្ចប់កិច្ចសន្ទនា

ពេលសន្ទនាពីនេះពីនោះ និងណែនាំខ្លួនរួចហើយ អ្នកអាចជូននាមបណ្ណទៅវិញទៅមកជាមួយភាគីម្ខាងទៀតតាមពេលដ៏សមគួរ ដូចជាបន្ទាប់ពីណែនាំខ្លួន។ ពេលសន្ទនាចប់អ្នកអាចចាប់ដៃម្តងទៀត ដើម្បីលាគ្នា ឬអរគុណ និងរីករាយចំពោះជួបគ្នា និងការជជែក។

### ❻ បន្តជួបនិយាយជាមួយមនុស្សផ្សេងៗតាមវិធីដូចខាងដើម

បន្ទាប់ពីបានជួបជជែកជាមួយមនុស្សម្នាក់រួចហើយ អ្នកត្រូវបន្តអនុវត្តនូវវិធីដូចៗគ្នាក្នុងការចូលទៅប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀតៗ ដើម្បីព្យាយាមស្វែងយល់ និងបង្កើតបណ្តាញរបស់អ្នកឱ្យបានកាន់តែច្រើន កាន់តែប្រសើរ។

## បន្ទាប់ពីពេលចូលរួមព្រឹត្តិការណ៍ជួបជុំបែបបណ្តាញសង្គម

### ● រំឭក និងបន្តតាមដានចំពោះវឌ្ឍនភាពនៃទំនាក់ទំនងបង្កើតថ្មី

អ្នកគួរសរសេរនូវលិខិត ឬការអរគុណដល់មនុស្សដែលអ្នកបានជួបជជែក។ ករណីនេះ អ្នកអាចបន្តពង្រីក និងវឌ្ឍនភាពទំនាក់ទំនងដល់មនុស្សសំខាន់ៗដែលបានឆ្លើយឆ្លងលិខិតជាមួយអ្នក៕

សូមប្រិយមិត្ត និងមិត្តអ្នកអានទាំងអស់រង់ចាំអានបន្ត
អំពីការបង្កើតបណ្តាញតាមរយៈប្រព័ន្ធអ៊ីនធើរណិត និងការស្វែងរក
ការងារដែលមិនមានផ្សព្វផ្សាយជាសាធារណៈ!



ការរៀបចំខ្លួនចូលសម្ភាសន៍ការងារ

# ប្រភេទនៃសំណួរ និង របៀបនៃការឆ្លើយសំណួរ ក្នុងពេលសម្ភាសន៍ការងារ

នៅក្នុងការផ្សាយលេខ (០០៧) ព្រឹត្តិបត្រការងារបាន បង្ហាញជូនមិត្តអ្នកអាន និងអ្នកស្វែងរកការងារធ្វើ អំពីគន្លឹះក្នុងការឆ្លើយសំណួរនៅពេលសម្ភាសន៍ការងារ ដែល កាលនោះ យើងខ្ញុំបានបកស្រាយអំពីប្រភេទនៃសំណួរដែល និយោជកសាកសួរបេក្ខជន (អ្នកដាក់ពាក្យសុំការងារ) អំពីការ គិតបែបជាយុទ្ធសាស្ត្រក្នុងការបំពេញការងារ និងសំណួរអំពីការ បង្កើតទំនាក់ទំនងក្នុងកន្លែងធ្វើការងារ។

ក្នុងការផ្សាយលេខនេះ យើងនឹងពិនិត្យមើលជាបន្តអំពី ប្រភេទសំណួរផ្សេងៗដូចខាងក្រោម៖

## ❖ សំណួរអំពីការយល់ដឹងរបស់បេក្ខជនចំពោះកិច្ចការជំនួញ

អ្នកស្វែងរកការងារធ្វើ បេក្ខជនដាក់ពាក្យសុំការងារ និងបេក្ខជនត្រៀមខ្លួនចូលសម្ភាសន៍ទាំងអស់ត្រូវចងចាំថា អ្នកគួរយល់ដឹងពីកិច្ចការ និងស្ថានភាពជំនួញជាទូទៅដោយពុំចាំបាច់តម្រូវថាស្ថាប័ន ឬក្រុមហ៊ុន ដែលអ្នកកំពុងដាក់ពាក្យសុំការងារជាប្រភេទស្ថាប័ន ឬក្រុមហ៊ុនបែបណានោះឡើយ។

ដូច្នេះ អ្នកគួរយល់ដឹងអំពីស្ថានភាពនៃកិច្ចការជំនួញ ព្រមទាំងអាចរកវិធីក្នុងការចូលរួមចំណែកលើកស្ទួយស្ថាប័ន ឬក្រុមហ៊ុនដែលអ្នកចង់ធ្វើការទៀតផង។

### ចំពោះយោបល់របស់អ្នក តើអ្នកដឹងថាហេតុអ្វីអតិថិជនជ្រើសរើសផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនយើង?

សំណួរប្រភេទនេះប្រហែលជាមានលក្ខណៈទូទៅ និងសាមញ្ញចំពោះអ្នកទាំងឡាយណា ដែលធ្លាប់រៀនមុខវិជ្ជាផ្នែកទីផ្សារពីមុនមក។

អ្នកអាចសាកល្បងឆ្លើយថា៖ អ្វីដែលខ្ញុំគិតជាបឋម និងសំខាន់ជាងគេគឺ ក្រុមហ៊ុនបានកសាងនូវកិត្តិនាម និងទំនុកចិត្តដ៏ល្អប្រសើរ ដែលជាហេតុបណ្ដាលឱ្យអតិថិជនមានការគិតពិចារណា និងសម្រេចចិត្តជ្រើសរើសផលិតផល និងប្រើប្រាស់សេវារបស់ក្រុមហ៊ុនដោយស្ម័យប្រវត្តិ។ ម្យ៉ាងវិញ

*អត្ថបទដកស្រង់ និងប្រែសម្រួលដោយ **ហៃ ហ៊ុនឡេង** ចេញពីឯកសារ៖ Charlie Gibbs (2009). How to Answer Hard Interview Questions and Everything else You Need to Know to Get the Job You Want. Howtobooks, 2nd Ed. សម្រាប់ព័ត៌មានបន្ថែមសូមលោកអ្នកអញ្ជើញរកអាន ឬទំនាក់ទំនង **«បណ្ណាល័យការងារ»** របស់ ទីភ្នាក់ងារជាតិមុខរបរ និងការងារដែលមានទីតាំងនៅក្នុងស្នាក់ការកណ្ដាល និងគ្រប់មជ្ឈមណ្ឌលការងារទាំងអស់។*

តទៅទំព័របន្ទាប់

ទៀត ខ្ញុំយល់ឃើញថា អតិថិជនបានចាត់ទុកក្រុមហ៊ុនជាភ្នាក់ងារ ឬអ្នកផ្គត់ផ្គង់ដ៏ចម្បងមួយសម្រាប់តម្រូវការរបស់ពួកគេ ហើយពួកគេតែងមានការរំពឹងគិតអំពីផលិតផលល្អ តម្លៃសមរម្យ និងការផ្គត់ផ្គង់ត្រឹមត្រូវតាមកាលៈទេសៈ។

## តើក្រុមហ៊ុនអាចធ្វើយ៉ាងដូចម្ដេចដើម្បីឱ្យផលិតផល និងសេវាកម្មមានកម្រិតប្រជួតប្រជែងកាន់តែខ្លាំងឡើង?

លក្ខខណ្ឌទូទៅនៅក្នុងទីផ្សារជំនួញ ក្រុមហ៊ុនអាចបង្កើនចំណូលបន្ថែមតាមរយៈចំណុចសំខាន់ពីរបែបគឺៈ ការលក់ផលិតផលឱ្យបានបរិមាណច្រើនក្នុងពេលតែមួយ ឬក៏បង្កើនវិសាលភាពនៃទំនិញ និងសេវាកម្ម។ ចំណុចខាងក្រោយនេះអាចអនុវត្តទៅបានលុះណាមានការបញ្ចុះតម្លៃ ឬបង្កើនតម្លៃនៃការលក់។ បេក្ខជនឆ្លើយសំណួរអាចបញ្ជាក់បន្ថែមទៀតថា ខ្ញុំមិនបានដឹងច្បាស់អំពីវិធីសាស្ត្រនៃការអនុវត្តរបស់ក្រុមហ៊ុនយ៉ាងដូចម្ដេចនោះទេ ហេតុនេះហាក់មានការលំបាកក្នុងការផ្ដល់ជាយោបល់ ឬចម្លើយ។ ប៉ុន្តែតើមានវិធីណា ឬពេលវេលាសមគួរដែលយើងអាចពិនិត្យមើលជាលម្អិតនាថ្ងៃមុខបានដែរឬទេ?

សំណួរប្រភេទនេះចង់បញ្ជាក់អំពីភាពស្មោះត្រង់ក្នុងការទទួលស្គាល់ថាអ្នកមិនមានព័ត៌មានពិតប្រាកដគ្រប់គ្រាន់ ដើម្បីនឹងឆ្លើយទៅសំណួរ។ សូមកត់សម្គាល់ថា បេក្ខជនដែលឆ្លើយទៅនឹងសំណួរដោយមិនបានសិក្សាឱ្យបានច្បាស់លាស់ ហើយបែរជាមានអំណួតចំពោះចម្លើយខ្លួនឯង នោះមិនមែនជាការប្រសើរទេ។ ផ្ទុយទៅវិញ វាអាចបណ្ដាលឱ្យអ្នកសម្ភាសន៍មានការយល់ខុស ដែលអាចផ្ដល់ជាផលអាក្រក់ចំពោះលទ្ធផលចុងក្រោយទៅវិញក៏សឹងមាន។

ប៉ុន្តែចំណុចដែលល្អគឺការឆ្លើយដោយមានទំនុកចិត្ត និងស្នើសុំការពន្យល់លម្អិតដោយការសិក្សាស្រាវជ្រាវបន្ថែមនៅពេលក្រោយទៀត ប្រសិនមានការអនុញ្ញាត្ត និងមានពេលវេលាគ្រប់គ្រាន់។

## តើ អ្វីជានិន្នាការទីផ្សារដែលអាចផ្ដល់ផលប៉ះពាល់មកដល់ក្រុមហ៊ុនយើង?

សំណួរប្រភេទនេះគឺជាឱកាសមួយដ៏ល្អសម្រាប់អ្នកធ្វើការឆ្លើយដោយទាក់ទាញការចាប់អារម្មណ៍ពីអ្នកសម្ភាសន៍។ ប្រការសំខាន់គឺអ្នកត្រូវតែយល់អំពីស្ថានភាព និងតួលេខជាក់ស្ដែងនៅក្នុងទីផ្សារជំនួញ និងកិច្ចការរបស់អនាគតនិយោជករបស់អ្នក។ ឧទាហរណ៍ៈ ប្រសិនក្រុមហ៊ុនផលិត ឬលក់ផលិតផលដែលមហាជន ឬសង្គមគិតថាមិនសូវល្អសម្រាប់សុខភាព ឬ បរិដ្ឋានដូចជា បារី ស្រា និងសារជាតិខ្លាញ់ ឬសារជាតិផ្អែមក្នុងចំណី អាហារជាដើម។ ត្រង់ចំណុចនេះអ្នកគួរយល់ដឹងពីស្ថានភាពទូទៅនៅក្នុងសង្គមពាក់ព័ន្ធនឹងបញ្ហានេះ ដូចជាតើប្រព័ន្ធឃោសនា និងច្បាប់មានហាមប្រាមអំពីផលិតផលទាំងអស់នោះដែរឬទេ?

អាស្រ័យហេតុនេះ ការឆ្លើយរបស់បេក្ខជនត្រូវមានភាពស៊ីសង្វាក់គ្នារវាងការចរាចរផលិតផលក្នុងទីផ្សារ និងកត្តាផ្សេងៗ ដែលអាចបង្កឱ្យមានការប៉ះពាល់ទៅដល់ទំនិញទាំងនោះ។ ម្យ៉ាងទៀត បេក្ខជនគួរតែសិក្សាផងដែរអំពីបម្រាម និងការលើកលែងនានាដែលមានចែងក្នុងបញ្ញត្តិនៃច្បាប់ ដើម្បីជាការប្រាកដក្នុងចិត្តថាផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនប្រព្រឹត្តទៅដោយរលូនតាមការគាំទ្រ និងស្របច្បាប់ ជាដើម។



# សំណួរអំពីភាពជាអ្នកដឹកនាំរបស់បេក្ខជនក្នុងការបំពេញការងារ

នៅក្នុងបរិបទការងារ និងអាជីព បុគ្គលិក ឬអ្នកបំពេញការងារទាំងអស់នឹងត្រូវជួបប្រទះ ហើយប្រឈមជាមួយការវិវឌ្ឍរបស់ការងារ ព្រមទាំងការលេចឡើងនូវបញ្ហាថ្មីៗដែលត្រូវដោះស្រាយ។ ចំណុចចាប់ផ្តើម និងដំណើរការក្នុងការងារ គឺប្រៀបបានទៅនឹងការខិតខំដើរឡើងភ្នំដែលតម្រូវឱ្យមានការតស៊ូ អត់ធ្មត់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីទៅដល់គោលដៅ។ ជាទូទៅ ក្នុងការបំពេញការងារបុគ្គលិកម្នាក់ៗត្រូវខំធ្វើការតាមតួនាទី និងភារកិច្ចរបស់ខ្លួន មិនតែប៉ុណ្ណោះពួកគេខ្លះអាចជួយធ្វើការជំនួសអ្នកដទៃទៀតផង។

បុគ្គលិកខ្លះបានព្យាយាមពន្យល់អំពីជោគជ័យនៅក្នុងការងាររបស់ពួកគេ តាមរយៈការបង្ហាញឱ្យឃើញអំពីកម្រិតនៃមុខតំណែង ឬតួនាទីដែលទទួលបានក្នុងការងារ ប៉ុន្តែពុំបានរួមបញ្ចូលនូវចំណុចសំខាន់ៗផ្សេងទៀត ដែលមាននៅក្នុងវង្វង់ការងារនោះទេ។ ហេតុនេះ សំណួរដែលនឹងបង្ហាញជូនខាងក្រោម គឺសំដៅទៅដល់តួនាទីក្នុងការងារដែលរួមបញ្ចូលទាំងការដឹកនាំអ្នកដទៃ ដើម្បីឈានទៅទទួលបានផលប្រយោជន៍រួម និងក្នុងបំណងល្អ។



***សូមបរិយាយអំពីពេលដែលអ្នកត្រូវសម្របសម្រួលការងាររបស់អ្នកដទៃ។ ● តើអ្នកមានបំណងទទួលបានលទ្ធផលបែបណា? ● តើអ្នករៀបចំកិច្ចការនោះយ៉ាងដូចម្តេច?***

នេះគឺជាសំណួរបែបទូទៅដែលចង់សួរអំពីភាពជាអ្នក-ដឹកនាំរបស់អ្នកនៅក្នុងការងារ។ ហេតុនេះ ចម្លើយគឺអាស្រ័យលើបទពិសោធន៍របស់អ្នកក្នុងការងារអ្វីមួយ។

អ្នកអាចឆ្លើយតាមលំនាំដូចនេះថា៖ ខ្ញុំធ្លាប់បម្រើការនៅក្នុងក្រុមហ៊ុនមួយ។ ពេលមួយ ក្រុមហ៊ុនបានរៀបចំធ្វើអង្កេតស្តីពីការពេញចិត្តរបស់បុគ្គលិកទាំងអស់ចំពោះកិច្ចការ និងការអនុវត្តរបស់ក្រុមហ៊ុន។ បន្ទាប់ពីប្រមូលបានលទ្ធផលរួចស្រេចហើយ ក្រុមហ៊ុនបានចាត់នូវក្រុមជនបង្គោលមួយក្រុមដើម្បីពិនិត្យលើលទ្ធផលទាំងនោះ។ ខ្ញុំក៏ត្រូវបានចាត់តាំងឱ្យទទួលកិច្ចការនេះដែរ។ ដាដំបូងខ្ញុំគិតថាក្រុមហ៊ុនគ្រាន់តែចង់ដឹងពីយោបល់របស់ក្រុមជនបង្គោលតែប៉ុណ្ណោះ ប៉ុន្តែផ្ទុយទៅវិញ លទ្ធផលតែទទួលបានពីអង្កេតនឹងប្រើសម្រាប់ជាការកែប្រែ ឬផ្លាស់ប្តូរកិច្ចការខ្លះៗក្នុងក្រុមហ៊ុន។ យោងតាមលទ្ធផលនៃអង្កេតបង្ហាញថា បុគ្គលិកភាគច្រើនបានបញ្ចេញយោបល់ថា ក្រុមហ៊ុនមិនសូវយកចិត្តទុកដាក់ជាមួយពួកគេ ឯការគ្រប់គ្រងក៏មិនសូវមានប្រសិទ្ធភាពនោះដែរ។ ដើម្បីកែលម្អបរិយាកាសការងារ និងការទំនាក់ទំនងឱ្យកាន់តែប្រសើរ ក្រុមហ៊ុនបានសម្រេចចិត្តចាត់តាំងក្រុមជនសកម្មមួយក្រុមឱ្យធ្វើការដោះស្រាយបញ្ហានេះ។ ជាថ្មីម្តងទៀត ខ្ញុំបានត្រូវជ្រើសតាំង និងអនុញ្ញាតឱ្យជ្រើសរើសសហ-ការី បី ឬបួននាក់ដើម្បីជួយកិច្ចការនេះ។ ក្រុមការងារត្រូវផ្តល់នូវអនុសាសន៍ត្រលប់ទៅក្រុមហ៊ុនវិញឱ្យទាន់តាមពេលវេលាកំណត់ ហេតុនេះខ្ញុំគិតថាត្រូវរើសមនុស្សសម្រាប់ក្រុមការងារដែលមានជំនាញប្លែកៗគ្នា ដើម្បីជួយសម្រេចកិច្ចការនេះឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពជូនដល់ក្រុមហ៊ុន។

ដើម្បីឱ្យកិច្ចការប្រព្រឹត្តទៅបានដោយរលូន ខ្ញុំបាន

តទៅទំព័របន្ទាប់

កោះប្រជុំសមាជិកក្រុម និងបែងចែកតួនាទីរៀងៗខ្លួន។ តាមរយៈការបែងចែកនេះ ខ្ញុំបានជ្រើសរើសឧបករណ៍ និងធនធានសម្រាប់ធ្វើការងារ ព្រមទាំងចាត់មនុស្សឱ្យបំពេញតាមតួនាទីរៀងៗខ្លួន។ នៅទីបំផុត ក្រុមការងាររបស់ខ្ញុំបានសម្រេចកិច្ចការជូនក្រុមហ៊ុនបានយ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលា គួរជាទីពេញចិត្ត។

ពិនិត្យទៅលើឧទាហរណ៍ខាងលើនេះ យើងឃើញថា ក្រុមការងារបានបង្ហាញពីភាពជាអ្នកដឹកនាំរបស់ប្រធានក្រុមក្នុងការសម្របសម្រួល និងការប្រើវិធីសាស្ត្រក្នុងការយកជោគជ័យលើការងារដែលបានដាក់ចេញដោយថ្នាក់លើ។

***សូមបង្ហាញអំពីជនគំរូណាម្នាក់ដែលមានជោគជ័យក្នុងការបង្កើនជំនាញនៃភាពជាអ្នកដឹកនាំ។ ០ តើជននោះអនុវត្តយ៉ាងដូចម្តេចទើបអាចទទួលបានជោគជ័យ?***

តើអ្នកមានជនគំរូ ឬវីរជនសម្រាប់យកតម្រាប់តាមក្នុងការបំពេញការងារដែរឬទេ?

ខ្ញុំធ្លាប់បំពេញការងារឱ្យប្រធានគ្រប់គ្រងម្នាក់ ឈ្មោះលោក ស័ក្តិ សិទ្ធ។ គាត់ជាប្រធានគ្រប់គ្រងលើបុគ្គលិកចំនួនដប់នាក់ រួមទាំងរូបខ្ញុំផង។ ខ្ញុំគិតថាគាត់ជាប្រធានដឹកនាំដ៏ពូកែ និងអស្ចារ្យ ទោះបីគាត់មិនសូវមានប្រិយភាពទៅមជ្ឈដ្ឋានខាងក្រៅក៏ដោយ។ គាត់ជាមនុស្សចេះយល់ចិត្ត និងមានការយកចិត្តទុកដាក់ចំពោះបុគ្គលិកដោយស្មើភាព និងមិនប្រកាន់ខ្លួន។ ពេលគាត់ដាក់ការងារឱ្យយើងធ្វើ យើងដឹងថាត្រូវធ្វើយ៉ាងម៉េច និងគាត់ចង់បានលទ្ធផលដូចម្តេច។ ពេលមានកំហុសគាត់ចង្អុលបង្ហាញ និងណែនាំឱ្យបំពេញការងារជាថ្មី។ ទោះបីគាត់មានចិត្តទូលាយ ប៉ុន្តែគាត់មិនមែនសម្រេចកិច្ចការដោយល្ងិតល្ងង់នោះទេ។ ម្យ៉ាងទៀត គាត់តែងរិះរកវិធីបង្កា និងជៀសវាងនូវរាល់កំហុសដែលធ្លាប់កើតមានកុំឱ្យលេចចេញនូវបាតុភាពជាថ្មីម្តងទៀត។ គាត់តែងលើកទឹកចិត្តឱ្យយើងធ្វើការឱ្យបានច្រើន និងពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ។

លោកប្រធានគឺជាបុគ្គលដ៏គួរឱ្យទុកចិត្ត និងមានការទទួលខុសត្រូវខ្ពស់ រាល់កិច្ចការពាក់ព័ន្ធនឹងបុគ្គលឯកជន ជាពិសេសបុគ្គលិកក្រោមបង្គាប់ តែងត្រូវបានរក្សាការសម្ងាត់។ ក្រៅពីទំនាក់ទំនង និងសកម្មភាពក្នុងវង្វង់ការងារ លោកប្រធានក៏ជាមនុស្ស ដែលចេះយល់ពីអារម្មណ៍របស់បុគ្គលិកផងដែរ ដូចជាការបង្កបរិយាកាសរីករាយក្នុងការងារ ការ-រៀបចំពិធីខួបកំណើតឱ្យបុគ្គលិក ឬជប់លៀងពេលសម្រាកពីការងារ ឬជួយបុគ្គលិកពេលមានធុរៈផ្សេងៗ។

ខ្ញុំយល់ថាលោកប្រធានគ្រប់គ្រង ស័ក្តិ សិទ្ធ គឺជាបុគ្គលដ៏ប្រសើរនៅក្នុងការគ្រប់គ្រងការងារ។ ខ្ញុំបានគិត និងយកគំរូតាមឥរិយាបថ និងរបៀបធ្វើការងាររបស់គាត់ ជាពិសេសនៅពេលដែលអាជីព និងការងាររបស់ខ្ញុំកាន់តែមានការរីកចម្រើនក្នុងពេលអនាគត។

ឧទាហរណ៍ខាងលើនេះបង្ហាញថា មនុស្សម្នាក់ៗគួរតែជ្រើសយកនូវបុគ្គលគំរូរបស់ខ្លួនមួយ ដើម្បីជាមាគ៌ាឆ្ពោះទៅកាន់ជោគជ័យក្នុងការងារ។ ពុំនោះសោត ការមិនបានតាំងចិត្ត និងមិនមានវីរជនក្នុងចិត្តអាចបណ្តាលឱ្យអ្នកខ្វះលំនឹងក្នុងផ្លូវចិត្ត ហើយហាក់មានភាពស្រពិចស្រពិលនៅក្នុងដំណើរផ្លូវឆ្ពោះទៅកាន់អនាគត និងភាពជោគជ័យក្នុងការងាររបស់ខ្លួន។



**សូមរង់ចាំអានលេខបន្ត ស្តីពីប្រភេទសំណួរផ្សេងៗ ដែលចោទសួរដោយនិយោជក ឬស្ថាប័នផ្តល់ការងារ!!!**



លិខិតបទដ្ឋានគតិយុត្ត

## ការបង្កើតកិច្ចសន្យាការងារ

# អានុភាពនៃកិច្ចសន្យាការងារ

អ្វីទៅជាអានុភាពនៃកិច្ចសន្យាការងារ? តើកិច្ចសន្យាការងារមួយបង្កើតអានុភាពនៅពេលណា? អានុភាពនៅទីនេះគឺសំដៅទៅលើអានុភាពគតិយុត្តដែលជាកម្លាំងចាប់បង្ខំតាមផ្លូវច្បាប់ឱ្យបុគ្គលត្រូវតែប្រតិបត្តិទៅតាមខដែលបានសន្យានៅក្នុងកិច្ចសន្យា។ ជាទូទៅ កិច្ចសន្យាការងារមួយមានអានុភាពអាចអនុវត្តបានគឺនូវពេលដែលការបង្កើតកិច្ចសន្យានោះស្របទៅតាមបញ្ញត្តិច្បាប់ ស្របទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ជាលក្ខខណ្ឌសុពលភាពនៃការបង្កើតកិច្ចសន្យា។



លើសពីនេះទៅទៀត អនុលោមតាមមាត្រា ២២ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាបានចែងថា កិច្ចសន្យាត្រូវតែកើតចេញពីឆន្ទៈសេរីរបស់គូភាគី ដោយសន្មត់បានថាជាច្បាប់របស់គូភាគី ដូចនេះអានុភាពគតិយុត្តដែលកើតចេញពីកិច្ចសន្យា គឺមានកម្លាំងដាក់កាតព្វកិច្ចចំពោះគូភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ឬសំដៅដល់អានុភាពចាប់បង្ខំតាមផ្លូវច្បាប់ដែលបុគ្គលមិនអាចបដិសេធបាន ប៉ុន្តែក្នុងករណីខ្លះកិច្ចសន្យាអាចមានអានុភាពចំពោះតតិយជន ប្រសិនបើ ខនៃកិច្ចសន្យាមានចែងពីអានុភាពចំពោះតតិយជនដែលបណ្តាលមកពីការអនុវត្តកិច្ចសន្យាមិនបានល្អ ឬអាចជាការព្រមព្រៀងផ្សេងៗទៀតដែលកើតចេញពីតម្រូវការ និងឆន្ទៈសេរីរបស់គូភាគី។

អនុវត្តដូចគ្នាចំពោះកិច្ចសន្យាការងារ ដែលកើតឡើងដោយសារការព្រមរវាងគូភាគីបានបង្កើតនូវកាតព្វកិច្ចទៅតាមវិធាននៃការព្រមព្រៀងនៃក្របខ័ណ្ឌការងារ និងស្របទៅតាមវិធាននៃច្បាប់ការងារខ្មែរ ដោយក្នុងនោះនិយោជិតបានសន្យាថានឹងបំពេញការងារជូននិយោជកក្នុងនាមនិយោជកដើម្បីប្តូរមកវិញនូវប្រាក់កម្រៃប្រចាំខែ។ មានន័យថារាល់គ្រប់កិច្ចព្រមព្រៀងទាំងឡាយណាដែលបង្កើតឡើងដោយភាគីនៃកិច្ចសន្យាការងារ ដែលស្របទៅតាមវិធានដែលបានសន្មត់ដោយគូភាគី គឺមានអត្ថន័យគ្រប់គ្រាន់ក្នុងការចាប់បង្ខំឱ្យគូភាគីត្រូវតែប្រតិបត្តិតាមភាគី គឺត្រូវតែគោរពវិធានដែលបានសន្មត់ឡើងដោយគូភាគីផ្ទាល់ ឬច្បាប់របស់គូភាគី ដែល



*អត្ថបទរៀបចំ និងដកស្រង់ចេញពីឯកសារច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ដោយលោក **សុខុន ដារីដ** (អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ) និងលោកស្រី **ប៉ូលី បញ្ញា** (គ្រូបង្រៀនកម្រិតឧត្តមនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)។*

បានបញ្ញត្តិនៅក្នុងកិច្ចសន្យាការងារសុពលមួយ និងស្របទៅនឹងវិធាននៃច្បាប់ការងារខ្មែរ។

ទាំងអស់នេះអាចឱ្យយើងធ្វើការសិក្សាបែងចែកចំពោះអានុភាពនៃកិច្ចសន្យាការងារដូចជា អានុភាពចំពោះគូភាគីតតិយជននិងអានុភាពចំពោះចៅក្រម។

## អានុភាពរវាងគូភាគី

អនុលោមតាមបទប្បញ្ញត្តិនៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ដែលកំណត់ថាកិច្ចសន្យា គឺជាច្បាប់របស់គូភាគី ទាំងនេះមានអត្ថន័យគ្រប់គ្រាន់ចំពោះរាល់គ្រប់កិច្ចសន្យាទាំងអស់ ក៏ដូចជាកិច្ចសន្យាការងារដែលត្រូវតែបង្ខំឱ្យគូភាគីត្រូវតែប្រតិបត្តិក្នុងនាមជាឪពុកគំរូ និងមិនអាចប្រកែកបាន។

### ● បង្ខំឱ្យគូភាគីត្រូវតែប្រតិបត្តិ

អានុភាពនៃកិច្ចសន្យាការងារដែលបង្ខំឱ្យគូភាគីត្រូវតែប្រតិបត្តិ មានន័យថាដាក់កាតព្វកិច្ចចំពោះគូភាគីនៃកិច្ចសន្យាការងារ ក្នុងនោះកូនបំណុលដែលជាភាគីនិយោជិតជាប់កាតព្វកិច្ចត្រូវតែប្រតិបត្តិទៅតាមការសន្យា ដែលគេសន្មត់បានថាជាតាវកាលិក ដែលកូនបំណុលត្រូវតែបំពេញដោយខានមិនបាន។




ដូចនេះរាល់កិច្ចសន្យាការងារទាំងឡាយដែលបង្កើតឡើងហើយស្របតាមបទប្បញ្ញត្តិច្បាប់ការងារគឺតម្រូវឱ្យគូភាគីត្រូវតែប្រតិបត្តិ ក្នុងករណីមិនប្រតិបត្តិ ឬប្រតិបត្តិដែរតែមិនគ្រប់គ្រាន់ គឺភាគីម្ខាងទៀតនៃកិច្ចសន្យា មានសិទ្ធិអនុវត្តបង្ខំឱ្យប្រតិបត្តិ ឬអាចតម្រូវឱ្យមានការជួសជុលនូវសំណងរដ្ឋប្បវេណី។

### ● គូភាគីប្រតិបត្តិក្នុងនាមឪពុកគំរូ

ភាគីនៃកិច្ចសន្យាការងារត្រូវប្រតិបត្តិក្នុងនាមឪពុកគំរូ មានន័យថានៅក្នុងក្របខណ្ឌនៃកិច្ចសន្យាការងារ ភាគីនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដល់សហគ្រាស កម្មករនិយោជិតមានកាតព្វកិច្ចត្រូវធ្វើការដែលគេជួលឱ្យធ្វើ ហើយអនុវត្តការងារនោះដោយខ្លួនឯង និងដោយយកចិត្តទុកដាក់។

មានន័យថានិយោជិត ឬកម្មករនិយោជិតត្រូវគិតថាទោះបីជាសេវាការងារដែលខ្លួនបំពេញ គឺជាផលប្រយោជន៍របស់ភាគីនិយោជកក្នុងនាមនិយោជកក៏ដោយ ប៉ុន្តែខ្លួនត្រូវប្រតិបត្តិឱ្យបានល្អ និងចាត់ទុកដូចជាទ្រព្យ ឬប្រយោជន៍របស់ខ្លួនផ្ទាល់ ពីព្រោះទាំងនេះគឺជាកាតព្វកិច្ចស្របច្បាប់និងកំណត់ថាជាតាវកាលិក នៃកិច្ចសន្យាការងារដែលនិយោជិតត្រូវតែបំពេញដោយខានមិនបាន។ លើសពីនេះទៅទៀតក្នុងករណីធ្វេសប្រហែសដែលកើតចេញពីទង្វើ ឬសកម្មភាពណាមួយដែលបង្កឱ្យមានព្យសនកម្ម ភាគីនិយោជក មានសិទ្ធិទាមទារឱ្យមានការទទួលខុសត្រូវ។

បន្ថែមពីនេះទៀត ក្រៅពីម៉ោងធ្វើការកម្មករនិយោជិតទាំងនោះអាចធ្វើសកម្មភាពខាងវិជ្ជាជីវៈបាន ដែលមិនជាការប្រណាំងប្រជែងនឹងសហគ្រាសដែលខ្លួនបម្រើ ឬធ្វើឱ្យខូចដំណើរការដែលបានព្រមព្រៀងគ្នា និងលើកលែងក្នុងករណីមានការព្រមព្រៀងផ្ទុយពីនេះ។

អនុវត្តដូចគ្នាចំពោះភាគីនិយោជកដែលមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់កម្រៃ ផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗក្នុងការលើកទឹកចិត្តដែលជាថ្នូរទៅនឹងការផ្គត់ផ្គង់នូវសេវាការងាររបស់និយោជិត ឬកម្មករនិយោជិតដោយមិនកេងប្រវ័ញ្ចទៅលើកម្លាំង

ពលកម្មរបស់ភាគីកូនចៅ និងមិនអនុវត្តផ្ទុយទៅនឹងបទប្បញ្ញត្តិការងារខ្មែរ ចំពោះលក្ខខណ្ឌការងារដែលអនុវត្តនៅក្នុងគ្រឹះស្ថាន ឬសហគ្រាសរបស់ខ្លួន។

ការប្រតិបត្តិក្នុងនាមឪពុកគំរូនេះ គឺកើតចេញពីការសន្មត់របស់គូភាគី ជាវិធានដែលកើតចេញពីឆន្ទៈសេរីរបស់គូភាគី និងស្របទៅនឹងបញ្ញត្តិច្បាប់ការងារខ្មែរ។

## គូភាគីត្រូវប្រតិបត្តិដោយមិនអាចប្រកែកបាន

ករណីនេះយើងធ្វើការបកស្រាយតាមទ្រឹស្តីស្វ័យភាពនៃឆន្ទៈរបស់គូភាគីក្នុងការបង្កើតកិច្ចសន្យាការងារ គេស្វែងរកបាននូវឆន្ទៈព្រមព្រៀងមួយដោយពិតប្រាកដ ជាការស្រុះស្រួលគ្នាថានឹងទទួលយកនូវលក្ខខណ្ឌនៃកិច្ចសន្យាការងារ មានកាតព្វកិច្ចត្រូវតែប្រតិបត្តិដោយមិនអាចប្រកែកបាន។ ប៉ុន្តែ ស្ថានភាពនេះអាចប្រែប្រួលប្រសិនបើមានការព្រមព្រៀងផ្សេងពីនេះ ឬនៅក្នុងករណីខ្លះដែលច្បាប់បញ្ញត្តិថាភាគីមានសិទ្ធិកែប្រែកិច្ចសន្យាជាឯកតោភាគី និងមិនត្រូវការនូវឆន្ទៈព្រមព្រៀងជាឯកឆន្ទៈ។

## អានុភាពចំពោះតតិយជន

តតិយជន គឺជាជនទី៣ ចំពោះកិច្ចសន្យាត្រូវបានគេសន្មត់ថាមិនមែនជាភាគីនៃកិច្ចសន្យា ឬជាជននៅក្រៅកិច្ចសន្យា ជាបុគ្គលដែលមិនមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងកិច្ចសន្យា។ ដូចនេះតាមគោលការណ៍កិច្ចសន្យាដែលបញ្ញត្តិថាជាច្បាប់របស់គូភាគី គឺមិនមានអានុភាពចំពោះតតិយជន ដែលជាជនទីបីនៅក្រៅកិច្ចសន្យានោះទេ។

តើកិច្ចសន្យាការងារបង្កើតអានុភាពចំពោះតតិយជនបានយ៉ាងដូចម្តេចនៅក្នុងទំនាក់ទំនងការងារ? ទាំងនេះអាចកើតមានដោយសារឆន្ទៈសេរីរបស់គូភាគី ដែលសន្មត់ឱ្យជនទីបីមានសិទ្ធិពាក់ព័ន្ធទៅនឹងកិច្ចសន្យា ឬជនទីបីទទួលបានសិទ្ធិតាមបញ្ញាត្តិច្បាប់ក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍រួម ឬផលប្រយោជន៍បុគ្គលទូទៅនៅក្នុងសង្គម។



**ឧទាហរណ៍៖** កិច្ចសន្យាការងារដែលបញ្ជូនពលករទៅបម្រើការងារនៅបរទេសមួយ ដែលធ្វើឡើងដោយមានការទទួលដឹងឮពីក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (MTSOB) និងនិយោជកនៃក្រុមហ៊ុនបរទេស។ ក្នុងទំនាក់ទំនងខាងលើនេះគេសង្កេតឃើញថាអ្នកទទួលបានផលប្រយោជន៍ គឺនិយោជកនៃក្រុមហ៊ុនបរទេស និងពលករ ដែលត្រូវបានជ្រើសរើសឱ្យទៅបម្រើការងារនៅបរទេស ប៉ុន្តែផ្អែកតាមគោលការណ៍រដ្ឋធម្មនុញ្ញដែលបានចែងថា **រដ្ឋ** គឺជាអាណាព្យាបាលរបស់ប្រជាពលរដ្ឋ ដូចនេះជាកាតព្វកិច្ច និងក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍រួមផង ស្ថាប័នមានសមត្ថកិច្ចខាងលើនេះបានដើរតួនាទីជាអ្នកទទួលដឹងឮ និងមានសិទ្ធិចូលរួមអន្តរាគមន៍នៅក្នុងកិច្ចសន្យាការងារ។

ដូចនេះ គេអាចសន្និដ្ឋានបានថា: កិច្ចសន្យាគឺជាបាតុភូតសង្គម ដែលតាមរយៈកិច្ចសន្យានេះវាអាចនាំឱ្យមានការផ្លាស់ប្តូរស្ថានភាពគតិយុត្តណាមួយ ដែលតាមរយៈនេះច្បាប់អាចអនុញ្ញាតឱ្យតតិយជនមានសិទ្ធិជំទាស់ទៅនឹងកិច្ចសន្យាបានក្នុងករណីដែលមានការអនុវត្តកិច្ចសន្យាដោយមិនគោរពច្បាប់។

## អានុភាពចំពោះចៅក្រម



ក្នុងករណីមានវិវាទ រវាងគូភាគីនៃកិច្ចសន្យា ចៅក្រមគឺមានទំនាក់ទំនងទៅនឹងកិច្ចសន្យា ជាលទ្ធផលចៅក្រមមិនមានសិទ្ធិក្នុងការកែប្រែ ឬផ្លាស់ប្តូរនូវលក្ខខណ្ឌណាមួយនៃកិច្ចសន្យាទេពីព្រោះ កិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមព្រៀងពិតប្រាកដរបស់គូភាគី ប៉ុន្តែចៅក្រមមានសិទ្ធិក្នុងការបកស្រាយកិច្ចសន្យានោះ ដោយផ្អែកទៅតាមឆន្ទៈសេរីរបស់គូភាគី វិភាគពីតម្រូវការរបស់គូភាគីនៅពេលដែលបង្កើតកិច្ចសន្យានោះឡើង។

ហេតុដូច្នេះ ការកែប្រែកិច្ចសន្យាមិនអាចសម្រេចបានដោយចៅក្រមទេ លើកលែងតែការព្រមព្រៀងរបស់គូភាគីខុសច្បាប់ ឬជាការព្រមព្រៀងមួយដែលផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់ របៀបរៀបរយ ឬទំនៀមទម្លាប់ប្រពៃណីល្អ។

ជារួមអានុភាពនៃកិច្ចសន្យាការងារអាចអនុវត្តបាននៅពេលដែលកិច្ចសន្យាការងារនោះមានសុពលភាព មិនផ្ទុយទៅនឹងអត្ថន័យនៃច្បាប់ការងារខ្មែរ៕

**ចូលរួមគោរពច្បាប់ការងារទាំងអស់គ្នា ដើម្បី**
**នាពស្របច្បាប់ សុវត្ថិភាព ការងារល្អប្រសើរ វឌ្ឍនភាពការងារ និង**
**ការអភិវឌ្ឍសង្គម**





ព័ត៌មានទីផ្សារការងារ

# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ទិន្នន័យសំខាន់ៗស្តីពីអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ

អត្ថបទនេះមានបំណងបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងពេលបច្ចុប្បន្ន នៅក្នុងទីផ្សារការងារកម្ពុជាតាមរយៈទិន្នន័យស្ថិតិអ្នកចុះឈ្មោះស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារចាប់ពីខែមីនា ឆ្នាំ២០១០ ដល់ខែកុម្ភៈ ឆ្នាំ២០១២។ ទិន្នន័យទាំងអស់នោះរួមមាន អ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ៨.៦៩៥នាក់ (មិនរួមបញ្ចូលអ្នកស្វែងរកការងារធ្វើ ដែលបានប្រមូលនៅតាមមូលដ្ឋាន) និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤.៤៦២ នាក់។ ជាថ្មីម្តងទៀត ទ.ជ.ម.ក សូមបញ្ជាក់ថាទិន្នន័យដែលបាន និងកំពុងលើកយកមកបង្ហាញជូនក្នុងផ្នែកនេះ គឺមិនបានគ្របដណ្តប់លើទិន្នន័យសម្រាប់ប្រទេសកម្ពុជាទាំងមូលទេ ដូច្នេះរាល់ការប្រើប្រាស់ និងបកស្រាយទិន្នន័យទាំងនេះ សូមយកមកពិចារណានូវបញ្ហានេះផង។

### ១. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំនាត់ថ្នាក់មុខរបរ (ISCO) (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)

ដើម្បីធ្វើការបង្ហាញ អំពីស្ថានភាពទីផ្សារការងារមួយ យើងចាំបាច់ត្រូវតែធ្វើការពិចារណាទៅលើតម្រូវការ និងការផ្គត់ផ្គង់នៃកម្លាំងពលកម្មនៅក្នុងទីផ្សារនេះ។ ប៉ុន្តែ ការវិភាគអំពីកម្លាំងពលកម្មអាចធ្វើឡើងក្នុងទម្រង់ និងរូបភាពច្រើនសណ្ឋាន។ ក្នុងចំណុចនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) សូមលើកយកការប្រៀបធៀបរវាងចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ISCO) មកធ្វើការបង្ហាញជូន។ បើពិនិត្យមើលទៅលើក្រុមចំ-ណាត់ថ្នាក់មុខរបរធំបំផុត (Major Group) ដែលបានបង្ហាញជូនក្នុងរូបទី១ ឃើញថា ក្រុមដែលមានការផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេ គឺក្រុមអ្នកជំនាញឯកទេសវិជ្ជាជីវៈ ដែលមានអត្រារហូតដល់៣១,៧% នៃចំនួនអ្នកស្វែងរកការងារធ្វើសរុប ដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ។ ចំណែក តម្រូវការកម្លាំងពលកម្មសម្រាប់ក្រុមជំនាញដូចគ្នានេះ គឺមានត្រឹមតែ១៧,១% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើផ្នែកតម្រូវការកម្លាំងពលកម្មវិញ ឃើញថា ក្រុមដែលមានតម្រូវការខ្ពស់ជាងគេ គឺកម្មករជំនាញផ្នែក សិប្បកម្ម និងកិច្ច-ការជំនួញផ្សេងៗ ដែលមានអត្រារហូតដល់២៨,៦% នៃតម្រូវការកម្លាំងពលកម្មសរុប ដែលបានប្រមូលដោយ ទ.ជ.ម.ក រីឯការផ្គត់ផ្គង់សម្រាប់ក្រុមចំណាត់ថ្នាក់មុខរបរដូចគ្នានេះមានត្រឹមតែ១១,៧% ប៉ុណ្ណោះ។

តទៅទំព័របន្ទាប់

### រូបទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤.៤៦២នាក់

## ២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)

បើពិនិត្យមើលទៅលើចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកទៅតាមវិស័យធំៗទាំងបីនៃសកម្មភាពសេដ្ឋកិច្ច យើងចាប់អារម្មណ៍ឃើញថា ទាំងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម គឺបានប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម និងតាមពីក្រោយរៀងគ្នាដោយវិស័យឧស្សាហកម្ម និងកសិកម្មៗ ក្នុងនោះ យើងសង្កេតឃើញថា នៅក្នុងវិស័យសេវាកម្ម ចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម)មានអត្រា៧៧,០% ខ្ពស់ជាងព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)ដែលមានអត្រា៦២,៦% ប៉ុណ្ណោះៗ ចំណែកឯ វិស័យឧស្សាហកម្មវិញ ឃើញថាព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) មានអត្រាប្រហែល ៣៦,៧% ចំណែកឯ ចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) ក្នុងវិស័យនេះមានអត្រាត្រឹមតែ២១,១%ប៉ុណ្ណោះៗ

### រូបទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមវិស័យសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០-ខែកុម្ភៈ ឆ្នាំ២០១២)

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤.៤៦២នាក់



តារាងទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)

| | ចំណាត់ថ្នាក់នៃសហគ្រាស | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| A | កសិកម្ម និងរុក្ខាប្រមាញ់ | 168 | 1.9 | 393 | 0.7 |
| B | រ៉ែ និងថ្ម | 10 | 0.1 | 9 | 0.0 |
| C | កម្មន្តសាល | 1056 | 12.1 | 18631 | 34.2 |
| D | អគ្គិសនី ឧស្ម័ន ចំហាយ និងផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | 498 | 5.7 | 576 | 1.1 |
| E | ផ្គត់ផ្គង់ទឹក លូទឹក គ្រប់គ្រងសំរាម និងសកម្មភាពផ្សេងៗ | 32 | 0.4 | 16 | 0.0 |
| F | សំណង់ | 237 | 2.7 | 769 | 1.4 |
| G | លក់ដុំ និងរាយ | 868 | 10.0 | 4736 | 8.7 |
| H | ដឹកជញ្ជូន ស្តុក និងឃ្លាំង | 91 | 1.1 | 231 | 0.4 |
| I | សណ្ឋាគារ ការស្នាក់អាស្រ័យ អាហារ ភេសជ្ជៈ និងសេវាផ្សេងៗ | 692 | 8.0 | 5432 | 10.0 |
| J | ព័ត៌មាន និងទូរគមនាគមន៍ | 659 | 7.6 | 1769 | 3.2 |
| K | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 1755 | 20.2 | 1735 | 3.2 |
| L | អចលនទ្រព្យ | 20 | 0.2 | 153 | 0.3 |
| M | វិជ្ជាជីវៈ បច្ចេកទេស និងវិទ្យាសាស្ត្រ | 656 | 7.5 | 980 | 1.8 |
| N | រដ្ឋបាល និងសេវាគាំទ្រ | 325 | 3.7 | 1646 | 3.0 |
| O | រដ្ឋបាលសាធារណៈ និងការពារ | 150 | 1.7 | 189 | 0.3 |
| P | អប់រំ | 530 | 6.1 | 6721 | 12.3 |
| Q | សុខភាព និងសេវាសង្គម | 139 | 1.6 | 2530 | 4.6 |
| R | សិល្បៈ ការកំសាន្ត និងការច្នៃប្រឌិត | 36 | 0.4 | 953 | 1.7 |
| S | សេវាផ្សេងៗ | 637 | 7.3 | 6281 | 11.5 |
| T | សកម្មភាពជានិយោជកនៅក្នុងផ្ទះដោយប្រកបអាជីវកម្ម ឬសេវាផ្សេងៗ | 14 | 0.2 | 63 | 0.1 |
| U | សកម្មភាពរបស់ស្ថានទូត កុងស៊ុល និងអង្គការអន្តរជាតិ | 120 | 1.4 | 650 | 1.2 |
| | សរុប | 8695 | 100.0 | 54462 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤.៤៦២នាក់

ព័ត៌មានទីផ្សារការងារជាចំណែកកោសិកានៃការអភិវឌ្ឍ!

## ៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំ (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)

ដោយផ្អែកលើទិន្នន័យ នៃចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយបែងចែកតាមកម្រិតអប់រំ (រូបទី៣ និងតារាងទី២) ឃើញថា អ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មួយភាគធំប្រមាណជា ៦៤,៣% កាន់សញ្ញាបត្របរិញ្ញាបត្រ ចំណែកឯព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) កម្រិតបរិញ្ញាបត្រវិញមានត្រឹមតែ២០,២% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) វិញ ឃើញថាតម្រូវការកម្លាំងពលកម្មមួយភាគធំមិនតម្រូវឱ្យបញ្ចប់ថ្នាក់សិក្សាណាមួយឡើយ ដែលមានអត្រារហូតដល់ ៥២,៤% ដែលជាអត្រាមួយខ្ពស់ខ្លាំង បើប្រៀបធៀបជាមួយនឹងចំនួនអ្នកស្វែងរកការងារធ្វើ ដែលមានកម្រិតអប់រំដូចគ្នានេះ។

**រូបទី៣ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតអប់រំ (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)**




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៥.៨៦២នាក់

តារាងទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំ (ខែមីនា ឆ្នាំ២០១០ - ខែកុម្ភៈ ឆ្នាំ២០១២)

| ល.រ | ប្រភេទកម្រិតសិក្សា | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| ១ | មិនធ្លាប់បានសិក្សាឬបញ្ចប់ថ្នាក់ណាមួយឡើយ | 889 | 10.2 | 28511 | 52.4 |
| ២ | បឋម | 139 | 1.6 | 639 | 1.2 |
| ៣ | អនុវិទ្យាល័យ | 310 | 3.6 | 2788 | 5.1 |
| ៤ | វិទ្យាល័យ | 410 | 4.7 | 2873 | 5.3 |
| ៥ | សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) | 555 | 6.4 | 5586 | 10.3 |
| ៦ | សញ្ញាប័ត្រវិជ្ជាជីវៈរយៈពេលវគ្គខ្លី | 48 | 0.6 | 273 | 0.5 |
| ៧ | សញ្ញាប័ត្របណ្ដុះបណ្ដាលវិជ្ជាជីវៈកម្រិត I | 6 | 0.1 | 13 | 0.0 |
| ៨ | សញ្ញាប័ត្របណ្ដុះបណ្ដាលវិជ្ជាជីវៈកម្រិត II | 7 | 0.1 | 0 | 0.0 |
| ៩ | សញ្ញាប័ត្របណ្ដុះបណ្ដាលវិជ្ជាជីវៈកម្រិត III | 20 | 0.2 | 11 | 0.0 |
| ១០ | សញ្ញាប័ត្របច្ចេកទេស | 118 | 1.4 | 357 | 0.7 |
| ១១ | បរិញ្ញាប័ត្ររង | 468 | 5.4 | 750 | 1.4 |
| ១២ | បរិញ្ញាប័ត្រ | 5591 | 64.3 | 11000 | 20.2 |
| ១៣ | អនុបណ្ឌិត | 103 | 1.2 | 418 | 0.8 |
| ១៤ | បណ្ឌិត | 2 | 0.0 | 623 | 1.1 |
| ១៥ | សញ្ញាប័ត្របញ្ចាក់វិជ្ជាជីវៈ/អាជ្ញាបណ្ណ/កម្រិត | 29 | 0.3 | 620 | 1.1 |
| | សរុប | 8695 | 100.0 | 54462 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ៨.៦៩៥នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ៥៤.៤៦២នាក់

*អត្ថបទស្តីពី ព័ត៌មានទីផ្សារការងារនៅកម្ពុជា រៀបចំ និងបកស្រាយពន្យល់ដោយលោក **តាំង ប៉ាងថារិទ្ធ** (ទីប្រឹក្សា ទីភ្នាក់ងារជាតិមុខរបរ និងការងារ) យោងតាម មូលដ្ឋានទិន្នន័យដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ។*



ព័ត៌មានជ្រើសរើសបុគ្គលិក

# ព័ត៌មានជ្រើសរើសបុគ្គលិក

## VACANCY ANNOUNCEMENT

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ «**មជ្ឈមណ្ឌលការងារ**» ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះ

### សណ្ឋាគារ Kabiki

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. Receptionist (ចំនួន២នាក់)

២. Maintenance (ចំនួន១នាក់)

**ទំនាក់ទំនងតាមរយៈ:**

☎ ០១២ ៦៧៩ ៦៩១ ឬ ០២៣ ២២២ ២៩០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

### ហាងសិរីយ៉ាម៉ាស្សា និងស្បា

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. មេការ

២. នារីម៉ាស្សាមុខ កាត់ក្រចក សំអាតត្រចៀក

**ទំនាក់ទំនងតាមរយៈ:**

☎ ០១២ ៩៩២ ៤៣៣ ឬ ០១១ ៩៩២ ៤៣៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

ដើម្បីទទួលបានសេវាការងារដោយ «ឥតគិតថ្លៃ» សូមទំនាក់ទំនង ឬធ្វើដំណើរមកកាន់៖

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**
វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា
ខណ្ឌសែនសុខ រាជធានីភ្នំពេញ
០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥
jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង
ផ្លូវលេខ១ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
០៥៣ ៩៥៣ ៥៨០
០១៦ ៩២៦ ៦៥៥
jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តសៀមរាប សង្កាត់ស្លក្រាម
ក្រុងសៀមរាប
០៦៣ ៩៦៩ ៣៩៦
០១៦ ៥៣៦ ៦៥៥
jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត
ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត
០៣៣ ៩៣២ ១២២
០១៦ ៥០៦ ៦៥៥
jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តស្វាយរៀង ភូមិមេភ្លើង
សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង
០៤៤ ៩៤៥ ២៧៥
០១៦ ៦៤៦ ៦៥៥
jc_svayrieng@nea.gov.kh

ឥឡូវនេះ អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយ «ឥតគិតថ្លៃ» មកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ហាង ឡាវ៉ែន

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់សំលៀកបំពាក់ក្នុងហាង
២. ជាងដេរ (ភេទស្រី)

**លក្ខខណ្ឌជ្រើសរើស:**

- មានរូបសម្បត្តិសមរម្យ រួសរាយរាក់ទាក់
- ត្រូវមានបទពិសោធន៍ការងារចាប់ពី១ឆ្នាំឡើងទៅ(តំណែងទី១)
- ត្រូវមានបទពិសោធន៍ច្នៃម៉ូដ និងកាត់ដេរសំលៀកបំពាក់នារី ចាប់ពី២ឆ្នាំឡើងទៅ (តំណែងទី២)

**ទំនាក់ទំនងតាមរយៈ:**

☎ ០២៣ ២១២ ៦២១ ឬ ០៧៧ ៧៧៧ ៥១០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## រ៉ូ ភូ ភូ ម៉ាស្សា

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកមេជាង
២. ផ្នែកសាឡន

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ការងារ

**ទំនាក់ទំនងតាមរយៈ:**

☎ ០៩២ ៦៧៤ ៩០៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ស៊ុន ហ៊ួរ

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកទីផ្សារ (ចំនួន៣នាក់)
២. ផ្នែកលក់ (ចំនួន២នាក់)
៣. អ្នកកាន់ស្តុក

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានសញ្ញាបត្រដែលពាក់ព័ន្ធតាមជំនាញ
- ត្រូវចេះភាសាអង់គ្លេស និងចេះប្រើប្រាស់កុំព្យូទ័រ Word, Excel, និងInternet
- មានរូបសម្បត្តិសមរម្យ រួសរាយរាក់ទាក់ និងមានភាពស្មោះត្រង់ចំពោះក្រុមហ៊ុន
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច៣ឆ្នាំ

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៤២៧Eo ផ្លូវ៩៣ (ព្រះមុន្នីវង្ស) សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

☎ ០១៦ ៩៩២ ៣៧២

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន Mitchell Lucky

**ថ្ងៃផុតកំណត់:** ០៦-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ (ភេទប្រុស)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍លក់ផលិតផលថែរក្សាសក់

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៩A ផ្លូវលេខ១៣៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

☎ ០១១ ៦៧៨ ៤២៦ ឬ ០១៦ ៦៧៨ ៤២៦

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

តទៅទំព័របន្ទាប់

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងខែមេសា ឆ្នាំ២០១២

## ក្រុមហ៊ុន ខេមបូអេតទើថាយស៊ីង

ថ្ងៃផុតកំណត់: ០៦-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. អ្នកបើកបររថយន្ត
២. ជាងផ្សារដែក
៣. បុគ្គលិក និងកម្មករឃ្លាំង
ទំនាក់ទំនងតាមរយៈ:
☎ ០១៦ ៧៨៧ ៩១៤
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន SL

ថ្ងៃផុតកំណត់: ០៦-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. បុគ្គលិកផ្នែកជាងម៉ាស៊ីនភ្លើង និងជាងភ្លើង (ភេទប្រុស)
២. ផ្នែកលក់ (ភេទប្រុស)
លក្ខខណ្ឌជ្រើសរើស:
- ត្រូវមានអាយុចាប់ពី២០ ដល់ ៣០ឆ្នាំ
- ធ្លាប់រៀនជំនាញដែលពាក់ព័ន្ធ
- បទពិសោធន៍លើផ្នែកជាងម៉ាស៊ីន ឬជាងភ្លើង
- អាចអាន សរសេរអក្សរខ្មែរបាន
- ឧស្សាហ៍ព្យាយាម និងមានបំណងរៀនបន្ថែមអំពីម៉ាស៊ីន
- ចេះភាសាខ្មែរ ឬអង់គ្លេស
- ត្រូវមានបទពិសោធន៍ផ្នែកលក់
- ត្រូវមានសញ្ញាបត្រខាងគ្រឿងម៉ាស៊ីន (តំណែងទី១)

ទំនាក់ទំនងតាមរយៈ:
ផ្ទះលេខ៦១៥ ផ្លូវលេខ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
☎ ០១២ ៣៩៩ ៨៦៦ ឬ ០៧០ ៦៦៦ ២៨៨
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## HIGHTECH Office Automation

ថ្ងៃផុតកំណត់: ០៦-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ និងខេត្ត
មុខតំណែង:
១. ផ្នែកលក់
២. ផ្នែកការិយាល័យ និងកាន់បញ្ជីគណនេយ្យ
៣. អ្នកកាន់ស្តុក
លក្ខខណ្ឌជ្រើសរើស:
- ត្រូវចេះភាសាអង់គ្លេសច្បាស់លាស់
- ផ្តល់អាទិភាពចំពោះអ្នកចេះភាសាចិន និងវៀតណាម

ទំនាក់ទំនងតាមរយៈ:
ផ្ទះលេខ៤៩៨ ផ្លូវលេខ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
☎ ០២៣ ២២៣ ២៩៨
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ប៊ូរីម៉េង លី

ថ្ងៃផុតកំណត់: ០៦-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. វិស្វករសំណង់
២. ស្ថាបត្យករ
៣. វាស់វែង
៤. ផ្នែកលក់ផ្ទះ
៥. គណនេយ្យ និងគណនេយ្យឃ្លាំង
លក្ខខណ្ឌជ្រើសរើស:
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច១ឆ្នាំឡើងទៅ

ទំនាក់ទំនងតាមរយៈ:
ផ្លូវវែងស្រេង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
☎ ០១២ ៣២៦ ៧៤៩ ឬ ០៧៧ ២៩៧ ៨៨៨
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុន ហ៊ួត ជា

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១. ប្រធានផ្នែកទីផ្សារ (ចំនួន១នាក់)
២. ផ្នែកទីផ្សារ (ភេទស្រី) (ចំនួន២នាក់)
៣. ប្រធានគណនេយ្យ (ចំនួន១នាក់)
៤. អ្នកកាន់ស្តុក (ចំនួន១នាក់)

លក្ខខណ្ឌជ្រើសរើស:

- មានបទពិសោធន៍តាមតួនាទី យ៉ាងតិច១ឆ្នាំ
- មានចំណេះដឹងផ្នែកទីផ្សារ សំភារៈសំណង់
- មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន
- មានការទំនាក់ទំនងល្អជាមួយអតិថិជន

ទំនាក់ទំនងតាមរយៈ:

ក្បាលទំនប់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

០១២ ៧៧៨ ៤៨៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ភោជនីយដ្ឋាន សាម៉ូ សាម៉ូ

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១. ផ្នែកបេឡា
២. អ្នករត់តុ
៣. ផ្នែកជំនួយការចុងភៅ
៤. ផ្នែកអនាម័យ

ទំនាក់ទំនងតាមរយៈ:

០១៦ ៥៦៨ ០២០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ហាងបុស្សា ម៉ាស្សា

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១. នារីម៉ាស្សា

ទំនាក់ទំនងតាមរយៈ:

ផ្ទះលេខ១១២ ផ្លូវលេខ១៧៣ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ

០៧៧ ៧៥៧ ៣០០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន JOA

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១. អ្នកបើកបររថយន្តតូច-ធំ (ចំនួន២៥នាក់)
២. អ្នករត់តុ អ្នកអ៊ុជរ៍ អ្នកអនាម័យ (ចំនួន៣នាក់)
៣. អ្នកថៃសួន (ចំនួន៣នាក់)
៤. អ្នកទទួលភ្ញៀវ និងសន្តិសុខ (ចំនួន៣០នាក់)

ទំនាក់ទំនងតាមរយៈ:

០៩២ ៥១៦ ១៦៤ ឬ ០៩៣ ៤៦២ ៦៥៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ឈិន ឡុង លក់ម៉ាស៊ីនត្រជាក់

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២

ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ

មុខតំណែង:

១. ជាងម៉ាស៊ីនត្រជាក់
២. កូនជាងម៉ាស៊ីនត្រជាក់

លក្ខខណ្ឌជ្រើសរើស:

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងខែមេសា ឆ្នាំ២០១២

- ត្រូវមានជំនាញ និងបទពិសោធន៍ច្បាស់លាស់

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២០៤ BEo ផ្លូវម៉ៅសេទុង រាជធានីភ្នំពេញ

០១២ ៨៧៣ ៣៨៨ ឬ ០១៥ ៨៧៣ ៣៨៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន DDE Co., Ltd

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ និងទីផ្សារ ( ភេទស្រី ) (ចំនួន២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍
- មានសញ្ញាបត្រផ្នែកទីផ្សារ

**ទំនាក់ទំនងតាមរយៈ:**

អាគារ BS ជាន់ទី១

០១២ ៦០០ ០៧៤ ឬ ០៨១ ៦០០ ០៧៤

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ភោជនីយដ្ឋាន សាលីដេមបូ

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. Cashier

២. អ្នករត់តុ

៣. អ្នកអ៊ុជរ

៤. អ្នកយាមម៉ូតូ

៥. អ្នកអនាម័យ និងអ្នករៀបចំបន្លែ

៦. ចុងភៅសាច់អាំង និងគ្រឿងក្លែម

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ការងារ

**ទំនាក់ទំនងតាមរយៈ:**

នៅផ្សាររាត្រីកោះពេជ្រទល់មុខអាគារG

០១២ ៦០៣ ៧០៣ ឬ ០៩៧ ៧ ៦០៣ ៧០៣

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## តុលឡាយ លក់ម៉ាស៊ីនត្រជាក់

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. មេជាងម៉ាស៊ីនត្រជាក់ (ចំនួន៤នាក់)

២. កូនជាងម៉ាស៊ីនត្រជាក់ (ចំនួន៨នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍យ៉ាងតិច២ឆ្នាំ
- មានអាយុចាប់ពី២៥ឆ្នាំឡើងទៅ
- មានភាពអត់ធ្មត់ក្នុងការងារ និងស្មោះត្រង់

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១៥២AB ផ្លូវ១៤៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

០១២/០៩៨/០១៥ ៥៨៩ ១១១

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន មេគង្គសេវាសន្តិសុខ

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកសន្តិសុខ (ចំនួន១០០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានអាយុចាប់ពី១៨ ដល់ ៤០ឆ្នាំ

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៦០D ផ្លូវហាណូយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

០១២ ៨០៨ ០៤៥ ឬ ០៨៨ ៥៣៩ ៩៩ ៩៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»


តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុន Top One Dental Supply Co., Ltd

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែក Account (ភេទស្រី) (ចំនួន២នាក់)
២. ផ្នែក Marketing (ភេទស្រី) (ចំនួន២នាក់)
៣. ផ្នែក Sale (ភេទប្រុស) (ចំនួន២នាក់)
៤. ផ្នែក Customer Service (ភេទស្រី) (ចំនួន២នាក់)
៥. អ្នកបើកឡាន (ចំនួន២នាក់)
៦. ផ្នែក Delivery (ចំនួន៣នាក់)
៧. ផ្នែក Electronic (ចំនួន២នាក់)
៨. ផ្នែកជាងផលិតគ្រាប់ធ្មេញសិប្បនិមិត្ត (ចំនួន៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ការងារចាប់ពី១ឆ្នាំឡើងទៅ

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៧៤E២ ផ្លូវ១១៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

☎ ០៨៩ ២៦៦ ៦៨៩ ឬ ០២៣ ៦៤១ ៩១ ១១

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន អង្គរទិព្វគ្រុប

**ថ្ងៃផុតកំណត់:** ០៧-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ (ចំនួន៧នាក់)
២. ផ្នែកគណនេយ្យ (ភេទស្រី) (ចំនួន២នាក់)
៣. ផ្នែករចនាម៉ូត (ចំនួន២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- កំរិតវប្បធម៌យ៉ាងតិចថ្នាក់ទី៩
- មានអត្តចរិតល្អ រូបសម្បត្តិសមរម្យ អំណត់ព្យាយាម និងស្មោះត្រង់ក្នុងការងារ
- មានអាយុចាប់ពី១៨ ដល់ ២៥ឆ្នាំ (តំណែងទី១ និងទី៣)
- ត្រូវមានចំណេះដឹងផ្នែកគណនេយ្យ និងចេះកុំព្យូទ័រ (Ms. Word, Excel)
- មានបរិញ្ញាបត្រផ្នែកគណនេយ្យ ឬ មានបទពិសោធន៍ក្នុងការងារផ្នែកគណនេយ្យកាន់តែប្រសើរ
- មានអាយុចាប់ពី២៣ ដល់ ២៨ឆ្នាំ (តំណែងទី២)
- ត្រូវមានសមត្ថភាពច្បាស់លាស់ក្នុងកម្មវិធី CorelDraw, Photo Shop, AutoCAD
- មានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការងាររចនាម៉ូត
- មានបទពិសោធន៍ក្នុងការងាររចនាម៉ូតកាន់តែប្រសើរ
- មានអត្តចរិតល្អ រូបសម្បត្តិសមរម្យ អំណត់ព្យាយាម និងស្មោះត្រង់ក្នុងការងារ

**ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៥១-៥៣Eo ផ្លូវ១៣៦ ខាងកើតផ្សារធំថ្មី

☎ ០២៣ ៧២២ ៨៤៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ថេង សេងហេង

**ថ្ងៃផុតកំណត់:** ១២-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកទីផ្សារ (ចំនួន៣នាក់)
២. ផ្នែកជំនួយការឃ្លាំង (ចំនួន២នាក់)
៣. ផ្នែកកម្មករឃ្លាំង (ចំនួន១០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- កម្រិតអប់រំទាបបំផុតត្រឹមបរិញ្ញាបត្រ
- មានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំ(តំណែងទី១)
- ត្រូវមានអាណាព្យាបាល ឬអ្នកធានាច្បាស់លាស់
- មានភាពឧស្សាហ៍ព្យាយាម ស្មោះត្រង់(តំណែងទី២,៣)

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៦-២៨-៣០ ផ្លូវលេខ២៥៣កែង១៦០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០២៣ ៨៨១ ៦៦៨ ឬ ០២៣ ៦៣៥ ៥៨ ៨២

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

តទៅទំព័របន្ទាប់

ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងខែមេសា ឆ្នាំ២០១២

## ក្រុមហ៊ុន Sokimex

ថ្ងៃផុតកំណត់: ០៧-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. លេខាធិការប្រតិបត្តិ (ចំនួន១នាក់)
២. ផ្នែកទីផ្សារ (ចំនួន៥នាក់)
លក្ខខណ្ឌជ្រើសរើស:
- សញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកច្បាប់/ រដ្ឋបាល
- មានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំ
- មានចំណេះដឹងផ្នែកគ្រប់គ្រង និងត្រួតពិនិត្យឯកសារចេញ-ចូល និងតាមដានផែនការ
- មានចំណេះដឹងផ្នែកពាណិជ្ជកម្ម- កិច្ចការរដ្ឋបាល
- ចេះនិយាយ សរសេរភាសាខ្មែរ-អង់គ្លេស ស្ទាត់ជំនាញ និងចេះ (Ms. Word, Excel, E-mail) (តំណែងទី១)
- កម្រិតសញ្ញាបត្របរិញ្ញាបត្រផ្នែកទីផ្សារ
- មានបទពិសោធន៍ផ្នែកទីផ្សារយ៉ាងតិច១ឆ្នាំ
- មានភាពស្មោះត្រង់ យកចិត្តទុកដាក់ក្នុងការងារ មានទំនាក់ទំនងល្អ និងមានទំនួលខុសត្រូវ
- ចេះនិយាយ សរសេរភាសាខ្មែរ-អង់គ្លេស ស្ទាត់ជំនាញ និងចេះ (Ms. Word, Excel, E-mail) (តំណែងទី២)

ទំនាក់ទំនងតាមរយៈ:
វិឡាលេខ២២ វិថីក្រមួនស សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
☎ ០២៣ ៦៧២ ៤១ ៣៤
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ខុឌ្ឌិស័ក

ថ្ងៃផុតកំណត់: ១២-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. បុគ្គលិកផ្នែកថែរក្សាសម្ផស្ស (ភេទស្រី) (ចំនួន២០នាក់)
លក្ខខណ្ឌជ្រើសរើស:
• ត្រូវមានរូបសម្បត្តិសមរម្យ ស្រស់ស្អាត សម្បុរស
• មានអាយុចាប់ពី១៨ដល់៣០ឆ្នាំ
• អាចនិយាយភាសាថៃ នឹងមានអាទិភាព

ទំនាក់ទំនងតាមរយៈ:
ផ្ទះលេខ១១៦ABC ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
☎ ០២៣ ២២០ ៤៤៤ ឬ ០៨៥ ៩៩៩ ១៥៨ ឬ ០៩៧ ៩៧៦ ៥៨ ១៦ ឬ ០១៦ ៩៦៨ ៨៨១
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## ក្រុមហ៊ុន ទីទ ស្តារ

ថ្ងៃផុតកំណត់: ១២-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. ផ្នែកគណនេយ្យ (ចំនួន២នាក់)
២. ជំនួយការផ្នែកស្ថិតិ (ចំនួន២នាក់)
លក្ខខណ្ឌជ្រើសរើស:
- បេក្ខជនត្រូវចេះភាសាចិន
សូមទំនាក់ទំនងតាមរយៈ:
☎ ០១១ ៦៤៥ ៨៥២
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

## ក្រុមហ៊ុនសំណង់ Green Eco

ថ្ងៃផុតកំណត់: ១២-មេសា-២០១២
ទីកន្លែងធ្វើការ: រាជធានីភ្នំពេញ
មុខតំណែង:
១. ជាងសំណង់ និងកម្មករ
សូមទំនាក់ទំនងតាមរយៈ:
☎ ០១២ ៣៨៣ ១២៨
«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក.»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ភ្លឹប BOOM

**ថ្ងៃផុតកំណត់:** ១២-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែក Order (ចំនួន៨នាក់)
២. ផ្នែក Service (ចំនួន៨នាក់)
៣. ផ្នែក Cashier (ចំនួន២នាក់)
៤. ផ្នែក Bartender (ចំនួន៤នាក់)
៥. ផ្នែក Cleaner (ចំនួន៦នាក់)
៦. ផ្នែក Cook (ចំនួន១នាក់)

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៨Eo ផ្លូវ២៥២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
០១២ ៨០២ ៩៦៦ ឬ ០២៣ ៥៥៥ ១៧ ៥៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន M-Ly ផលិតស័ក្ខសី

**ថ្ងៃផុតកំណត់:** ១២-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកទីផ្សារ (ភេទស្រី) (ចំនួន១០នាក់)
២. ផ្នែកកូនជាង (ចំនួន១០នាក់)

**លក្ខខណ្ឌជ្រើសរើស**

- ត្រូវមានអាយុចាប់ពី៣០ឆ្នាំឡើងទៅ

**សូមទំនាក់ទំនងតាមរយៈ:**

ឃ្លាំងលេខ១០ ផ្លូវលេខ២៦៥ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
០២៣ ៦៣៣ ៣៣ ៣៦ ឬ ០១១ ៦៩៣ ៥៦៩

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន សូគីម៉ិច

**ថ្ងៃផុតកំណត់:** ១២-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. លេខាធិការប្រតិបត្តិ (ចំនួន១នាក់)
២. ផ្នែកទីផ្សារ (ចំនួន៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- សញ្ញាបត្រអនុបណ្ឌិតផ្នែកច្បាប់ ឬរដ្ឋបាល
- មានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំ
- មានចំណេះដឹងផ្នែកគ្រប់គ្រង និងត្រួតពិនិត្យឯកសារចេញ-ចូល និងតាមដានផែនការ
- មានចំណេះដឹងគ្រប់គ្រងពាណិជ្ជកម្ម-កិច្ចការរដ្ឋបាល
- ចេះនិយាយ និងសរសេរភាសាខ្មែរ-អង់គ្លេសស្ទាត់ជំនាញ និងចេះ Word, Excel and E-mail (តំណែងទី១)
- បរិញ្ញាបត្រផ្នែកទីផ្សារ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ផ្នែកទីផ្សារយ៉ាងតិច១ឆ្នាំ
- មានភាពស្មោះត្រង់ យកចិត្តទុកដាក់ក្នុងការងារ មានទំនាក់ទំនងល្អ និងមានទំនួលខុសត្រូវ
- ចេះនិយាយ និងសរសេរភាសាខ្មែរ-អង់គ្លេសស្ទាត់ជំនាញ និងចេះ Word, Excel and E-mail (តំណែងទី២)

**ទំនាក់ទំនងតាមរយៈ:**

វីឡាលេខ២២ វិថីក្រមួនស សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
០២៣ ៦៧២ ៤១ ៣៤

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន អ៊ី ប៊ី ស៊ី ខូអិលធីឌី

**ថ្ងៃផុតកំណត់:** ២២-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកទីផ្សារ

តទៅទំព័របន្ទាប់

## ព័ត៌មានជ្រើសរើសបុគ្គលិកទាំងអស់នេះមានសុពលភាពនៅក្នុងខែមេសា ឆ្នាំ២០១២

☑ **លក្ខខណ្ឌជ្រើសរើស:**

- មានភាពស្មោះត្រង់ ស្លូតបូត តស៊ូ ឧស្សាហ៍ព្យាយាមក្នុងការងារ
- រូបសម្បត្តិសមរម្យ រួសរាយរាក់ទាក់ មានជំនាញទីផ្សារកាន់តែប្រសើរ
- នៅលីវ អាយុចាប់ពី១៨ ដល់ ៣០ឆ្នាំ
- ចេះអាន ចេះសរសេរភាសាខ្មែរច្បាស់លាស់ ចេះភាសាបរទេសកាន់តែប្រសើរ

✉ **សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៦៦ ផ្លូវលេខ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០៨៨ ៨៩៦ ៤៣ ០៦ ឬ ០១២ ៩៦៤ ៣០៦

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ជេ មេឌី

**ថ្ងៃផុតកំណត់:** ១៩-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកផ្សព្វផ្សាយលក់

☑ **លក្ខខណ្ឌជ្រើសរើស:**

- ឧស្សាហ៍ព្យាយាម និងតស៊ូក្នុងការងារ
- បើមានបទពិសោធន៍ការងារកាន់តែប្រសើរ
- មានរូបសម្បត្តិសមរម្យ និងមានភាពស្មោះត្រង់
- មានទំនាក់ទំនងល្អជាមួយអតិថិជន
- មានអាយុចាប់ពី២០ ដល់ ៣០ឆ្នាំ

✉ **សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១០ ផ្លូវលេខ១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ទល់មុខទូរទស្សន៍អាស៊ីអាគ្នេយ៍)

☎ ០១២ ៤០៨ ៨៦៧ ឬ ០១៥ ៥៤០ ១៦០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## គីរីរម្យ ខារ៉ាអូខេ

**ថ្ងៃផុតកំណត់:** ១៣-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. ផ្នែកគ្រប់គ្រង

២. ផ្នែកកាន់បន្ទប់

៣. ផ្នែកអូតេស

៤. ផ្នែក Cashier

☑ **លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ការងារ
- មានរូបសម្បត្តិសមរម្យ
- មានអាយុចាប់ពី១៨ដល់២៧ឆ្នាំ

✉ **សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៥៨ មហាវិថីព្រះសីហនុ (អតីតរោងកុនគីរីរម្យ)

☎ ០១១ ៨០៩ ៦៧៨ ឬ ០៨១ ៨០៩ ៦៧៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## គ្លីនិក និងសម្ភព បឹងសាឡាង

**ថ្ងៃផុតកំណត់:** ១៣-មេសា-២០១២

**ទីកន្លែងធ្វើការ:** រាជធានីភ្នំពេញ

**មុខតំណែង:**

១. គិលានុបដ្ឋាក, គិលានុបដ្ឋាយិកា

២. គណនេយ្យ

៣. អ្នកអនាម័យ

✉ **ទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ៤៣BC ផ្លូវ២៧១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០១២ ៦៧២ ០០៧ ឬ ០៧៧ ៩៧៥ ៨៦៨

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៩៣/១២ ក.ប/អ.ជ.ណ

## សេចក្តីជូនដំណឹង

### ស្តីពីវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមគម្រោង "មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជនឱ្យបានជ្រាបថា រាជរដ្ឋាភិបាលបានអនុញ្ញាតបន្ត **មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈរយៈពេល ៣ឆ្នាំ ពីឆ្នាំ២០១១-២០១៣ ជូនដល់កម្មករ កម្មការិនី និងយុវជន យុវនារី ដែលបាត់បង់ និងគ្មានការងារធ្វើនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ សៀមរាប និងខេត្តមួយចំនួនទៀតដែលមាន ឬអាចមានតំបន់សេដ្ឋកិច្ចពិសេសដូចជាខេត្តស្វាយរៀង តាកែវ កោះកុង បន្ទាយមានជ័យ និងខេត្តកំពង់ចាម។ នៅក្នុងឆ្នាំ២០១២នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបើកវគ្គបណ្តុះបណ្តាលជូនដល់ក្រុមគោលដៅខាងលើ នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈស្ថិតក្រោមឱវាទក្រសួងផ្ទាល់តាមបណ្តារាជធានី-ខេត្តដូចដែលបានរៀបរាប់ខាងលើ។ ក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាលនេះសិក្ខាកាមនឹងទទួលបានអាហារូបករណ៍ និងប្រាក់ឧបត្ថម្ភជាថវិកាចំនួន ៤.០០០រៀល ក្នុង ១ថ្ងៃសម្រាប់ការហូបចុក និងចំនួន ៤០.០០០រៀល ក្នុង ១ខែ សម្រាប់ការស្នាក់នៅ (បញ្ជាក់៖ សិក្ខាកាមទាំងអស់បន្ទាប់ពីបានរៀនជំនាញចប់នឹងទទួលបានការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែក "សហគ្រិនភាព" ដែលមានរយៈពេល ៥ថ្ងៃ និងប្រាក់ឧបត្ថម្ភជាថវិកាចំនួន ២០.០០០រៀល ក្នុង ១នាក់)។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើសូម កម្មករ កម្មការិនី និងយុវជន យុវនារី ដែលមានចំណាប់អារម្មណ៍លើមូលនិធិពិសេសនេះ សូមមកធ្វើការទំនាក់ទំនងព័ត៌មានលម្អិតនៅនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី ឬនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរាជធានី-ខេត្ត ដែលស្ថិតនៅក្រោមឱវាទក្រសួងផ្ទាល់ នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២

រដ្ឋមន្ត្រី

វង សូត

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- គ្រឹះស្ថានសិក្សាក្រោមឱវាទ
  "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ-ឯកសារ
- ទូរស័ព្ទទំនាក់ទំនង: ០១៧ ៤១៨ ៧៤៨/០១២ ២២៣ ១៨៩
- ភ្ជាប់ជាមួយនូវបញ្ជីឈ្មោះគ្រឹះស្ថានដែលធ្វើការបណ្តុះបណ្តាល

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*



បទសម្ភាសន៍

# បទពិសោធន៍ & ជោគជ័យ ក្នុងជីវិតសិក្សា

| | |
|---|---|
| ឈ្មោះ: | ខេង សុជាតា |
| អាយុ: | ២២ឆ្នាំ |
| ស្ថាប័នការងារ: | U-Kiss Burger |
| តួនាទីក្នុងការងារ: | អ្នកគិតលុយ |
| ស្រុកកំណើត: | ស្រុកកោះធំ ខេត្តកណ្តាល |
| អាសយដ្ឋាន: | ស្ទឹងមានជ័យ រាជធានីភ្នំពេញ |



យុវតី ខេង សុជាតា ជាបេក្ខនារីជ័យលាភីមួយរូប
ក្នុងចំណោមបេក្ខជនចំនួន ១៥០ នាក់
ដែលត្រូវបានជ្រើសរើសឱ្យបន្តការសិក្សា
នៅប្រទេសចិនលើជំនាញផ្នែកបច្ចេកទេសអគ្គិសនី។
ការបន្តការសិក្សានៅបរទេសគឺជាក្តីសុបិន្តដែលកញ្ញា សុជាតា
បានគិតតាំងពីយូរយារណាស់មកហើយ។
ឥឡូវ សុបិន្តនេះបានក្លាយជាការពិត
ដោយសារការតាំងចិត្ត
និងការខិតខំប្រឹងប្រែងពុះពាររាល់គ្រប់ឧបសគ្គ។

**"ឱ្យតែមានការតាំងចិត្តធ្វើ អ្វីក៏អាចធ្វើបានដែរ!"**

យុវតី **ខេង សុជាតា** អាចចាត់ទុកថាជាយុវជនគំរូមួយរូប ប្រសិនពិនិត្យមើលទៅលើការខិតខំប្រឹងប្រែងរបស់នាងនៅក្នុងជីវិត ទាំងការសិក្សា និងការធ្វើការងារ។ ដោយការរស់ក្នុងភាពជាបុគ្គលឯករាជ្យ និងឆ្ងាយពីគ្រួសារនៅក្នុងផ្ទះជួលមួយនៅតំបន់ស្ទឹងមានជ័យពិតជាធ្វើឱ្យកញ្ញា សុជាតាជួបនូវផលវិបាកជាច្រើននៅក្នុងជីវិតប្រចាំថ្ងៃ។ កញ្ញា សុជាតា មានស្រុកកំណើតនៅស្រុកកោះធំ ខេត្តកណ្តាល ស្ថិតនៅក្នុងគ្រួសារមួយដែលមានជីវភាពខ្វះខាត មិនអាចផ្គត់ផ្គង់នូវសម្ភារៈ ក៏ដូចជាធនធានគ្រប់គ្រាន់សម្រាប់ការសិក្សាបន្តនៅកម្រិតឧត្តមសិក្សានោះទេ។ អាស្រ័យដោយហេតុផលជីវភាពខ្វះខាតបែបនេះហើយ ទើបធ្វើឱ្យកញ្ញា សុជាតា សម្រេចចិត្តស្វែងរកការងារធ្វើដើម្បីបានកម្រៃខ្លះៗសម្រាប់បង់ថ្លៃសិក្សា និងផ្គត់ផ្គង់ជីវភាពពេលរស់នៅក្នុងទីក្រុង។

*សព្វថ្ងៃ **កញ្ញា ខេង សុជាតា** ជានិស្សិតឆ្នាំទី៣ នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រផ្នែកគណនេយ្យ។ ដោយសារការតាំងចិត្ត និងការតស៊ូនៅក្នុងជីវិត **កញ្ញា សុជាតា** បានឆ្លៀតពេលពីការសិក្សាដើម្បីស្វែងរកការងារ និងទទួលបានប្រាក់កម្រៃ។ ពីមួយថ្ងៃទៅមួយថ្ងៃ **កញ្ញា សុជាតា** ហាក់បីដូចជាមានភាពមមាញឹកជាខ្លាំង ដោយសារកញ្ញាកំពុងបន្តការសិក្សាផង និងធ្វើការងារពេញម៉ោងផងនៅឯហាងលក់ហេមប៊ឺហ្គ័រ (U-Kiss Burger) ដែលមានមុខងារជាអ្នកគិត-លុយ។ កញ្ញាត្រូវធ្វើការជារៀងរាល់ថ្ងៃ គឺចាប់ពីពេលព្រឹករហូតដល់ថ្ងៃត្រង់ និងល្ងាចពីម៉ោង ៥: ៣០នាទី ដល់ម៉ោង ១០យប់ និងបន្តការសិក្សាផ្នែកគណនេយ្យនៅពេលសៀល*

*បទសម្ភាសន៍រវាង លោក **សុជាតិ កញ្ញារិទ្ធិ** ( ទីប្រឹក្សា NEA) ជាមួយកញ្ញា **ខេង សុជាតា** បេក្ខជនប្រឡងជាប់អាហារូបករណ៍ផ្នែកបច្ចេកទេសអគ្គិសនីទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន តាមរយៈកម្មវិធីបណ្តុះបណ្តាលរបស់ក្រុមហ៊ុន C.I.I.D.G. ដែលធ្វើការវិនិយោគលើវិស័យថាមពលអគ្គិសនីនៅខេត្តព្រះសីហនុ។*


តទៅទំព័របន្ទាប់

ពីម៉ោង២ រសៀល ដល់ម៉ោង៥ ល្ងាច។ ទោះបីជាមានភាពមមាញឹកខ្លាំងទាំងការសិក្សា និងការងារយ៉ាងណាក្តី ក៏**កញ្ញា សុជាតា** ហាក់ដូចជាសប្បាយចិត្ត និងមានមោទនភាពចំពោះខ្លួនឯងពីព្រោះនាងបានក្លាយជាយុវជន ដែលមានភាពឯក-រាជ្យ ដោយសារពុំចាំបាច់ពឹងពាក់ប្រាក់កាសពីឪពុកម្តាយនៅឯស្រុកកំណើត។ លើសពីនេះទៀត កញ្ញាអាចសន្សំបានប្រាក់កាសខ្លះដើម្បីផ្គត់ផ្គង់ប្អូនៗឱ្យរៀនបន្ត។ សូមបញ្ជាក់ថាកញ្ញាមានបងប្អូនចំនួន៦នាក់ ហើយកញ្ញាជាបងស្រីធំនៅក្នុងគ្រួសារដែលត្រូវមានភារកិច្ចមើលការខុសត្រូវប្អូនៗ។ សព្វថ្ងៃមានប្អូនស្រីម្នាក់មកបន្តការសិក្សានៅទីក្រុងភ្នំពេញ ហើយវាក៏ជាបន្ទុកមួយសម្រាប់ **សុជាតា** ក្នុងការផ្គត់ផ្គង់ប្អូនផងដែរ។

ទោះបីជាមានការលំបាកជាច្រើននៅក្នុងជីវិតក៏ដោយក៏ **កញ្ញា សុជាតា** នៅតែខំប្រឹងប្រែងតស៊ូនៅក្នុងជីវិត និងមិនបោះបង់ចោលនូវក្តីសុបិន្តរបស់ខ្លួនក្នុងការបន្តការសិក្សានៅឯបរទេស ដែលខ្លួននាងផ្ទាល់គិតថាជាការស្រមៃមួយ និងអាចជួយលើកកិត្តិយសគ្រួសារ។ ការរំពឹងក្នុងការបន្តការសិក្សានៅបរទេសហាក់បីដូចជាមានក្តីសង្ឃឹមនៅពេលដែល **កញ្ញា សុជាតា** បានទទួលដំណឹងអំពីការប្រកាសប្រលងអាហារូប-ករណ៍ទៅសិក្សានៅប្រទេសចិន តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដែលបានជួយសម្របសម្រួល និងរៀបចំឱ្យក្រុមហ៊ុន C.I.I.D.G. Erdos Hongjun Electric Power Co., Ltd. ដែលជាក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋា-ភិបាលកម្ពុជា ក្នុងការបង្កើតរោងចក្រអគ្គិសនីដែលមានកម្លាំងផលិតថាមពល ៧X១៣៥ MW នៅក្នុងខេត្តព្រះសីហនុសម្រាប់ផ្គត់ផ្គង់ថាមពលដល់អគ្គិសនីកម្ពុជា (EDC) ដើម្បីធ្វើការជ្រើសរើសសិស្ស-និស្សិតចំនួន ១៥០នាក់ សម្រាប់ទទួលអាហារូបករណ៍ទៅបណ្តុះបណ្តាលរយៈពេល ១ឆ្នាំ និង ៦ខែ នៅសាកលវិទ្យាល័យ Dian Li នៃសាធារណរដ្ឋប្រជាមានិត-ចិន និងត្រលប់មកធ្វើការនៅក្នុងរោងចក្រអគ្គិសនីរបស់ក្រុមហ៊ុននៅខេត្តព្រះសីហនុបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល។

នេះគឺជាដំណឹងដ៏ល្អមួយសម្រាប់ **កញ្ញា សុជាតា** ដើម្បីអាចសម្រេចនូវក្តីសុបិន្តរបស់ខ្លួនបាន។ ដោយសារចង់សម្រេចនូវក្តីសុបិន្តក្នុងការសិក្សានៅបរទេស និងដើម្បីលើកស្ទួយកិត្តិយសគ្រួសារ និងខ្លួនឯងផង **កញ្ញា ខេង សុជាតា** ក៏បានសម្រេចចិត្តដាក់ពាក្យប្រលង។ នៅក្នុងការប្រលងនេះបេក្ខជនត្រូវឆ្លងកាត់ការប្រឡងលើវិញ្ញាសារគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងភាសាបរទេស (អង់គ្លេស ឬភាសាចិន)។ ដោយសារការខិតខំសិក្សារបស់ **កញ្ញា សុជាតា** ជាពិសេសការឆ្លៀតសិក្សាបន្ថែមភាសាចិន អាចធ្វើឱ្យកញ្ញាមានសមត្ថ-ភាពក្នុងការឆ្លងកាត់វិញ្ញាសារប្រលងភាសាចិន។ ជាលទ្ធផល កញ្ញា **ខេង សុជាតា** ត្រូវបានក្រុមហ៊ុនជ្រើសរើសជាបេក្ខជនទទួលអាហារូបករណ៍សម្រាប់សិក្សានៅប្រទេសចិន។ ក្រោយពីទទួលដំណឹងនេះហើយ **កញ្ញា សុជាតា** មានអារម្មណ៍ភ័យផង អរផង ពីព្រោះត្រូវគិតអំពីផលវិបាកនៅពេលសិក្សានៅឯស្រុកគេ។ កញ្ញាបន្តថា «ខ្ញុំមានការព្រួយបារម្ភខ្លះៗនៅពេលរស់នៅប្រទេសចិនពីព្រោះអាកាសធាតុត្រជាក់ខ្លាំង ហើយមួយវិញទៀតបារម្ភអំពីរបៀបរបបរស់នៅនៅស្រុកគេដូចជាម្ហូបអាហារ ជាដើម។»

ទោះបីជាយ៉ាងណាក៏ដោយ **កញ្ញា សុជាតា** ជាយុវជនម្នាក់ដែលមានការតាំងចិត្តខ្ពស់ ហ៊ានពុះពារគ្រប់ឧបសគ្គ និងមិនរាយចុះចាញ់នូវការលំបាកឡើយ។

កញ្ញាបន្ថែមថា៖ «ខ្ញុំតែងតែឮចាស់ៗនិយាយប្រាប់នូវឃ្លាមួយថា មុជមិនជ្រៅទៅមិនឆ្ងាយ។ ខ្ញុំគិតថាពាក្យនេះល្អ និងបានណែនាំឱ្យមនុស្សចេះប្រឹងប្រែងខិតខំជំនះរាល់ឧបសគ្គ ទើបអាចទទួលបានលទ្ធផលមួយ ដែលយើងពេញចិត្ត។ សម្រាប់ខ្ញុំ គឺខ្ញុំមិនខ្លាចនឹងផលវិបាកទេ ផ្ទុយទៅវិញ ខ្ញុំនឹងខិតខំតស៊ូរៀននៅប្រទេសគេឱ្យបានទទួលជោគជ័យល្អ។ ហើយខ្ញុំសង្ឃឹមថាពេលរៀនចប់ នឹងទទួលបានការងារល្អមួយសម្រាប់ផ្គត់ផ្គង់ជីវភាពខ្លួន និងគ្រួសារនៅឯស្រុកកំណើតទៀតផង។»

**“មុជមិនជ្រៅ ទៅមិនឆ្ងាយ”**

តទៅទំព័របន្ទាប់

គួររំឭកដែរថា **កញ្ញា ខេង សុជាតា** គឺជាបេក្ខនារីមួយរូបក្នុងចំណោមបេក្ខនារីចំនួន៨នាក់តែប៉ុណ្ណោះ ដែលបានប្រលងជាប់នូវអាហារូបករណ៍សម្រាប់បន្តការសិក្សានៅក្នុងប្រទេសចិន ផ្នែកជំនាញអគ្គិសនី។ **សុជាតា** បានឆ្លងកាត់នូវការប្រលងជម្រុះបេក្ខជនទាំងអស់ប្រមាណ ៥០០នាក់។ សូមបញ្ជាក់ថា ឆ្នាំនេះគឺជាឆ្នាំទី២ហើយ ដែលក្រុមហ៊ុន C.I.I.D.G. Erdos Hongjun Electric Power Co., Ltd. បានធ្វើការប្រលងជ្រើសរើសបេក្ខជនសម្រាប់សិក្សាជំនាញ «បច្ចេកទេសអគ្គិសនី» នៅប្រទេសចិន ក្រោយពីបានបញ្ជូនសិស្សឱ្យទៅសិក្សាជំនាន់ទី ១ រួចមក។



ជាចុងក្រោយ **កញ្ញា ខេង សុជាតា** មានពាក្យពេចន៍មួយចំនួនចង់ផ្ដាំផ្ញើទៅដល់បងប្អូន និងនិស្សិតដែលកំពុងសិក្សា និងចង់ទទួលបាននូវជោគជ័យក្នុងជីវិតទាំងការសិក្សា និងការងារដូចរូបកញ្ញាថា៖

- ទី១ គឺយើងត្រូវដឹងអំពីអ្វី ដែលខ្លួនចង់ធ្វើ ដោយយើងត្រូវសិក្សាអំពីផលវិបាកនានា ហើយព្យាយាមជំនះនូវផលវិបាកទាំងអស់។
- ទី២ គឺយើងម្នាក់ៗត្រូវមានការតាំងចិត្តខ្ពស់ ពោលគឺតស៊ូ និងជំនះនូវឧបសគ្គនានា ដែលមាននៅក្នុងជីវិត។
- ទី៣ គឺ យើងមិនត្រូវស្ដីបន្ទោសលើព្រហ្មលិខិត និងវាសនារបស់ខ្លួននោះឡើយ ជាពិសេសកុំដាក់ទោសលើឪពុកម្ដាយ ដែលមិនមានលទ្ធភាពគ្រប់គ្រាន់។ អ្វីដែលសំខាន់នោះគឺស្ថិតនៅលើទឹកចិត្តរបស់យើង។ ឱ្យតែមានការតាំងចិត្ត គឺធ្វើអ្វីប្រាកដជាបានសម្រេច។

## លក្ខខណ្ឌជ្រើសរើសបេក្ខជនសម្រាប់ការប្រលងអាហារូបករណ៍របស់ក្រុមហ៊ុន

C.I.I.D.G. Erdos Hongjun Electric Power Co., Ltd.

### ❁ កម្រិតវប្បធម៌៖

- ☑ និសិត្សបញ្ចប់បរិញ្ញាប័ត្រ បរិញ្ញាប័ត្ររង ឬនិសិត្សឆ្នាំទី ៣ ទី៤ ឬជាបេក្ខជន ដែលមានសញ្ញាប័ត្រជាន់ខ្ពស់ទាក់ទងជំនាញវិស្វករអគ្គិសនី យន្តការី វិទ្យាសាស្ត្រកុំព្យូទ័រ វិទ្យាសស្ត្រធម្មជាតិ ឬសិស្សដែលបានបញ្ចប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។
- ☑ ត្រូវមានចំណេះដឹងផ្នែកគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

### ❁ លក្ខខណ្ឌអាទិភាពចំពោះ៖

- ☑ បេក្ខជនដែលចេះភាសាអង់គ្លេស និងភាសាចិន។
- ☑ បេក្ខជនដែលមានជំនាញផ្នែកអគ្គិសនី។
- ☑ បេក្ខជនដែលមានលំនៅដ្ឋាន ឬរស់នៅក្នុងខេត្តព្រះសីហនុ។

### ❁ លក្ខខណ្ឌផ្សេងទៀត៖

- ☑ បេក្ខជនត្រូវមានសុខភាពមាំមួន និងអត្តចរិតស្លូតបូត។
- ☑ បេក្ខជនត្រូវមានអាយុចាប់ពី១៨ ដល់ ២៧ឆ្នាំ។
- ☑ បេក្ខជនត្រូវមានអ្នកធានាចំនួនពីរនាក់ ដែលជាអាណាព្យាបាល ឬញាតិសន្ដានជិតស្និទ្ធ។

កូនដែលមិនដោយតាមគន្លងធម៌ម្នាក់ធ្វើឱ្យម្ដាយពិបាកចិត្ត

កូនល្អមួយរូបធ្វើឱ្យគ្រួសារមានកិត្តិយស!!



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និង ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## NEA សហការរៀបចំការប្រឡងជ្រើសរើស និស្សិតអាហារូបករណ៍ឱ្យក្រុមហ៊ុន C.I.I.D.G



NTTI៖ កាលពីថ្ងៃទី២៥-២៧ ខែកុម្ភៈ ឆ្នាំ២០១១ កន្លងទៅនេះ NEA បានសហការរៀបចំការប្រឡងអាហារូបករណ៍ជ្រើសរើសនិស្សិតខ្មែរទៅបណ្តុះបណ្តាលលើបច្ចេកទេសអគ្គិសនីនៅសាធារណរដ្ឋប្រជាមានិតចិន ទៅឱ្យក្រុមហ៊ុន C.I.I.D.G Edos Hongjun Electric Power Co., Ltd. ដែលបានប្រព្រឹត្តិទៅនៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI)។

វិញ្ញាសានៃការប្រឡងអាហារូបករណ៍នេះមានពីរដំណាក់កាលគឺ ទី១ ការធ្វើតេស្តសរសេរ និងទី២ ការធ្វើតេស្តផ្ទាល់មាត់។ ការប្រឡងបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដោយមានសិស្ស និស្សិតចូលរួមប្រឡងសរុបចំនួន ៥១៦នាក់ ក្នុងចំណោមអ្នកដាក់ពាក្យ ៦៣៨ នាក់។ ជាលទ្ធផល មានបេក្ខជន និងបេក្ខនារី ចំនួន ១៥០នាក់ (ស្រីចំនួន ០៨នាក់) ត្រូវបានជ្រើសរើស និងជាប់ជាស្ថាពរ។

សូមបញ្ជាក់ផងដែរថា នេះជាលើកទីពីរហើយដែល NEA បានសហការរៀបចំការប្រឡងអាហារូបករណ៍សម្រាប់ក្រុមហ៊ុន C.I.I.D.G ដែលលើកទី១ ប្រព្រឹត្តទៅនាថ្ងៃទី១៧-១៨ ខែសីហា ឆ្នាំ២០១១ ដែលមានបេក្ខជន និងបេក្ខនារីចំនួន ១៣៤នាក់ (ស្រីចំនួន ១២នាក់) ត្រូវបានបញ្ជូនទៅបណ្តុះបណ្តាល៕



សិស្សប្រឡងវិញ្ញាសាសរសេរ



តំណាងក្រុមហ៊ុនកំពុងសម្ភាសន៍បេក្ខជន

## កិច្ចប្រជុំពិភាក្សាការងាររវាង NEA ជាមួយតំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC)

**NEA**៖ កាលពីរសៀលថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ NEA ដែលដឹកនាំដោយ ឯកឧត្តម **ហុង ជឿន** (ប្រធាន NEA) បានទទួលជួបពិភាក្សាការងារស្តីពីតម្រូវការកម្លាំងពលកម្មក្នុងវិស័យវាយនភ័ណ្ឌ ជាមួយលោក **លី តេកហេង** តំណាងសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC)។

លោក **លី តេកហេង** បានលើកឡើងពីកង្វល់នៃកង្វះខាតកម្លាំងពលកម្មនៅតាមបណ្តារោងចក្រនានាដែលបច្ចុប្បន្ននេះមានរោងចក្រចំនួន ៤៤ កំពុងត្រូវការកម្លាំងពលកម្មចំនួន ១៨.៧២៤ នាក់ ។ បន្ថែមលើនេះ លោកបានស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធរវាង NEA និង GMAC ក្នុងកិច្ចការផ្គត់ផ្គង់កម្លាំងពលកម្ម ព្រមទាំងស្នើសុំលទ្ធភាពឱ្យមន្ត្រី GMAC បានចូលរួមផ្សព្វផ្សាយ និងជ្រើសរើសពលករនៅតាមមូលដ្ឋានក្រោមកិច្ចសម្របសម្រួលរបស់ NEA ។



ភាគីទាំងពីរបានព្រមព្រៀងគ្នាជាបឋមក្នុងការចាត់តាំងជនបង្គោលសម្រាប់សម្របសម្រួលលើកិច្ចការនេះ ដែលមានលោក **សាម៉េន សុខា** (តំណាង NEA) និងលោក **ទឹម សាវ៉ាន់** (តំណាង GMAC)៕

## មជ្ឈមណ្ឌលការងារខេត្តបាត់ដំបងរៀបចំសិក្ខាសាលាស្តីពី «ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព»

**បាត់ដំបង**៖ មជ្ឈមណ្ឌលការងារខេត្តបាត់ដំបងក្រោមជំនួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីអង្គការពលកម្មអន្តរជាតិ (ILO) បានរៀបចំសិក្ខាសាលាស្តីអំពី "ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព" ដែលមានរយៈពេល ១ថ្ងៃ គឺថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ នៅសណ្ឋាគារខេមរា បាត់ដំបង១ ខេត្តបាត់ដំបង ក្រោមអធិបតីភាពរបស់ លោក **ភួង ជា** ជាប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង លោក **ឃ្លាំង រីម**

តទៅទំព័របន្ទាប់

អ្នកសម្របសម្រួលគម្រោងរបស់អង្គការពលកម្មអន្តរជាតិ (ILO) និង លោក **សួង សង្វារុទ្ធី** ប្រធានផ្នែកផែនការ និងសហប្រតិបត្តិការនៃ NEA ។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួមចំនួន ២៦នាក់ ។

គោលបំណងនៃវគ្គសិក្ខាសាលានេះ គឺដើម្បីបង្កើនការយល់ដឹង និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីឃុំ/សង្កាត់ លើការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ សិក្ខាកាមទាំងអស់ទទួលបាននូវចំណេះដឹងពាក់ព័ន្ធទៅនឹងគោលនយោបាយជាតិស្តីពីការធ្វើទេសន្តរប្រវេសន៍ ភាពងាយរងគ្រោះ និងបញ្ហាប្រឈមរបស់ជនទេសន្តរប្រវេសន៍ បណ្តាញ និងការចែកចាយព័ត៌មានគម្រោងផែនការអនុវត្តន៍របស់បណ្តាអង្គការពាក់ព័ន្ធ៕



## កិច្ចប្រជុំពិភាក្សាការងាររវាង NEA ជាមួយអ្នកជំនាញការជាន់ខ្ពស់ផ្នែកជំនាញ និងលទ្ធភាពការងាររបស់អង្គការ ILO



កាលពីរសៀលថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១៤.០០ នាទី នៅបន្ទប់ប្រជុំរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ បានទទួលជួបប្រជុំជាមួយលោកស្រី Carmela I. Torres អ្នកជំនាញការជាន់ខ្ពស់ផ្នែកជំនាញ និងលទ្ធភាពការងាររបស់អង្គការ ILO។

ក្នុងរបៀបវារៈនៃកិច្ចប្រជុំនោះ **លោកស្រី** Carmela I. Torres ចង់ស្វែងយល់អំពីដំណើរការនៃការពង្រឹងសមត្ថភាពចំពោះមន្ត្រីថ្មីរបស់ NEA និងមន្ត្រីនៅមជ្ឈមណ្ឌលការងារ ព្រមទាំងសកម្មភាពនៃការណែនាំពីសេវាកម្មរបស់ NEA ទៅកាន់សិស្ស និស្សិត សាធារណជនទូទៅ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត និងដំណើរការនៃការចងក្រង Top Ten Job/Vacancy។

បន្ទាប់ពីបានពិភាក្សា និងបកស្រាយនូវចំណុចលម្អិតជូនតំណាងអង្គការ ILO រួចមក ឯកឧត្តមប្រធាន ក៏បានថ្លែងអំណរគុណ និងរំឭកឡើងវិញដែរថាអង្គការ ILO ជានិច្ចកាលគឺជាដៃគូអភិវឌ្ឍយ៉ាងសំខាន់ដែលតែងតែគាំទ្រដល់សកម្មភាពការងាររបស់ NEA ជារៀងរហូតមក៕

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ និងទិសដៅអនុវត្តខែបន្តរបស់ ទ.ជ.ម.ក



NEA៖ កាលពីថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១២ នៅទីស្នាក់ការកណ្តាលរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ និងលើកទិសដៅអនុវត្តបន្តក្នុងខែមីនា ដែលប្រព្រឹត្តិទៅក្រោមអធិបតីភាព **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ និងមានការចូលរួមពីសំណាក់មន្ត្រីរាជការនៅថ្នាក់កណ្តាលទាំងអស់។

កិច្ចប្រជុំបូកសរុបនេះបានទទួលលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

- បានបញ្ចប់សេចក្តីព្រាងកិច្ចសន្យាគ្រប់គ្រងការផ្តល់សេវាឆ្នាំ២០១២ របស់ NEA។
- បានធ្វើតារាងបែងចែកភារកិច្ចសម្រាប់ចុះប្រមូលទិន្នន័យអ្នកស្វែងរកការងារធ្វើ នៅទូទាំងរាជធានី ខេត្ត និងកាលវិភាគសម្រាប់ចុះតាមស្រុកនៃខេត្តចំនួន ៤ គឺ ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តមណ្ឌលគិរី។
- បានផ្សព្វផ្សាយសៀវភៅដែល NEA បានបោះពុម្ពរួចទៅក្នុងគេហទំព័រមគ្គុទេសក៍អាជីព និងការងារដែលមានសៀវភៅណែនាំសម្រាប់អ្នកស្វែងរកការងារធ្វើ សៀវភៅណែនាំស្តីអំពីការប្រឹក្សាយោបល់ការងារ សៀវភៅណែនាំស្តីពីដំណើរការប្រតិបត្តិការការងាររបស់មជ្ឈមណ្ឌលការងារនៃ NEA និងបណ្ណណែនាំស្តីពីការងារ និងព្រឹត្តិបត្រការងារទាំង០៧លេខ។

បន្ទាប់ពីការធ្វើរបាយការណ៍តាមផ្នែក និងក្រុមការងារនីមួយៗរួចមក ឯឧត្តមប្រធានអង្គប្រជុំបានវាយតម្លៃខ្ពស់ចំពោះការអនុវត្តការងារ ដែលសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ និងសំណូមពរឱ្យមន្ត្រីរាជការទាំងអស់បន្តនូវឆន្ទៈអនុវត្តការងារ ដើម្បីរួមចំណែកទាំងអស់គ្នាសម្រេចឱ្យបាននូវផែនការអនុវត្តការងារប្រចាំឆ្នាំ២០១២នេះ៕




# កំសាន្តនិងប្រាជ្ញា

ទំព័រកំសាន្ត និងប្រាជ្ញាត្រូវបានបង្កើតឡើងក្នុងចំណងផ្តល់នូវការកំសាន្តតាមបែបល្បងប្រាជ្ញា ដើម្បីទទួលបាននូវការរីករាយ និងបង្កើនចំណេះជូនមិត្តអ្នកអានទាំងអស់។ ព្រឹត្តិបត្រការងារសង្ឃឹមថា ទំព័រនេះអាចជួយផ្តល់ជាប្រយោជន៍ផ្នែកសតិប្រាជ្ញានិងការត្រិះរិះពិចារណា ជាពិសេស ចំពោះមិត្តអ្នកអានណាដែលមិនធ្លាប់សាកល្បងដោះស្រាយនូវចំណោទបែបនេះពីមុនមក។

ទំព័រកំសាន្ត និងប្រាជ្ញានេះមានល្បែងផ្សេងៗដូចជា ការស្វែងរកពាក្យខ្វែងជាភាសាអង់គ្លេស (Crossword) និងការធ្វើចំណោទជាលេខនព្វន្ត ជាដើម។ អាស្រ័យហេតុនេះ សូមប្រិយមិត្តអ្នកអានទាំងអស់សាកល្បងដោះស្រាយ និងរីករាយជាមួយល្បែងល្បងប្រាជ្ញា ដូចខាងក្រោម៖

ចូរបំពេញនូវការេនីមួយៗ ដែលធ្វើឱ្យជួរដេក និងជួរឈរ ព្រមទាំងប្រអប់ទាំង ៣x៣ មានលេខពី ១ដល់៩។ ចម្លើយគឺមានតែមួយគត់ចំពោះល្បែងនេះ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1 3 7 9 | 3 4 7 9 | 8 | 1 89 | 6 | 2 | 5 | 1 3 4 7 9 | 123 4 8 |
| 1 | 23 45 | 12 45 7 9 | 7 | 8 | 1 3 45 | 6 | 23 4 | 9 |
| 456 7 | 23 456 789 | 2 4 6 7 9 | 1 5 9 | 3 56 9 | 1 3 45 | 23 4 6 78 | 123 4 7 | 123 4 8 |
| 2 4 78 | 2 4 78 | 3 | 6 | 2 4 7 | 9 | 1 | 5 | 2 6 789 |
| 2 6 8 | 12 6 8 | 5 | 3 | 4 | 123 5 78 | 2 89 | 2 56 9 | 7 |
| 9 | 1 | 2 6 7 | 2 45 8 | 3 5 7 9 | 1 5 78 | 23 8 | 23 56 | 4 |
| 2 | 56 789 | 1 56 7 9 | 5 89 | 3 5 7 9 | 3 56 789 | 23 4 7 9 | 1 3 4 6 7 9 | 123 56 |
| 4 | 56 7 9 | 6 7 9 | 45 89 | 1 | 3 56 7 9 | 23 7 9 | 8 | 23 56 7 |
| 3 | 56 789 | 1 56 7 9 | 4 | 2 | 1 56 78 | 1 3 56 7 9 | 1 6 7 9 | 1 56 |

## ល្បែងពាក្យខ្វែង (Crossword puzzle) (Banking)




**ACROSS**

5 special place in a bank where large amounts of cash is kept
7 bank employee who helps customers deposit or withdraw money
8 take money out of a bank account
10 a bank employee who helps customers borrow money (2 words)
12 automated teller machine
13 can be coins or paper money
14 a safe place to deposit your money

**DOWN**

1 employee who guards a bank (2words)
2 put money in a bank account
3 special trucks with armored guards that pick up and deliver cash to banks (2 words)
4 borrowed money
6 safe ___________ boxes
9 another word for cash
11 "Cash, ___________, or charge?"

*សូមផ្ទៀងផ្ទាត់ចម្លើយរបស់លោកអ្នក សម្រាប់ល្បែងទាំងបីប្រភេទ ដែលនឹងចេញផ្សាយនៅលេខបន្ទាប់!*

*«ទំព័រកំសាន្ត និងប្រាជ្ញា» ដកស្រង់ និងរៀបចំដោយ លោក **ទូច សុផាត** (អនុប្រធានផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន) និង កញ្ញា **ឈា បញ្ញារី** (មន្ត្រីផ្នែករចនា-គំនូរក្រាហ្វិក)។*

តទៅទំព័របន្ទាប់

# ល្បែងតក្កវិជ្ជា ( Logical Game )

តេស្តនេះគឺចោទជាប្រស្នាក្នុងបំណងចង់ដឹងថា តើលោកអ្នកអាចធ្វើការសម្រេចចិត្តដោយស្របទៅតាមចក្ខុវិញ្ញាណ ពោលគឺរបស់លោកអ្នកកំពុងមើលឃើញដែរឬទេ។

លោកអ្នកត្រូវជ្រើសរើសរៀបរូប ដែលមានបង្ហាញជូនទាំងអស់នេះតាមលំដាប់លំដោយ។ លោកអ្នកត្រូវជ្រើសរើសយករូបមួយក្នុងចំណោមរូប៤ (A, B, C, និង D) ដើម្បីរកឱ្យឃើញថា តើរូបណាមួយដែលជារូបត្រឹមត្រូវទៅតាមស៊េរី ឬលំដាប់នៃលេខរៀងរបស់វា។

**ឧទាហរណ៍:** ចម្លើយត្រឹមត្រូវសម្រាប់រូបខាងក្រោមនេះគឺ រូប (A) ដែលត្រូវយកមកបំពេញនៅត្រង់ចន្លោះកន្លែងសញ្ញាសួរ។



☑ A ☐ B ☐ C ☐ D

ចម្លើយត្រឹមត្រូវគឺ (A) ពីព្រោះគេសម្គាល់ឃើញថាបន្ទាត់មួយត្រូវបានបន្ថែមជាដរាប។ បន្ទាត់វែងដែលទ្រេតពីឆ្វេងទៅស្តាំគឺតែងតែបន្ថែមមុនដំបូងគេ (សូមមើលរូប)។

ប្រសិនបើ លោកអ្នកចង់កំណត់ពេលសម្រាប់ការដោះស្រាយចំណោទដែលមានបង្ហាញជូននៅផ្នែកខាងស្តាំ គឺលោកអ្នកមានរយៈពេល៦នាទី។

១.តើរង្វង់មួយណាត្រូវជំនួសបន្ទាប់នៅត្រង់កន្លែងសញ្ញាសួរ?



☐ A ☐ B ☐ C ☐ D

២. តើរង្វង់នៅក្នុងចតុកោណកែងមួយណាត្រូវជំនួសបន្ទាប់នៅត្រង់កន្លែងសញ្ញាសួរ?



☐ A ☐ B ☐ C ☐ D

៣.តើសញ្ញាព្រួញមួយណាត្រូវជំនួសបន្ទាប់នៅត្រង់កន្លែងសញ្ញាសួរ?



☐ A ☐ B ☐ C ☐ D

៣.តើត្រីកោណមួយណាត្រូវជំនួសបន្ទាប់នៅត្រង់កន្លែងសញ្ញាសួរ?



☐ A ☐ B ☐ C ☐ D

៤.តើរូបមួយណាត្រូវជំនួសបន្ទាប់នៅត្រង់កន្លែងសញ្ញាសួរ?



☐ A ☐ B ☐ C ☐ D

## ចម្លើយកំសាន្ត និងប្រាជ្ញា (ក្នុងការផ្សាយលេខ ០០៧)

ល្បែងតក្កវិជ្ជា ១.☑ C) ២.☑ B) ៣.☑ C)

ល្បែងពាក្យខ្វែង




Sudoku





សួស្តីឆ្នាំថ្មី ឆ្នាំ២០១២
Happy Khmer New Year
2012
សូមបួងសួងដល់ទេវតាឆ្នាំថ្មី ព្រះនាម គិរិណីទេវី ជួយប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ
មហាប្រសើរ ក្នុងឱកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរោង ចត្វាស័ក ព.ស២៥៥៦ ត្រូវនឹងគ.ស២០១២
សូមឆ្នាំថ្មីនាំមកនូវសេចក្តីសុខ សុភមង្គល សុខភាពមាំមួន កម្លាំងមាំមួន ប្រាជ្ញាឈ្លាសវៃ
ជ័យជំនះគ្រប់ភារកិច្ច និងវឌ្ឍនភាព កុំបីឃ្លៀងឃ្លាតឡើយ។
May this coming year, the year of Dragon,
bring you Good Health, Happiness, Success, and Prosperity.
គោរពជូនពរពី ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃ
Best Wishes From the management and staff of
ទីភ្នាក់ងារជាតិមុខរបរ និងការងារ
National Employment Agency
អាសយដ្ឋាន: វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
: ០២៣ ៦៣៥ ៧១៧៧ ឬ ០៨៨ ៦៧៨ ៥៦៧៨ :info@nea.gov.kh :www.nea.gov.kh




ព្រឹត្តិបត្រការងារ
Labour Bulletin
JOB SHOP
ទំនាក់ទំនងផ្សព្វផ្សាយក្នុងគេហទំព័រ
www.nea.gov.kh
សូមទំនាក់ទំនង:
លោក ចាន់ វឌ្ឍនៈ
មន្ត្រីផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន
ទូរស័ព្ទ: ០១៦ ៧១៦ ៨៩១
អ៊ីម៉ែល: vatanak_chan@yahoo.com




KWIN Inc.
Web Design
Web Hosting
Domain Registration
Web Application
Windows Application
Mobile Application
Contact Us
Tel: 012 783 999 , 011 322 511
015 322 511 , 023 633 8003
sales@kwin.com.kh , www.kwin.com.kh



hello
និយាយបានរហូតដល់ 20 ម៉ោង
ក្នុង 1 ថ្ងៃ ត្រឹមតែ 400 រៀល!
ជាមួយ ហេឡូ លោកអ្នកអាចនិយាយបានកាន់តែយូរពេញមួយថ្ងៃ និងគ្រប់ទីកន្លែង។ លោកអ្នកអាចចុះឈ្មោះប្រើប្រាស់គម្រោងឥតកំណត់ 20 ម៉ោង ឬគម្រោងឥតកំណត់ 24 ម៉ោង។ ឡូយ!
គម្រោង | រយៈពេល | តម្លៃ | វិធីចុះឈ្មោះ
ឥតកំណត់ 20* ម៉ោង | ប្រចាំថ្ងៃ | 400 រៀល | *123*400#
ប្រចាំខែ | 2 ដុល្លារ | *123*130#
ឥតកំណត់ 24 ម៉ោង | ប្រចាំថ្ងៃ | 800 រៀល | *123*1#
ប្រចាំខែ | 3 ដុល្លារ | *123*30#
*ពីម៉ោង 10 យប់ ដល់ម៉ោង 6 ល្ងាច។ លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត។
400៛
facebook.com/helloaxiata
hello
an axiata company (ក្រុមហ៊ុន ម៉ាឡេស៊ី)
www.hello.com.kh | សេវាបំរើអតិថិជន 016 810 000 ឬ 1452
ក្រុមហ៊ុន ហេឡូ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីដោយពុំមានការជម្រាបជូនជាមុន។

# វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

# NATIONAL TECHNICAL TRAINING INSTITUTE

NTTI អភិវឌ្ឍន៍កម្មវិធីសិក្សាតម្រូវតាមទីផ្សារបច្ចុប្បន្ន និងបច្ចេកវិទ្យាឈានមុខគេក្នុងវិស័យបណ្តុះបណ្តាល

## ឱកាសការងារ ឱកាសអាជីវកម្ម ឱកាសក្លាយជាមន្ត្រីរាជការ

NTTI ជាគ្រឹះស្ថានឧត្តមសិក្សាបច្ចេកទេសរបស់រដ្ឋឈានមុខមួយ ដែលទទួលស្គាល់ ដោយរាជរដ្ឋាភិបាលតាមអនុក្រឹត្យលេខ ១០៩ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០១ ។

វិទ្យាស្ថាន បណ្តុះបណ្តាលដល់និស្សិតតាមប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលទទួលបាននូវ ចំណេះដឹង ជំនាញ បទពិសោធន៍ សីលធម៌វិជ្ជាជីវៈ ព្រមទាំងសមត្ថភាពប្រកបដោយគុណភាព ឆ្លើយតបនឹង តម្រូវការទីផ្សារការងារ ។

### កិច្ចសហប្រតិបត្តិការក្នុង និងក្រៅប្រទេស

- កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន (amco-Phnom Penh Tower, KTC, K-Cement ...)
- កិច្ចសហការ និងផ្លាស់ប្តូរបទពិសោធន៍ជាមួយក្រុមនិស្សិតមកពីសាកល វិទ្យាល័យ Lyles រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ ។

### កម្រិតសញ្ញាបត្រ

ថ្នាក់អនុបណ្ឌិត
ថ្នាក់បរិញ្ញាបត្រ
ថ្នាក់ត្រៀមបន្តបរិញ្ញាបត្រ
ថ្នាក់បរិញ្ញាបត្ររង
ថ្នាក់បណ្តុះបណ្តាលគ្រូបច្ចេកទេស

### មុខជំនាញបរិញ្ញាបត្រ

សំណង់ស៊ីវិល
អគ្គិសនី
អេឡិចត្រូនិច
ព័ត៌មានវិទ្យា
ស្ថាបត្យកម្ម






### ទំនាក់ទំនងតាមរយៈ

Email: info@ntti.edu.kh
Tel : (855-23) 883 039
Fax : (855-23) 883 039
Website: www.ntti.edu.kh

012 859 901
012 900 951
012 957 684
012 528 900
097 7610 831
011 322 294
092 804 868

# ផ្នែកមួយនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា

និស្សិតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាមានលទ្ធភាពធ្វើមនុស្សយន្ត (Robot) ដែលអាចដើរ ទាត់បាល់ ធ្វើតម្រាប់តាមកាយវិការមនុស្ស និងកាយវិការជាច្រើនទៀត។ ដោយមានកិច្ចសហការរវាងវិទ្យាស្ថាន និងសាកលវិទ្យាល័យ KUT សាធារណរដ្ឋកូរ៉េយ៉ាងស្និតរមួតលើផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ប្រតិភូសាកលវិទ្យាល័យ KUT មួយក្រុមមានសាស្ត្រាចារ្យ និងនិស្សិតកូរ៉េផងនោះ បានមកផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាថ្មីជាមួយនិស្សិតយើង។



នៅក្នុងឆ្នាំនេះ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានអញ្ជើញប្អូនៗសិស្សវិទ្យាល័យថ្នាក់ទី១២ ចំនួន២៨៣០នាក់ ក្នុងគោលបំណង៖ **ទី១** គឺបង្ហាញអំពីសំភារៈបរិក្ខារទំនើបៗ កម្មវិធីសិក្សា និងសក្តានុពលភាពផ្សេងៗ។ **ទី២** គឺផ្តល់គំនិត និងចក្ខុវិស័យយ៉ាងច្បាស់លាស់ថា មានតែការសិក្សាបច្ចេកទេស ទើបមានការងារធ្វើច្រើនជាងគេ ព្រោះប្រទេសកម្ពុជារីកចំរើនច្រើនវិស័យណាស់ ជាពិសេស ក្រុមហ៊ុន រោងចក្រឧស្សាហកម្មត្រូវការវិស្វករ និងអ្នកបច្ចេកទេសច្រើនអនេក។






***ព័ត៌មានសិក្សាបន្ថែម៖***

កាលបរិច្ឆេទចូលរៀនឆ្នាំសិក្សា២០១២-២០១៣ គឺ ទទួលពាក្យចូលរៀនពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ រហូតដល់ថ្ងៃបើកបវេសនកាលថ្មី ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២។ ទីតាំង៖ ផ្លូវទំនប់កប់ស្រូវ ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ។ ទូរសព្ទ៖023 69 15 193/023 673 6633/012 38 12 46/011 76 9003

# ដៃគូសហការសំខាន់ៗ

## គ្រឹះស្ថានអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ

- វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
- វិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស
- វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
- វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា
- វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម
- វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង
- សាកលវិទ្យាល័យបាត់ដំបង
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត
- សាកលវិទ្យាល័យបៀលប្រាយ
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច
- សាកលវិទ្យាល័យមេគង្គកម្ពុជា
- សាកលវិទ្យាល័យអាស៊ីអឺរ៉ុប
- សាកលវិទ្យាល័យជាតិគ្រប់គ្រង
- សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
- វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសច្ចៈ
- សាកលវិទ្យាល័យធនធានមនុស្ស
- វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិ កម្ពុជា
- សាកលវិទ្យាល័យឯកទេសនៃកម្ពុជា
- សាកលវិទ្យាល័យកម្ពុជា

## អង្គការ ក្រុមហ៊ុន សហគ្រាស និងស្ថាប័នផ្សេងៗ

# ទីភ្នាក់ងារជាតិមុខរបរ និងការងារ
# នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## ជាស្ពានឆ្ពោះទៅកាន់

ការងារ    កម្លាំងពលកម្ម    ព័ត៌មានទីផ្សារការងារ

## Gateway to

Jobs    Work Forces    Labour Market Information

# ទូទាំងប្រទេសនៅមួយកន្លែងងាយស្រួល

# NATIONWIDE IN A SINGLE SOURCE

សម្រាប់ព័ត៌មានបន្ថែមសូមចូលមើលគេហទំព័រ:

**www.nea.gov.kh**

ចំណាំ: អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយឥតគិតថ្លៃមកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!



*ដើម្បីទទួលបានសេវាទាំងអស់នេះ ដោយឥតគិតថ្លៃសូមទំនាក់ទំនង:*

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**
០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥
jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**
០៥៣ ៧៣៣ ១១១
០១៦ ៩២៦ ៦៥៥
jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**
០៦៣ ២១០ ២៧៧
០១៦ ៥៣៦ ៦៥៥
jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**
០៣៣ ២១០ ២៧៧
០១៦ ៥០៦ ៦៥៥
jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**
០៤៤ ៧១៥ ២៧៧
០១៦ ៦៤៦ ៦៥៥
jc_svayrieng@nea.gov.kh

**អាសយដ្ឋានរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ**
មានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស(NTTI)មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៦៣៥ ៧១៧៧ ឬ ០៨៨ ៦៧៨ ៥៦៧៨ ទូរសារ: ០២៣ ៨៨២ ៧៣៤ អ៊ីម៉ែល: info@nea.gov.kh